**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# សេដ្ឋកិច្ចឌីជីថលកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ មិថុនា ឆ្នាំ២០២១


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **គ្រី លីតា**

**ហេង សុខណា**

សាស្ត្រាចារ្យណែនាំ

**ឡុង ម៉ាមីឌី**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៥

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គ្រី លីតា** និង **ហេង សុខណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៥ ក្រុម D4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមសម្ដែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖**

មាតាបិតារបស់យើងខ្ញុំទាំងពីរនាក់ដែលបានផ្ដល់កំណើត និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូន តាំងពីតូចរហូតធំដឹងក្ដីជាមួយនឹងការទូន្មានប្រៀនប្រដៅពោរពេញទៅដោយព្រហ្មវិហារធម៌។ លោកមានគុណ តែងតែផ្គត់ផ្គង់រូបកូនគ្រប់បែបយ៉ាងអោយបានសិក្សាពីបឋមសិក្សារហូតបានមកដល់ថ្នាក់ឧត្ដមសិក្សា មិនថា ហត់នឿយយ៉ាងណាក្ដី លោកមិនដែលរអ៊ូ ថែមទាំងបានផ្ដល់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត លើកទឹកចិត្តកូន គ្រប់ពេលវេលាអោយចេះតស៊ូព្យាយាម ខិតខំប្រឹងប្រែងមិនថាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ លោកមាន គោលបំណងតែមួយគត់គឺចង់អោយកូនៗទទួលបាននូវការអប់រំដែលពេញលេញ ដើម្បីជាស្ពានឈានទៅរកការ សម្រេចបាននូវគោលបំណង និងក្ដីស្រមៃដែលកូនបានប៉ង។

ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកមន្ត្រីរាជការទាំងអស់ដែលបានខិតខំប្រឹងយកចិត្តទុកដាក់ និងលះបង់អស់ពីកម្លាំង កាយកម្លាំងចិត្តក្នុងការដឹកនាំសាកលវិទ្យាល័យទាំងមូល និងជួយសម្រួលដល់ការសិក្សារបស់យើងខ្ញុំ រួមទាំង បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបណ្ដុះបណ្ដាលគ្រប់មុខវិជ្ជាក៏ដូចជាបានផ្ដល់ដំបូន្មានល្អៗ ដល់យើង ខ្ញុំផងដែរ។

ជាពិសេសសាស្ត្រាចារ្យ **ឡុង ម៉ាមីឌី** ដែលបានចំណាយពេលដ៏មានតម្លៃ ក្នុងការណែនាំ ផ្ដល់ជាគំនិត ល្អៗ និងជាមតិសម្រាប់ការកែសម្រួលអោយការតាក់តែងសរសេរសៀវភៅសារណាមួយក្បាលនេះកាន់តែមាន ភាពប្រសើរឡើង តាំងពីចំណុចផ្ដើមរហូតដល់ទីបញ្ចប់បានដោយជោគជ័យ។

ជាចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរនាក់សូមធ្វើការគោរពដឹងគុណ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាល ជ្រៅ ចំពោះមាតាបិតា រួមទាំងលោកគ្រូ អ្នកគ្រូ បណ្ឌិត សាស្ត្រាចារ្យគ្រប់រូបជួបប្រទះតែសេចក្ដីសុខ សំណាងល្អ ព្រមទាំងពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានចំណាយអស់រយៈពេល៤ឆ្នាំក្នុងការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរនាក់ត្រូវបានជាប់ឈ្មោះនិងបានសម្រេចចិត្តរួមគ្នាធ្វើការសរសេរសៀវភៅសារណាមួយក្បាលនេះ សម្រាប់ជាសមិទ្ធផលចុងក្រោយនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ដែលជាការស្រាវជ្រាវបឋមក្នុងរយៈពេលកំណត់មួយ ដោយបានរួមផ្សំជាមួយនឹងចំណេះដឹងដែលបានសិក្សាអស់រយៈពេល៤ឆ្នាំនៃថ្នាក់បរិញ្ញាបត្រ និងការស្រាវជ្រាវបន្ថែមដើម្បីអភិវឌ្ឍន៍ការសរសេរប្រធានបទនេះអោយបានសម្រេច។

ស្របនៅក្នុងឱកាសនេះយើងបានសម្រេចជ្រើសរើសយកប្រធានបទស្តីពី **"សេដ្ឋកិច្ចឌីជីថលកម្ពុជា"** ដើម្បីធ្វើជាការស្រាវជ្រាវសម្រាប់ធ្វើបទបង្ហាញនៅពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ មូលហេតុដែលជម្រុញអោយយើងខ្ញុំជ្រើសរើសប្រធានបទនេះ គឺដោយសារតែយើងចង់បង្កើតជាកម្រងឯកសារដែលចងក្រងពីសេដ្ឋកិច្ចឌីជីថលជាភាសាខ្មែរដែលមានសារៈសំខាន់សម្រាប់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយគួរសិក្សាស្វែងយល់ ដោយយល់ឃើញថាក្នុងរយៈពេលពីមួយឆ្នាំទៅមួយឆ្នាំ តែងមានការប្រែប្រួលជានិច្ចមិនថាបរិបទសង្គម ឬ សេដ្ឋកិច្ច។ ពិសេសជាងនេះទៅទៀត បច្ចេកវិទ្យាឌីជីថលគឺជាកាតាលីករមួយដែលមានសារៈសំខាន់ក្នុងការបង្កើនអោយមានប្រសិទ្ធភាព និងផលិតភាពក្នុងសេដ្ឋកិច្ចប្រទេសទូទាំងសកលលោករួមទាំងកម្ពុជាផងដែរ ហេតុនេះការយល់ដឹងពីសេដ្ឋកិច្ចឌីជីថល ជាកត្តាមួយដែលអាចជំរុញអោយយុវជនខ្មែរកាន់តែយល់ដឹង និងអាចត្រៀមខ្លួនរួចជាស្រេចក្នុងការអភិវឌ្ឍខ្លួនដើម្បីសម្របជាមួយនឹងការផ្លាស់ប្តូរទៅតាមសម័យឌីជីថលនាសតវត្សទី២១នេះ។

សារណាមួយនេះបានចេញរូបរាងឡើងដោយសារតែមានការខិតខំប្រឹងប្រែង និងឆន្ទៈរួមគ្នាក្នុងការធ្វើការងារជាក្រុមដែលនឹងអាចផ្តល់ផលប្រយោជន៍ទៅកាន់និស្សិតជំនាន់ក្រោយដើម្បីធ្វើជាឯកសារបន្ទាប់បន្សំក្នុងការសិក្សាទាក់ទងទៅនឹងប្រធានបទសេដ្ឋកិច្ចឌីជីថល។ យើងសង្ឃឹមថា ក្រោយពីបានអានកិច្ចការស្រាវជ្រាវនេះហើយអ្នកអាននឹងទទួលបាននូវព័ត៌មានល្អៗ និងទស្សនៈទូលំទូលាយជាងមុនពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល។

ជាចុងក្រោយនេះ យើងទាំងពីរនាក់សូមការអភ័យទោសទុកជាមុនពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងអ្នកដែលបានអានទាំងអស់ ប្រសិនបើមានកំហុសខុសឆ្គងដោយអចេតនាត្រង់អក្ខរាវិរុទ្ធ ឬអត្ថន័យយ៉ាងណាក្តីពីព្រោះថាបទពិសោធន៍ និងការយល់ដឹងរបស់យើងខ្ញុំនៅមានកម្រិត។ យើងនឹងរង់ចាំជានិច្ចចំពោះការរិះគន់ក្នុងន័យស្ថាបនា ពីគ្រប់មជ្ឈដ្ឋានទាំងអស់ដោយសុទ្ធចិត្ត។

# មាតិកា

ទំព័រ

បញ្ជីអក្សរកាត់ ........ vii
បញ្ជីក្រាហ្វិក ........ viii
បញ្ជីឧបសម្ព័ន្ធ ........ ix

# សេចក្តីផ្តើម

១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣
៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣
៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ ៤
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

# ជំពូកទី១
# ការសិក្សាទ្រឹស្តីពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល

១.១. និយមន័យសេដ្ឋកិច្ចឌីជីថល ........ ៨
១.១.១. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ........ ៨
១.១.២. អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ ........ ៨
១.១.៣. ទស្សនៈរបស់លោក Bukht និង Heeks ........ ៩
១.១.៤. ទស្សនៈរបស់ធនាគារពិភពលោក ........ ៩
១. ២. សារៈសំខាន់នៃសេដ្ឋកិច្ចឌីជីថល ........ ១០
១. ៣. ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថល ........ ១៣
១. ៣.១. អាជ្ញាធរខាងរូបិយវត្ថុនៃសិង្ហបុរី ........ ១៣

១.៣.១.១. អត្តសញ្ញាណឌីជីថល.......................................................................................................១៣
១.៣.១.២. សេចក្តីអនុញ្ញាត និងការយល់ព្រម......................................................................................១៣
១.៣.១.៣.ការទូទាត់បែបអន្តរប្រតិបត្តិការ ......................................................................................... ១៤
១.៣.១.៤. ការផ្លាស់ប្តូរទិន្នន័យ ........................................................................................................ ១៤
១.៣.២. គណៈកម្មការអ៊ឺរ៉ុប.................................................................................................................. ១៤
១.៣.២.១. បណ្តាញអ៊ីនធើណេត.......................................................................................................... ១៤
១. ៣.២.២. ធនធានមនុស្ស................................................................................................................. ១៤
១. ៣.២.៣. ការប្រើប្រាស់អ៊ីនធើណេត ................................................................................................. ១៥
១.៣.២.៤. ការដាក់បញ្ចូលនូវបច្ចេកវិទ្យាឌីជីថល ............................................................................... ១៥
១.៣.២.៥. សេវាសាធារណៈដោយប្រើឌីជីថល ..................................................................................... ១៥
១.៣.៣. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ................................................................................................ ១៥
១.៣.៣.១. ការតភ្ជាប់ឌីជីថល ........................................................................................................... ១៦
១.៣.៣.២. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ..................... ១៦
១.៣.៣.៣ ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ .................................................. ១៦
១.៤. ផលប៉ះពាល់អវិជ្ជមាននៃបរិវត្តកម្មឌីជីថលទៅលើសេដ្ឋកិច្ចនិងសង្គម........................................ ១៧
១.៤.១. ផលប៉ះពាល់មកលើសេដ្ឋកិច្ច.................................................................................................. ១៧
១. ៤.១.១. ការផ្លាស់ប្តូររចនាសម្ព័ន្ធពលកម្ម និងការងារ........................................................................ ១៧
១.៤.១.២. ការប្រែប្រួលមូលដ្ឋាននៃការប្រមូលពន្ធ ............................................................................. ១៨
១.៤.១.៣. ការបង្វែរអាទិភាពវិនិយោគសាធារណៈ ............................................................................. ១៨
១.៤.១.៤. គម្លាតឌីជីថល.................................................................................................................. ១៨
១.៤.២. ផលប៉ះពាល់លើសង្គម............................................................................................................. ១៩

១.៤.២.១. ផលប៉ះពាល់ទៅលើប្រពៃណី វប្បធម៌ និងការប្រាស្រ័យទាក់ទង .................................. ១៩
១.៤.២.២. ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន .......................................................... ២០
១.៤.២.៣.ឧក្រិដ្ឋកម្ម និងការគម្រាមគំហែងតាមប្រព័ន្ធបច្ចេកវិទ្យា ............................................ ២០
១.៥. កត្តាដែលឈានទៅរកសេដ្ឋកិច្ចឌីជីថល ............................................................................... ២១
១.៥.១. ពលរដ្ឋឌីជីថល ........................................................................................................ ២១
១.៥.២. ធុរកិច្ចឌីជីថល ......................................................................................................... ២២
១.៥.៣. រដ្ឋាភិបាលឌីជីថល .................................................................................................. ២៤
១.៦. ឧបសគ្គនៃការឈានទៅរកសេដ្ឋកិច្ចឌីជីថល ......................................................................... ២៦
១.៦.១. កង្វះហេដ្ឋារចនាសម្ព័ន្ធឌីជីថល ................................................................................. ២៦
១.៦.២. អក្ខរកម្មឌីជីថលនៅមានកម្រិត ................................................................................... ២៨

## ជំពូកទី២

## ស្ថានភាពទូទៅនៃសេដ្ឋកិច្ចឌីជីថលនៃប្រទេសកម្ពុជា

២.១. ស្ថានភាពសេដ្ឋកិច្ចឌីជីថលនៃប្រទេសកម្ពុជា .......................................................................... ៣០
២.១.១.សន្ទស្សន៍នៃការត្រៀមខ្លួនទៅកាន់ឌីជីថល .................................................................... ៣១
២.១.២. សន្ទស្សន៍នៃការប្រកួតប្រជែងពិភពលោក ...................................................................... ៣២
២.១.៣. សូចនាករឆ្លុះបញ្ចាំងពីសេដ្ឋកិច្ចឌីជីថលកម្ពុជា ................................................................ ៣២
២.១.៣.១. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ................................................................................ ៣២
២.១.៣.២. ការសម្របខ្លួនទៅនឹងបច្ចេកវិទ្យា .............................................................................. ៣៥
២.២.ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការកសាងសេដ្ឋកិច្ចឌីជីថល ........................................................ ៣៧
២.២.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ .......................................................................... ៣៧
២.២.២. ផែនការមេបច្ចេកវិទ្យាគមនាគមន៍ ២០២០ ....................................................................... ៣៨
២.២.៣. គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០ ៣៨

២.២.៤. ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ...... ៤០
២.២.៥. ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ...... ៤១
២.៣. ចំណុចរបត់នៃសេដ្ឋកិច្ចឌីជីថលក្នុងបរិបទកូវីដ១៩ ...... ៤៣
២.៣.១. អ្នកប្រើប្រាស់បណ្តាញអ៊ីនធើណេត ...... ៤៤
២.៣.២. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងការដឹកជញ្ជូន ...... ៤៥
២.៣.៣. កន្លែងការងារ និងឌីជីថលូបនីយកម្ម ...... ៤៥
២.៣.៤.ស្ថានភាពកូវីដ១៩ជម្រុញអោយមានការកើនឡើងអ្នកប្រើប្រាស់e-WALLET ...... ៤៦
២.៣.៥. ឌីជីថលូបនីយកម្មជាផ្លូវទៅកាន់ភាពដូចដើមវិញ ...... ៤៦

## ជំពូកទី៣
## ពលរដ្ឋឌីជីថល

៣.១. និយមន័យពលរដ្ឋឌីជីថល ...... ៤៨
៣.២. ជំនាញដែលពលរដ្ឋឌីជីថលត្រូវការក្នុងសេដ្ឋកិច្ចឌីជីថល ...... ៤៨
៣.២.១. ជំនាញទូទៅនៅក្នុងសេដ្ឋកិច្ចឌីជីថល ...... ៤៨
៣.២.១.១. ធនាគារពិភពលោក ...... ៤៨
៣.២.១.២. វេទិកាសេដ្ឋកិច្ចពិភពលោក ...... ៤៩
៣.២.២. ជំនាញឌីជីថល ...... ៥០
៣.២.២.១. ជំនាញឌីជីថលកម្រិតមូលដ្ឋាន ...... ៥០
៣.២.២.២.ជំនាញបន្ទាប់បន្សំផ្នែកឌីជីថល ...... ៥០
៣.២.២.៣. ជំនាញខ្ពស់ និងឯកទេស ...... ៥១
៣.៣. អក្ខរកម្មឌីជីថល ...... ៥១
៣.៤. គម្លាតជំនាញនៅក្នុងប្រទេសកម្ពុជា ...... ៥២
៣.៥. ទស្សនៈយុវជនភ្នំពេញមកលើសេដ្ឋកិច្ចឌីជិថល ...... ៥៣

៣.៦. ការកសាងពលរដ្ឋឌីជីថល ..................................................... ៥៤
៣.៦.១. វិធានការគោលនយោបាយផ្នែកអ្នកដឹកនាំឌីជីថល ..................................................... ៥៤
៣.៦.២. វិធានការផ្នែកបណ្ដុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ..................................................... ៥៥
៣.៦.៣. វិធានការគោលនយោបាយផ្នែកពលរដ្ឋឌីជីថល ..................................................... ៥៦

## ជំពូកទី៤
## ការវិភាគ និងបកស្រាយទិន្នន័យ

៤.១. ស្ថានភាពទូទៅនៃយុវជនដែលចូលរួមការស្ទង់មតិ ..................................................... ៥៩
៤.១.១. ភេទ និងអាយុ ..................................................... ៥៩
៤.១.២. ទីតាំងរស់នៅ ..................................................... ៦០
៤.១.៣. កម្រិតនៃការអប់រំ និងស្ថានភាពការងារ ..................................................... ៦០
៤.១.៤. កម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស ..................................................... ៦១
៤.២. ការយល់ដឹងពីសេដ្ឋកិច្ចឌីជីថល ..................................................... ៦២
៤.៣. ការប្រើប្រាស់បណ្ដាញ ..................................................... ៦៣
៤.៣.១. ប្រភេទបណ្ដាញដែលប្រើប្រាស់ ..................................................... ៦៣
៤.៣.២. កម្រិតល្បឿននៃបណ្ដាញ ..................................................... ៦៤
៤.៣.៣. កម្រិតនៃការពេញចិត្តល្បឿននិងតម្លៃនៃបណ្ដាញតភ្ជាប់ ..................................................... ៦៥
៤.៣.៤. រយៈពេលនៃការប្រើប្រាស់បណ្ដាញអ៊ីនធើណេត ..................................................... ៦៦
៤.៤. ការចាប់យកឌីជីថល ..................................................... ៦៦
៤.៤.១. ឧបករណ៍ឌីជីថល ..................................................... ៦៦
៤.៤.២. ការប្រើប្រាស់សេវាកម្មបែបឌីជីថល ..................................................... ៦៧
៤.៥. កម្រិតជំនាញនៃយុវជន ..................................................... ៧១
៤.៥.១. ការប្រើប្រាស់ភាសាបរទេស ..................................................... ៧១

៤.៥.២. ជំនាញដែលសំខាន់ក្នុងសេដ្ឋកិច្ចឌីជីថល........................................................ ៧២

៤.៥.៣. ជំនាញឌីជីថល......................................................................................................៧៣

៤.៥.៤. កម្រិតនៃការត្រៀមខ្លួនសម្រាប់ការឈានទៅរកសេដ្ឋកិច្ចឌីជីថល........................................ ៧៤

៤.៦. ការយល់ដឹងពីពលរដ្ឋឌីជីថល...................................................................................... ៧៥

៤.៦.១. បញ្ហាប្រឈមនៃពលរដ្ឋឌីជីថល ................................................................................ ៧៥

៤.៦.២. កត្តាជំរុញអោយមានពលរដ្ឋឌីជីថល........................................................................... ៧៥

**សេចក្តីសន្និដ្ឋាន**.................................................................................................................... ៧៧

**អនុសាសន៍**...........................................................................................................................៧៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ទ.ប.គ.ព | ៖ | ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| ប.គ.ព | ៖ | បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន |
| ICT | ៖ | Internet Communication Technology |
| WEF | ៖ | World Economic Forum |
| GDP | ៖ | Gross Domestic Product |
| CDRI | ៖ | Cambodia Development Resource Institute |
| OCED | ៖ | Organization for Co-operation and Development |

# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១៖ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័ត..........................................................................................៣៣
ក្រាហ្វិកទី២៖ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទអចល័ត........................................................................................៣៣
ក្រាហ្វិកទី៣៖ ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេតចល័ត..................................................................................៣៤
ក្រាហ្វិកទី៤៖ ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេតអចល័ត................................................................................៣៥
ក្រាហ្វិកទី៥៖ ភេទនៃអ្នកចូលរួមក្នុងការវាស់ស្ទង់មតិ.................................................................................៥៩
ក្រាហ្វិកទី៦៖ ទីតាំងរស់នៅនៃអ្នកចូលរួមក្នុងការស្ទង់មតិ.........................................................................៦០
ក្រាហ្វិកទី៧៖ កម្រិតនៃការអប់រំ...................................................................................................................៦០
ក្រាហ្វិកទី៨៖ ស្ថានភាពការងារ....................................................................................................................៦១
ក្រាហ្វិកទី៩៖ កម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស.....................................................................................៦២
ក្រាហ្វិកទី១០៖ កម្រិតនៃការយល់ដឹងពីសេដ្ឋកិច្ចឌីជីថល...............................................................................៦២
ក្រាហ្វិកទី១១៖ ប្រភេទបណ្តាញតភ្ជាប់ដែលនិយមប្រើប្រាស់..........................................................................៦៣
ក្រាហ្វិកទី១២៖ កម្រិតល្បឿននៃបណ្តាញតភ្ជាប់............................................................................................៦៤
ក្រាហ្វិកទី១៣៖ កម្រិតល្បឿននៃបណ្តាញតភ្ជាប់ និងតំបន់...............................................................................៦៥
ក្រាហ្វិកទី១៤៖ កម្រិតនៃការពេញចិត្តល្បឿននិងតម្លៃបណ្តាញតភ្ជាប់..................................................................៦៥
ក្រាហ្វិកទី១៥៖ រយៈពេលនៃការប្រើប្រាស់បណ្តាញអ៊ីនធើណេត........................................................................៦៦
ក្រាហ្វិកទី១៦៖ ឧបករណ៍ឌីជីថលដែលយុវជនប្រើប្រាស់................................................................................៦៧
ក្រាហ្វិកទី១៧៖ ការប្រើប្រាស់សេវាកម្មបែបឌីជីថល........................................................................................៦៩
ក្រាហ្វិកទី១៨៖ កម្រិតនៃការប្រើប្រាស់សេវាកម្មបែបឌីជីថល.........................................................................៧០
ក្រាហ្វិកទី១៩៖ បញ្ហាប្រឈមនៃការប្រើប្រាស់សេវាកម្មឌីជីថល.......................................................................៧១
ក្រាហ្វិកទី២០៖ ការប្រើប្រាស់ភាសាបរទេស....................................................................................................៧២
ក្រាហ្វិកទី២១៖ កម្រិតជំនាញសំខាន់ក្នុងសេដ្ឋកិច្ចឌីជីថល.............................................................................៧៣
ក្រាហ្វិកទី២២៖ កម្រិតជំនាញឌីជីថល..............................................................................................................៧៤
ក្រាហ្វិកទី២៣៖ កម្រិតនៃការត្រៀមខ្លួនសម្រាប់ការឈានទៅរកសេដ្ឋកិច្ចឌីជីថល.................................................៧៤
ក្រាហ្វិកទី២៤៖ កម្រិតនៃការយល់ដឹងពីពលរដ្ឋឌីជីថល...................................................................................៧៥

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១៖ កម្រងសំណួរ

ឧបសម្ព័ន្ធទី២៖ សន្ទានុក្រម

ឧបសម្ព័ន្ធទី៣៖ គំនូសបំព្រួញស្តីពីអន្តរសកម្មរវាងតួអង្គសំខាន់ៗ ផ្អែកលើមូលដ្ឋានបច្ចេកវិទ្យាឌីជីថល

ឧបសម្ព័ន្ធទី៤៖ គោលការណ៍ និងក្របខណ្ឌកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា

ឧបសម្ព័ន្ធទី៥៖ ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចឌីជីថលប្រទេសកម្ពុជា

ឧបសម្ព័ន្ធទី៦៖ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទ

ឧបសម្ព័ន្ធទី៧៖ ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេត

ឧបសម្ព័ន្ធទី៨៖ Global Competitiveness Index 2018-2019

ឧបសម្ព័ន្ធទី៨៖ Network Readiness Index 2019

ឧបសម្ព័ន្ធទី៩៖ Network Readiness Index 2020

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានកំណើនលូតលាស់លឿនបំផុតនៅអាស៊ីដែលមានអត្រាផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំជាមធ្យម ៨,១%។[1] កំណើនសេដ្ឋកិច្ចក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយបានធ្វើឱ្យប្រទេសកម្ពុជាវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងរចនាសម្ព័ន្ធសង្គមដែលបានធ្វើការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស នាំអោយមានការបង្កើតឱកាសការងារ និងលើកកម្ពស់ប្រជាជនរាប់លាននាក់ចេញពីភាពក្រីក្រ បណ្តាលអោយប្រទេសកម្ពុជាបានប្រែក្លាយទៅជាប្រទេសមួយដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥។ ថ្វីត្បិតតែសេដ្ឋកិច្ចមានការរីកចម្រើនល្អក៏ពិតមែនតែចក្ខុវិស័យនៃកំណើនសេដ្ឋកិច្ចរយៈពេលវែងរបស់កម្ពុជា អាចនឹងត្រូវបានរារាំងដោយសារតែមានការប្រកួតប្រជែងក្នុងកម្រិតទាបធៀបជាមួយនឹងប្រទេសដទៃ។ តាមរយៈរបាយការណ៍ប្រកួតប្រជែងសមត្ថភាពសកលឆ្នាំ២០១៨ ប្រទេសកម្ពុជាត្រូវបានចាត់ទុកជាប្រទេសមួយដែលស្ថិតនៅក្នុងលំដាប់លេខរៀងដែលទាបបើធៀបជាមួយនឹងបណ្តាប្រទេសផ្សេងទៀតនៅក្នុងសមាជិកអាស៊ាន។ ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ ១១០ ក្នុងចំណោម ១៤០ ប្រទេសកាលពីឆ្នាំ២០១៨ ដែលបញ្ជាក់អោយឃើញថាកម្ពុជាធ្លាក់ចុះពីចំណាត់ថ្នាក់លេខ១០៩ មកដល់១១០នៅក្នុងរបាយការណ៍នៃការប្រកួតប្រជែងសមត្ថភាពសកលកាលពីឆ្នាំ២០១៧ដោយសារតែកម្ពុជាត្រូវបានរារាំងដោយកម្លាំងពលកម្មដែលការអប់រំនៅមានកម្រិត កង្វះស្ថាប័ននិងហេដ្ឋារចនាសម្ព័ន្ធ កម្រិតនៃភាពទំនើបនិងការច្នៃប្រឌិតអាជីវកម្មនៅមានកម្រិត។[2] អាស្រ័យហេតុនេះហើយ ប្រទេសកម្ពុជាមិនអាចពឹងផ្អែកលើកត្តាជំរុញកំណើនសេដ្ឋកិច្ចតាមរបៀបដដែលដូចពេលពីរទសវត្សចុងក្រោយនេះទេ ព្រោះកន្លងមកប្រទេសកម្ពុជាបានពឹងផ្អែកយ៉ាងចម្បងទៅលើ សម្លៀកបំពាក់ អង្ករ ទេសចរណ៍ និងសំណង់ ដោយបានចាត់ទុកវាជាឧស្សាហកម្មដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ចកម្ពុជា។ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយសុខុមាលភាពក្នុងរយៈពេលវែង ប្រទេសកម្ពុជាត្រូវការធ្វើពិពិធកម្ម និងធ្វើទំនើបកម្មសេដ្ឋកិច្ចរបស់ខ្លួនដោយធ្វើការចាប់យកបរិវត្តកម្មឌីជីថលក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល។

សេដ្ឋកិច្ចឌីជីថលអាចជំរុញអោយមានកំណើន និងផលិតភាពរួមទាំងជួយអោយមានការអភិវឌ្ឍប្រកបដោយបរិយាប័ន្នតាមវិធីច្រើនយ៉ាង។ កាលណាដែលអ្នកប្រើប្រាស់ សហគ្រាស និងរដ្ឋាភិបាល ចាប់យកបច្ចេកវិទ្យាឌីជីថល នោះវានឹងធ្វើអោយមានកំណើនផលិតភាពនៃធនធាន និងកម្លាំងពលកម្ម រួមទាំងបណ្តាលអោយ

[1] ធនាគារអភិវឌ្ឍន៍អាស៊ី, *Asia's New Tiger Economy (២០១៦)*

[2] វេទិកាសេដ្ឋកិច្ចពិភពលោក, *World Competitiveness Index (២០១៨)*

មានការចូលរួមនៅក្នុងខ្សែសង្វាក់តម្លៃជាសាកលផងដែរ។[3] បច្ចេកវិទ្យាឌីជីថលជម្រុញអោយសហគ្រាសនិងរដ្ឋាភិបាលអាចធ្វើការនាំមកនូវផលិតផល ឬសេវាកម្មកាន់តែមានផលិតភាព និងប្រសិទ្ធភាព ។ លើសពីនេះទៅទៀត សេដ្ឋកិច្ចឌីជីថលចូលរួមចំណែកយ៉ាងសកម្មនៅក្នុងសង្គមមួយដែលប្រកបដោយបរិយាប័ន្ន ដោយសារតែមានការចំណាយថ្លៃប្រតិបត្តិការណ៍តិចជាងមុន កាត់បន្ថយការផ្តល់ព័ត៌មានដែលមានការកេងប្រវ័ញ្ច(information asymmetries) និងបង្កើនអោយមានលំនឹងសេដ្ឋកិច្ច។[4] ទោះជាយ៉ាងណាក៏ដោយ ការចាប់យកនូវសេដ្ឋកិច្ចឌីជីថលមិនមែនគ្មានបញ្ហាប្រឈមនោះទេ ព្រោះថាបរិវត្តកម្មឌីជីថលអាចធ្វើឱ្យមានការរំខានដល់ទីផ្សារការងារ តាមរយៈការបង្កើតការងារថ្មី បំផ្លាញការងារចាស់ និងផ្លាស់ប្តូរសមាសភាពការងារដែលមានស្រាប់។ កម្មករដែលអាចចាប់យកជំនាញឌីជីថលបានលឿននឹងទទួលបានអត្ថប្រយោជន៍ពីនិន្នាការនេះ ប៉ុន្តែអ្នកដែលចាប់យកជំនាញឌីជីថលយឺតរឺមិនចេះសម្របខ្លួនជាមួយនឹងបរិបទថ្មីនេះនឹងឈានទៅរកការបាត់បង់ឱកាសការងារនាពេលដែលបច្ចេកវិទ្យាកាន់តែមានភាពជឿនលឿន។[5]

ដើម្បីបង្កើនការប្រកួតប្រជែង និងចាប់យកឱកាសនៃការវិវត្តផ្នែកបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស រដ្ឋាភិបាលកម្ពុជាបានប្រកាសផែនការមួយ នៅឆ្នាំ២០១៨ ដើម្បីធ្វើការត្រៀមផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចឌីជីថល នៅឆ្នាំ២០២៣។ការសម្រេចបាននូវគោលដៅដែលប្តូរទៅជាសេដ្ឋកិច្ចឌីជីថលនេះនឹងធ្វើអោយមានការបង្កើនការប្រកួតប្រជែង ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការលើកកម្ពស់ជំនាញ និងការចូលរួមកាន់តែស៊ីជម្រៅនៅក្នុងខ្សែសង្វាក់តម្លៃក្នុងតំបន់និងពិភពលោក។ ដោយស្របតាមមហិច្ឆតារបស់ប្រទេសកម្ពុជាដែលថានឹងសម្រេចឱ្យបានក្នុងការប្រែខ្លួនជាប្រទេសមានចំណូលមធ្យមខ្ពស់ត្រឹមឆ្នាំ២០៣០និងជាប្រទេសដែលមានចំណូលខ្ពស់នាឆ្នាំ២០៥០កាលពីខែ ឧសភា ឆ្នាំ២០២១ កន្លងទៅនេះ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិបានរៀបចំ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលជាផ្នែកដ៏សំខាន់នៅក្នុងការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ១៩ ដោយសារតែកាលពីឆ្នាំ២០២០នេះកំណើនសេដ្ឋកិច្ចកម្ពុជាមានការធ្លាក់ចុះរហូតដល់ -៣.១ភាគរយ[6]។ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជានឹងអាចជួយអោយមានកំណើនសេដ្ឋកិច្ចឡើងវិញតាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលការទាក់ទាញវិនិយោគក្នុងស្រុកនិងពីបរទេសការជម្រុញការបង្កើតធុរកិច្ចថ្មី ការបង្កើនផលិតភាព និងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច ។

---

[3] Miller, B. និងR.D. Atkinson, *Raising European productivity growth through ICT (២០១៤)*

[4] ធនាគារពិភពលោក, *Digital Divident (២០១៦)*

[5] ហេង ភក្តី, *Embracing the Digital Economy (២០១៨)*

[6] ធនាគារពិភពលោក, *Cambodia Overview (២០២១)*

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

សន្ទុះកំណើនសេដ្ឋកិច្ចកម្ពុជាមានសញ្ញាថមថយ ចាប់តាំងពីមានវិបត្តិកូវីដ១៩ ដោយសារតែកម្ពុជាត្រូវបានរងផលប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរមកលើវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម ដែលជាផ្នែកចម្បងនៃសេដ្ឋកិច្ចកម្ពុជាពីព្រោះថាកូវីដ១៩ បានធ្វើការវាយលុកយ៉ាងខ្លាំងដែលបណ្តាលអោយឈានទៅមានការបិទខ្ទប់ការរក្សាគម្លាត ជាហេតុនាំអោយប្រជាជនកម្ពុជាត្រូវរស់នៅតាមបែបថ្មី ដើម្បីរក្សាសុវត្ថិភាពរបស់ខ្លួនពីជំងឺដ៏កាចសាហាវនេះ។ ការផ្លាស់ប្តូររបៀបរស់នៅក៏ដូចជាការធ្វើសកម្មភាពសេដ្ឋកិច្ច ធ្វើអោយមានការប៉ះទង្គិចទៅនឹងអ្នកដែលប្រកបការងារមួយចំនួនធំ ដែលបណ្តាលអោយមានកំណើនអវិជ្ជមានដល់សកម្មភាពសេដ្ឋកិច្ចទាំងមូល។ ដើម្បីស្តារឡើងនូវសេដ្ឋកិច្ចក្នុងប្រទេសឡើងវិញ តម្រូវអោយកម្ពុជាគិតគូរ និងរៀបចំម៉ូដែលកំណើនថ្មី ដែលមានភាពឆ្លើយតប និងភាពធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត។ ជាមួយនឹងស្ថានភាពស្រួចស្រាល់នេះ វិស័យឌីជីថលត្រូវបានមើលឃើញថាជាប្រភពកំណើនថ្មី ដែលមានសក្តានុពលខ្ពស់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចកម្ពុជាឱ្យមានវឌ្ឍនភាពឡើងវិញ មិនថានៅក្នុងស្ថានភាពដ៏លំបាកក្នុងបរិបទកូវីដ១៩នេះក៏ដោយ។ អ្វីដែលសំខាន់ជាងនេះទៅទៀត កម្រិតនៃការប្រកួតប្រជែងប្រទេសកម្ពុជាស្ថិតនៅក្នុងកម្រិតមួយដែលទាបនៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសផ្សេងទៀតនៅក្នុងអាស៊ានដោយសារតែកម្រិតនៃការចាប់យកឌីជីថល ហេដ្ឋារចនាសម្ព័ន្ធឌីជីល និងចំណេះដឹងពាក់ព័ន្ធនឹងឌីជីថលនៅមានកម្រិតនៅឡើយ។

ដោយសារតែកត្តាដែលបានសបញ្ជាក់ខាងលើនេះហើយ ទើបយើងខ្ញុំបានធ្វើការជ្រើសរើសយកប្រធានបទ **សេដ្ឋកិច្ចឌីជីថលកម្ពុជា** មកធ្វើការសិក្សាដោយលើកឡើងនូវចំណោទបញ្ហាដូចខាងក្រោមៈ

- តើសេដ្ឋកិច្ចឌីជីថលនៅប្រទេសកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេច?
- តើពលរដ្ឋឌីជីថលត្រូវត្រៀមខ្លួនយ៉ាងណាខ្លះក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល?
- តើយុវជនកម្ពុជាមានទស្សនៈយ៉ាងដូចម្តេចចំពោះបញ្ហាប្រឈមនៃពលរដ្ឋឌីជីថល និងកត្តាដែលជម្រុញអោយមានពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះខ្លឹមសារនៃសារណាទាំងមូល មានគោលបំណងដូចតទៅៈ

- ឈ្វេងយល់ពីស្ថានភាពទូទៅ និងការវិវត្តនៃសេដ្ឋកិច្ចឌីជីថលនៅក្នុងប្រទេសកម្ពុជា
- ឈ្វេងយល់ពីរបៀបនៃការត្រៀមខ្លួនដើម្បីឆ្លើយតបទៅនឹងសេដ្ឋកិច្ចឌីជីថល
- ឈ្វេងយល់ពីអត្ថប្រយោជន៍និងបញ្ហាប្រឈមនៃសេដ្ឋកិច្ចឌីជីថល
- ឈ្វេងយល់ជំនាញដែលយុវជនត្រូវមាន ដើម្បីឈានទៅរកការរីកចំរើននៃសេដ្ឋកិច្ចឌិជីថល

- ឈ្វេងយល់ពីទស្សនៈយុវជនកម្ពុជាមកលើបញ្ហាប្រឈមនៃពលរដ្ឋឌីជីថល និងកត្តាដែលជម្រុញអោយមានពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល

## ៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ក្នុងកិច្ចការស្រាវជ្រាវប្រធានបទស្តីពី **សេដ្ឋកិច្ចឌីជីថលកម្ពុជា** ក្រុមយើងខ្ញុំផ្តោតសំខាន់តែទៅលើពលរដ្ឋឌីជីថលដែលជាចំណែកមួយដ៏សំខាន់នៅក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល ដែលយើងនឹងធ្វើការវាស់ស្ទង់មតិដើម្បីធ្វើការឈ្វេងយល់ពីទស្សនៈរបស់យុវជនទៅលើបញ្ហាប្រឈមនៃពលរដ្ឋឌីជីថលនិងកត្តាដែលជម្រុញអោយមានពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថលតែប៉ុណ្ណោះ។ ចំពោះសំណាកគឺយើងធ្វើការសួរតែយុវជនដែលមានអាយុចន្លោះពី ១៥ ទៅ ៣៥ ឆ្នាំ ដែលរស់នៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

មួយវិញទៀត ក្រុមយើងខ្ញុំធ្វើការសិក្សាចន្លោះឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០ ដោយផ្អែកលើឯកសារដែលមានជាក់ស្តែងនិយាយពីលក្ខណៈទូទៅនៃស្ថានភាពសេដ្ឋកិច្ចឌីជីថលនៅត្រឹមឆ្នាំ២០២០។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវពីប្រធានបទ "**សេដ្ឋកិច្ចឌីជីថលកម្ពុជា**" មានដូចខាងក្រោម៖

➢ **ចំពោះសេដ្ឋកិច្ច និង សង្គម៖**

- យល់ដឹងពីស្ថានភាពទូទៅនៃសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា
- យល់ដឹងពីការត្រៀមខ្លួនអោយបានរួចរាល់ក្នុងការឆ្លើយតបទៅនឹងសេដ្ឋកិច្ចឌីជីថល
- មានការចងក្រងឯកសារដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថលជាភាសាខ្មែរ ដែលជាប្រធានបទមួយយ៉ាងថ្មីស្រឡាង និងល្អសម្រាប់យុវជនកម្ពុជាជំនាន់ក្រោយ
- ទទួលបានការយល់ដឹងពីទស្សនៈយុវជនកម្ពុជាមកលើបញ្ហាប្រឈមនៃពលរដ្ឋឌីជីថល និងកត្តាដែលជម្រុញអោយមានពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល

➢ **សម្រាប់អ្នកស្រាវជ្រាវ ៖**

- យល់ដឹងអំពីចំណេះដឹងបន្ថែមដែលផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តី
- ទទួលបានចំណេះដឹងផ្នែកទ្រឹស្តី និងការវិភាគទិន្នន័យជាក់ស្តែង
- ជួយពង្រឹងបន្ថែមនូវចំណេះដឹង និងការយល់ដឹងទៅលើទ្រឹស្តីដែលបានសិក្សាកន្លងមក
- បង្កើនឯកសារទាក់ទងទៅនឹងចំណេះដឹងស្តីពីសេដ្ឋកិច្ចឌីជីថល
- អាចជួយអោយនិស្សិតជំនាន់ក្រោយសិក្សាបន្ថែមទៀតដោយមានភាពងាយស្រួល

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងដោយប្រើប្រាស់ វិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ ដែលមានទាំងបែបគុណវិស័យ(Qualitative Method) និងបរិមាណវិស័យ (Quantitative Method) ដែលបានធ្វើឡើងតាមរបៀបពណ៌នាពន្យល់ និងប្រើស្ថិតិពិពណ៌នាសម្រាប់ជំនួយក្នុងការបកស្រាយ និងបញ្ជាក់អោយកាន់តែច្បាស់។

### ៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ ការប្រមូលព័ត៌មាន និងទិន្នន័យសម្រាប់ការស្រាវជ្រាវនេះពឹងផ្អែកទៅលើវិធីសាស្ត្រចម្រុះដែលមាន វិធីសាស្ត្រប្រមូលទិន្នន័យបន្ទាប់បន្សំ (Secondary data) និងទិន្នន័យចម្បង (Primary data) ជាទិន្នន័យដែលបានមកពីការស្ទង់មតិតាមប្រព័ន្ធអនឡាញសម្រាប់ការវិភាគលទ្ធផលស្រាវជ្រាវ។

- ទិន្នន័យចម្បង (Primary data)៖ យើងបានធ្វើការវាស់ស្ទង់មតិតាមប្រព័ន្ធអនឡាញដោយប្រើកម្មវិធី Google Form ដោយមានការរៀបចំជាកម្រងសំណួរជាភាសាខ្មែរក្នុងការចោទសួរទៅកាន់យុវជនដើម្បីវិភាគពីការយល់ដឹងពីបញ្ហាប្រឈមនៃពលរដ្ឋឌីជីថល និងកត្តាដែលជម្រុញអោយមានពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល។ កម្រងសំណួរទាំងអស់មានចំនួន ២៤ ដែលក្នុងនោះមានសំណួរបិទចំនួន ២២ និងសំណួរបើកចំនួន ២។ យើងធ្វើការជ្រើសរើសយកការស្ទង់មតិតាមប្រព័ន្ធអនឡាញនេះ ដោយសារតែការស្រាវជ្រាវនិងប្រមូលទិន្នន័យស្ថិតនៅក្នុងកំឡុងពេលបរិបទកូវីដ១៩ធ្វើអោយយើងមានបញ្ហាពិបាកនៅក្នុងការចុះសម្ភាសយុវជនផ្ទាល់។
- ទិន្នន័យបន្ទាប់បន្សំ (Secondary data)៖ ឯកសារដែលត្រូវបានបោះពុម្ពផ្សាយដោយស្ថាប័នផ្សេងៗកន្លងមកដែលទាក់ទងនឹងសេដ្ឋកិច្ចឌីជីថលដែលមាននៅក្នុងគេហទំព័រផ្លូវការរបស់ស្ថាប័នផ្សេងៗដូចជា ធនាគារពិភពលោក (World Bank), វេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) វិទ្យាស្ថានធនធានអភិវឌ្ឍន៍កម្ពុជា (CDRI) វិទ្យាស្ថានអ៊ីនរិច (Enrich Institute) អង្គការតម្លាភាព ធនាគារជាតិកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្សេងៗទៀតជាច្រើន។

### ៦.២. ដំណើរការនៃការជ្រើសរើសសំណាក

យើងខ្ញុំបានជ្រើសរើសសំណាកចំនួន ៣៩០ នាក់ ដែលសំណាកទាំងនោះត្រូវបានជ្រើសរើសចៃដន្យក្នុងចំណោមយុវជនដែលមានអាយុចន្លោះពី ១៥ ឆ្នាំទៅ ៣៥ឆ្នាំ ដែលមានកម្រិតអប់រំថ្នាក់វិទ្យាល័យ បរិញ្ញាបត្រ និងអនុបណ្ឌិត ដែលធ្វើការរស់នៅ តំបន់៣ផ្សេងគ្នា គឺភ្នំពេញ ទីរួមខេត្ត/ក្រុង និងតំបន់ដាច់ស្រយាលដែលនៅតាមបណ្តាខេត្ត។ វិធីសាស្ត្រនៅក្នុងដំណើរការនៃការជ្រើសរើសសំណាកនេះ គឺប្រើប្រាស់វិធី "Convenience Sampling Method" ដោយធ្វើការផ្ញើកម្រងសំណួរទាំងនោះបន្តទៅកាន់យុវជនតាមបណ្តាញសង្គមដូចជា

ហ្វេសប៊ុក (Facebook) តេលេក្រាម ( Telegram) ជាដើម ពីព្រោះថាវាជាវិធីមួយដែលមានភាពងាយស្រួល និងអាចប្រមូលទិន្នន័យបានច្រើនក្នុងបរិបទកូវីដ១៩នេះ។

### ៦.៣. វិធីសាស្ត្រវិភាគទិន្នន័យ

ក្រោយទទួលបានព័ត៌មាន និងទិន្នន័យដែលប្រមូលបានពីការស្ទង់មតិតាមរយៈកម្មវិធី Google Form យើងខ្ញុំធ្វើការបញ្ចូលទិន្នន័យនោះទៅក្នុងកម្មវិធី Microsoft Excel ដើម្បីធ្វើការវិភាគទៅតាមអ្វីដែលខ្ញុំចង់បាន បន្ទាប់មកបង្កើតចេញជាក្រាហ្វិក ហើយបកស្រាយលទ្ធផលទាំងអស់ចូលទៅក្នុងកម្មវិធី Microsoft Word។

**ក. ការវិភាគទិន្នន័យបែបគុណភាព** ( Qualitative data analysis )

ទិន្នន័យបែបគុណភាព គឺជាទិន្នន័យដែលធ្វើការឆ្លុះបញ្ចាំងពីទស្សនៈយល់ឃើញរបស់យុវជនមកលើបញ្ហាអ្វីដែលរារាំងការអភិវឌ្ឍពលរដ្ឋឌីជីថល និងអ្វីដែលគួរធ្វើដើម្បីជម្រុញអោយមានការកើនឡើងពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល។ ទិន្នន័យប្រភេទនេះ មិនបានស្តែងចេញជារង្វាស់ ឬជាតួលេខនោះទេ។ ទិន្នន័យទាំងនេះត្រូវបានយកមកធ្វើការវិភាគទៅតាមប្រធានបទ ហើយបកស្រាយជាគំនិតតាមផ្នែកនីមួយៗក្នុងការសិក្សា។

**ខ. ការវិភាគទិន្នន័យបែបបរិមាណ** ( Quantitative data analysis )

ទិន្នន័យបែបបរិមាណ គឺជាទិន្នន័យដែលទាក់ទងនឹងរង្វាស់ ឬជាតួលេខដូចជា កម្រិតនៃការអប់រំ ស្ថានភាពការងារ កម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស កម្រិតនៃការយល់ដឹងពីសេដ្ឋកិច្ចឌីជីថល។ ទិន្នន័យទាំងអស់ដែលទទួលបានពីការវិភាគក៏ត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការវិភាគបែបពណ៌នាដែលបង្ហាញតាមរយៈតារាង និងក្រាហ្វិកផ្សេងៗ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណាបញ្ចប់ការសិក្សាដែលលើកឡើងពី **"សេដ្ឋកិច្ចឌីជីថលកម្ពុជា"** នេះយើងបានបែងចែកជា ៦ផ្នែកសំខាន់ៗរួមមាន៖

- **សេចក្តីផ្តើម៖** នៅក្នុងចំណុចនេះនឹងមានបញ្ចូលនូវចំណុចមួយចំនួនដូចជា លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និង រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី១៖ ការសិក្សាទ្រឹស្តីពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល** ក្នុងជំពូកនេះ ក្រុមយើងខ្ញុំបានធ្វើការបកស្រាយនិយមន័យសេដ្ឋកិច្ចឌីជីថលពីបណ្តាស្ថាប័នផ្សេងៗគ្នា ក៏ដូចជាសារៈសំខាន់នៃសេដ្ឋកិច្ចឌីជីថល ផលប៉ះពាល់អវិជ្ជមាននៃបរិវត្តកម្មឌីជីថលទៅលើសេដ្ឋកិច្ចនិងសង្គម ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះសម្រាប់

សេដ្ឋកិច្ចឌីជីថល កត្តាដែលឈានទៅរកសេដ្ឋកិច្ចឌីជីថល និងឧបសគ្គនៃការឈានទៅរកសេដ្ឋកិច្ចឌីជីថល។

- **ជំពូកទី២៖ ស្ថានភាពទូទៅនៃសេដ្ឋកិច្ចឌីជីថលនៃប្រទេសកម្ពុជា** នៅក្នុងជំពូកនេះ យើងនឹងធ្វើការលើកឡើងពីស្ថានភាពសេដ្ឋកិច្ចឌីជីថលនៅក្នុងប្រទេសកម្ពុជា ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល និងចំណុចរបត់នៃសេដ្ឋកិច្ចឌីជីថលនៅក្នុងបរិបទកូវីដ១៩។
- **ជំពូកទី៣៖ ពលរដ្ឋឌីជីថល** នៅក្នុងជំពូកនេះនឹងធ្វើការលើកយកពី និយមន័យនៃពលរដ្ឋឌីជីថល ជំនាញដែលសំខាន់សម្រាប់ពលរដ្ឋឌីជីថលក្នុងសេដ្ឋកិច្ចឌីជីថល គម្លាតជំនាញនៃយុវជនក្នុងប្រទេសកម្ពុជា ទស្សនៈយុវជនដែលរស់នៅភ្នំពេញមកលើសេដ្ឋកិច្ចឌីជីថល និងគោលនយោបាយដែលគាំទ្រការកសាងពលរដ្ឋឌីជីថល។
- **ជំពូកទី៤៖ ការវិភាគ និងបកស្រាយទិន្នន័យ** នៅក្នុងជំពូកនេះយើងធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានពីការស្ទង់មតិតាមអនឡាញ ទៅជាក្រាហ្វិកដែលលើកឡើងអំពីស្ថានភាពទូទៅនៃអ្នកដែលចូលរួមក្នុងការស្ទង់មតិ ការយល់ដឹងរបស់យុវជនអំពីសេដ្ឋកិច្ចឌីជីថល ស្ថានភាពនៃការប្រើប្រាស់បណ្ដាញ ការចាប់យកឌីជីថល កម្រិតជំនាញនៃយុវជន និងការយល់ដឹងពីពលរដ្ឋឌីជីថលដែលធ្វើការផ្ដល់ជាមតិយោបល់មកលើបញ្ហាប្រឈម និងកត្តាជំរុញអោយមានពលរដ្ឋឌីជីថល។
- **សន្និដ្ឋាន និងអនុសាសន៍៖** ជាចំណុចចុងក្រោយបង្អស់ដែលនឹងធ្វើការបង្ហាញពីចំណុចសំខាន់ៗដែលត្រូវបានរកឃើញ និងថែមទាំងមានភ្ជាប់ជាមួយនឹងមតិយោបល់មួយចំនួនដែលជាអនុសាសន៍ចំពោះប្រធានបទមួយនេះទៀតផង។

# ជំពូកទី១

# ការសិក្សាទ្រឹស្តីពាក់ព័ន្ធនឹងសេដ្ឋ
# កិច្ចឌីជីថល

# ជំពូកទី១

# ការសិក្សាទ្រឹស្តីពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល

## ១.១. និយមន័យសេដ្ឋកិច្ចឌីជីថល

ការកំណត់និយមន័យសេដ្ឋកិច្ចឌីជីថល និងវិសាលភាពគ្របដណ្តប់នៃសេដ្ឋកិច្ចឌីជីថលនៅមិនទាន់មានភាពជាក់លាក់ និងមានលក្ខខណ្ឌស្តង់ដាររួមណាមួយនៅឡើយទេ ដែលជាហេតុធ្វើអោយនិយមន័យរបស់សេដ្ឋកិច្ចឌីជីថល ត្រូវបានកំណត់ផ្សេងគ្នាទៅតាមស្ថាប័ននីមួយៗ ឬខុសគ្នាតាមស្ថានភាពជាក់ស្តែងទៅតាមបណ្តាប្រទេសផ្សេងៗទៀត។ ខាងក្រោមនេះ យើងនឹងធ្វើការលើកយកនូវការអោយនិយមន័យសេដ្ឋកិច្ចឌីជីថលពីប្រភពចំនួន ៤ គឺឧត្តមប្រឹក្សាសេដ្ឋកិច្ចជាតិ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ ទស្សនៈរបស់លោក Bukht និងលោក Heeks និងទស្សនៈរបស់ធនាគារពិភពលោក។

### ១.១.១. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

នៅក្នុងស្ថានភាពសេដ្ឋកិច្ច វឌ្ឍនភាពនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានជំរុញអោយមានការបង្កើតគំរូធុរកិច្ចថ្មីៗ ផ្លាស់ប្តូរដំណើរការផលិតកម្ម ការប្រើប្រាស់ និងការចែកចាយទំនិញនិងសេវាកម្ម។ លើសពីនេះទៅទៀត របៀបនៃការធ្វើការក៏កាន់តែមានការផ្លាស់ប្តូរជាបណ្តើរៗដែលផ្តោតសំខាន់ទៅលើការពង្រីកមូលដ្ឋានផលិតផល និងសេវាឌីជីថល រួមជាមួយនឹងការធ្វើទំនើបកម្មផលិតកម្ម និងការបង្កើនផលិតភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ចឆ្លើយតបទៅនឹងការវិវឌ្ឍនៃបច្ចេកវិទ្យាត្រូវបានគេហៅថា **សេដ្ឋកិច្ចឌីជីថល** ។[7]

ដោយស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលត្រូវបានរៀបចំដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានបែងចែកនិយមន័យសេដ្ឋកិច្ចឌីជីថលក្នុងន័យចង្អៀត និងន័យទូលំទូលាយដូចខាងក្រោម៖

- **ន័យចង្អៀត**៖ សេដ្ឋកិច្ចឌីជីថល គឺជាទីផ្សារដែលពឹងផ្អែកលើបច្ចេកវិទ្យាឌីជីថលក្នុងការសម្របសម្រួលដល់ការដោះដូរទំនិញ និងការផ្តល់សេវាកម្មតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឬដែលគេអាចហៅបានមួយបែបទៀតថា ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ផ្អែកលើអ៊ីនធើណេតនៅក្នុងដំណើរការផលិតកម្ម និងការទិញលក់ទំនិញនិងសេវាកម្ម។
- **ន័យទំលំទូលាយ**៖ សេដ្ឋកិច្ចឌីជីថល គឺសំដៅដល់ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានពឹងផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) និងឌីជីថល។

### ១.១.២. អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ

[7] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥ (២០២១)*

បើយោងទៅតាម អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ ដែលត្រូវបានហៅកាត់ថា OCED បានកំណត់និយមន័យថា សេដ្ឋកិច្ចឌីជីថល គឺជាផ្នែកមួយដែលពណ៌នាអំពីទីផ្សារ ដែលផ្តោតទៅលើបច្ចេកវិទ្យាឌីជីថល ដែលសំដៅទៅលើរាល់សកម្មភាពសេដ្ឋកិច្ចសង្គម និងសកម្មភាពវប្បធម៌ដែលពឹងផ្អែកលើអ៊ីនធឺណេតប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ICT)។[8]

### ១.១.៣. ទស្សនៈរបស់លោក Bukht និង Heeks

លោក Bukht និងលោក Heeks បានបដិសេធយ៉ាងមោះមុតថាកាលណាតែយើងកំណត់និយមន័យសេដ្ឋកិច្ចឌីជីថលទូលាយពេក វាធ្វើអោយនិយមន័យមានសភាពមិនច្បាស់លាស់ និងវិសាលភាពមានភាពមិនជាក់លាក់ដែលធ្វើអោយមានការពិបាកនៅក្នុងការបែងចែកនិងវែកញែកនូវភាពខុសគ្នារវាងសេដ្ឋកិច្ច និងសេដ្ឋកិច្ចឌីជីថល ដោយសារតែការពឹងផ្អែកទៅលើប្រព័ន្ធបច្ចេកវិទ្យា នៅក្នុងសេវាកម្មនិងដំណើរការផលិតកម្ម នឹងកាន់តែមានការកើនឡើងគគុឈប់ឈរកាន់តែខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ។[9] ដោយហេតុនេះហើយ លោកបានកំណត់សេដ្ឋកិច្ចឌីជីថល នៅក្នុងវិសាលភាពបី៖

- ទី១៖ ស្នូលនៃសេដ្ឋកិច្ចឌីជីថលគ្របដណ្តប់លើកត្តាបច្ចេកវិទ្យាព័ត៌មានវិទ្យាដែលវាបានរាប់បញ្ចូលរោងចក្រផលិតកម្ម hardware ការប្រឹក្សាយោបល់អំពី software និងព័ត៌មានវិទ្យា សេវាកម្ម និងទូរគមនាគមន៍។
- ទី២៖ រួមបញ្ចូលស្នូលនៃសេដ្ឋកិច្ចឌីជីថលជាមួយនឹងសកម្មភាពសេដ្ឋកិច្ចថ្មីៗដូចជា សេវាកម្មឌីជីថល platform economy, gig economy, និង sharing economy ដែលលេចចេញឡើងដោយសារតែបច្ចេកវិទ្យាឌីជីថល ។
- ទី៣៖ ដែនកំណត់ដែលទូលំទូលាយជាងគេមានក្តោបយកនូវអាជីវកម្មបែបអេឡិចត្រូនិច ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច បដិវត្តន៍ឧស្សាហកម្ម ៤.0 ការធ្វើកសិកម្មបែបឌីជីថល និងសេដ្ឋកិច្ចដែលប្រើប្រព័ន្ធបច្ចេកវិទ្យានៅក្នុងការដោះស្រាយបញ្ហាណាមួយជាក់លាក់ ។

### ១.១.៤. ទស្សនៈរបស់ធនាគារពិភពលោក

ធនាគារពិភពលោកបានកំណត់និយមន័យសេដ្ឋកិច្ចឌីជីថល ថាជាការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដោយវិស័យឯកជន ដើម្បីអោយមានកំណើនសេដ្ឋកិច្ច នវានុវត្តន៍ និងសេដ្ឋកិច្ចទាំងមូល ដែលធ្វើអោយសេដ្ឋកិច្ច

[8] អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ, *សេដ្ឋកិច្ចឌីជីថល* (២០១២)

[9] Bukht និង Heeks, *Defining, Conceptualising and Measuring the Digital Economy (២០១៧)*

ឌីជីថលក្តោបយកនូវវិស័យផ្សេងៗ ដូចជាវិស័យសហគ្រិនភាពឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច បច្ចេកវិទ្យាហិរញ្ញវត្ថុ បច្ចេកវិទ្យាព័ត៌មាន និង បរិវត្តកម្មឌីជីថលនៅក្នុងស្ថាប័ន។[10]

នៅក្នុងការស្រាវជ្រាវនេះ យើងនឹងផ្តោតសំខាន់ទៅលើនិយមន័យសេដ្ឋកិច្ចឌីជីថលក្នុងន័យចង្អៀត ដែលលើកឡើងដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលត្រូវបានបញ្ជាក់ខាងលើ។

## ១. ២. សារៈសំខាន់នៃសេដ្ឋកិច្ចឌីជីថល

ដើម្បីឆ្ពោះទៅកាន់បដិវត្តន៍ឧស្សាហកម្ម ៤.0 និងស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ បរិវត្តកម្មឌីជីថលត្រូវបានចាត់ទុកជាកាតាលីករមួយយ៉ាងសំខាន់ដែលបានជួយជំរុញអោយមានកំណើនការអភិវឌ្ឍសេដ្ឋកិច្ច។

កម្ពុជាបានរំពឹងថា នឹងជម្រុញវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍(ICT) ដោយចាប់យកវិស័យឌីជីថលជាមូលដ្ឋាន ដើម្បីលើកកម្ពស់ផលិតភាព ប្រសិទ្ធភាព និងការប្រកួតប្រជែងសេដ្ឋកិច្ច។ សក្តានុពលសំខាន់ៗនៃបរិវត្តកម្មឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថលមានដូចជា៖

- ការតភ្ជាប់នឹងខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់តម្លៃតំបន់និងសកល ៖ ផលិតកម្មនៅក្នុងស្រុកនឹងស្ថិតនៅក្នុងវិសាលភាពទូលំទូលាយគ្មានព្រំដែននៃបច្ចេកវិទ្យាឌីជីថល និងសម្របបានតាមនិន្នាការសកលភាវូបនីយកម្មតាមរយៈការតភ្ជាប់តម្លៃតំបន់ និងសកល។ ជាពិសេស ការតភ្ជាប់សហគ្រាសធុនតូច និងមធ្យម(SMEs) នៅក្នុងខ្សែច្រវាក់តំបន់ និងសកល ត្រូវបានគេរំពឹងថានឹងក្លាយជាមូលដ្ឋានដ៏រឹងមាំក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច។
- ជំរុញសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច៖ ប្រសិទ្ធភាពនៃប្រតិបត្តិការទិញ-លក់ទំនិញ និងសេវា ជាពិសេស ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច តាមរយៈការទូទាត់កាន់តែងាយស្រួល រហ័ស គួបផ្សំនឹងការដឹកជញ្ជូនលឿន តម្លៃសមរម្យ នឹងត្រូវបានលើកកម្ពស់។ បន្ថែមលើសពីនេះ ការគ្រប់គ្រងអាជីវកម្ម និងផលិតកម្មនឹងកាន់តែមានប្រសិទ្ធភាពដោយសារតែការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល រួមផ្សំជាមួយនឹងកម្លាំងពលកម្មប្រកបដោយជំនាញ។ ជាមួយគ្នានេះ ការរៀបចំពិព័ណ៌តាមប្រព័ន្ធអេឡិចត្រូនិច និងការរៀបចំថ្នាលសម្រាប់ដាក់លក់ ផ្សព្វផ្សាយផលិតផល ដើម្បីជំរុញការនាំចេញ និងការផ្សារភ្ជាប់ទីផ្សារដល់អតិថិជនចុងក្រោយ ក៏អាចប្រព្រឹត្តទៅបានតាមបច្ចេកវិទ្យាឌីជីថល។
- ការបង្កើតការងារ ជំនាញ និងការវិនិយោគ៖ ការងារ និងកម្រិតជំនាញត្រូវបានរំពឹងថានឹងកើនឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ តាមរយៈយន្តការរដ្ឋ តួយ៉ាង កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស

[10] ធនាគារពិភពលោក, *Strengthening the Foundations for Future Growth*(២០១៩)

វិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញបន្ថែមដោយវិស័យឯកជន។ ការលើកកម្ពស់សហគ្រិនភាព និងនវានុវត្តន៍នឹងចូលរួមចំណែកក្នុងការបង្កើតធុរកិច្ចថ្មី ការទាក់ទាញវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកនៅក្នុងវិស័យ ICT។

- ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាកម្ម៖ សម្រាប់វិស័យសាធារណៈ ការផ្តល់សេវាកម្មសាធារណៈត្រូវបានរំពឹងថានឹងមានប្រសិទ្ធភាពកាន់តែប្រសើរ និងមានតម្លាភាពកាន់តែខ្ពស់ តាមរយៈការទទួលយកផ្នត់គំនិតឌីជីថល និងការលើកកម្ពស់សមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ និន្នាការនេះក៏បានបង្កើនឱកាសសម្រាប់ដោះស្រាយបញ្ហារចនាសម្ព័ន្ធនៅក្នុងវិស័យប្រពៃណី រួមទាំងសេដ្ឋកិច្ច សង្គម និងសន្តិសុខ។[11]

ដោយយោងទៅតាមឯកសារដែលដកស្រង់ចេញពី អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ ដែលលើកឡើងពី ការចាប់យកផលប្រយោជន៍ពីសេដ្ឋកិច្ចឌីជីថលសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍(Harnessing the digital economy for developing countries) បានបញ្ជាក់អោយឃើញថា សេដ្ឋកិច្ចឌីជីថល អាចនាំមកនូវផលប្រយោជន៍ដូចខាងក្រោម៖

- សេដ្ឋកិច្ចឌីជីថល ជម្រុញអោយមានការកើនឡើងនៃសេដ្ឋកិច្ច និងផលិតភាព រួមទាំងចូលរួមនៅក្នុងការធ្វើអោយមានការអភិវឌ្ឍប្រកបដោយចីរភាព។ កំណើននៃការកើនឡើងនេះ ត្រូវបានកំណត់ដោយសារការចាប់យកបច្ចេកវិទ្យាឌីជីថលនៃអ្នកប្រើប្រាស់ សហគ្រាស និងរដ្ឋាភិបាល ទោះបីជាមានអត្រាខុសគ្នាទៅតាមវិស័យ និងប្រទេសក្តី ។ ការចាប់យកឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបានធ្វើអោយមានផលិតភាពនៃមូលធន និងពលកម្ម រួមទាំងធ្វើអោយមានការចូលរួមនៅក្នុងខ្សែច្រវាក់តម្លៃសកលផងដែរ ។
- សេដ្ឋកិច្ចឌីជីថលបានចូលរួមចំណែកនៅក្នុងការកាត់បន្ថយចំណាយថ្លៃប្រតិបត្តិការ ដោះស្រាយបញ្ហានៃការលាក់បាំងព័ត៌មាន (information asymmetries) និងការធ្វើអោយមានលំនឹងសេដ្ឋកិច្ច និងផលប្រយោជន៍ពីបណ្តាញ ( network effect)។
- បង្កើនអោយមានការចូលរួមបានច្រើនជាងមុននៅក្នុងទីផ្សារនិងសេវាកម្មទាំងមូលពីសំណាក់ក្រុមដែលមានដែលមិនសូវទទួលបានឱកាស ។
- ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលអាចធ្វើអោយមានការកើនឡើងប្រកបដោយចីរភាពនៅក្នុងប្រទេសមួយ ឧទាហរណ៍ដូចជា ប្រទេសមួយដែលមិនសូវមានការអភិវឌ្ឍ ការចាប់យក និងប្រើប្រាស់ប្រព័ន្ធបច្ចេក

[11] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)

វិទ្យាតាមទូរស័ព្ទធ្វើអោយគេអាចចូលប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ ជួយអោយកសិករអាចលក់ផលិតផលរបស់គេនៅក្នុងតម្លៃសមរម្យមួយ ។

ប្រសិនបើមានហេដ្ឋារចនាសម្ព័ន្ធត្រឹមត្រូវមិនថាប្រទេសនោះកំពុងស្ថិតនៅក្នុងការអភិវឌ្ឍដំណាក់កាលណាទេ គឺសុទ្ធតែអាចប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការពន្លឿននូវសេវាកម្មដែលទូលំទូលាយដូចជា ការថែទាំសុខភាពដែលមានគុណភាពខ្ពស់ ការអប់រំ និងសេវាកម្មសាធារណៈរបស់រដ្ឋាភិបាល។ បើប្រទេសមួយកាន់តែព្យាយាមក្នុងការអភិវឌ្ឍ និងរៀបចំមូលដ្ឋាននៃសេដ្ឋកិច្ចឌីជីថល នោះប្រទេសនោះនឹងកាន់តែអាចអាចផ្លាស់ប្តូរបានច្រើនដែលដល់ដំណាក់កាលមួយដែលអ្នកអ្នកផ្គត់ផ្គង់ផលិតផល និងសេវាកម្មរបស់ខ្លួនតាមប្រព័ន្ធអនឡាញនឹងអាចប្រកួតប្រជែងជាមួយនឹងសេដ្ឋកិច្ចទូទាំងសាកលលោកផងដែរ។[12]

សេដ្ឋកិច្ចឌីជីថលធ្វើអោយលេចចេញនូវឱកាសឌីជីថលសម្រាប់អ្នកប្រើប្រាស់ ប្រជាពលរដ្ឋ អាជីវកម្ម និងរដ្ឋាភិបាលដូចខាងក្រោម[13]៖

- សេដ្ឋកិច្ចឌីជីថលធ្វើអោយជីវិតរបស់ប្រជាពលរដ្ឋនិងអ្នកប្រើប្រាស់កាន់តែមានភាពងាយស្រួល ដែលអាចទទួលបានសេវាកម្មបានកាន់តែលឿន មានជម្រើសនៅក្នុងការសម្រេចចិត្តជ្រើសរើសផលិតផលបានច្រើន រួមទាំងអាចចូលទៅស្វែងរកឱកាសការងារជាច្រើនតាមប្រព័ន្ធអនឡាញបានកាន់តែប្រសើរឡើង និងបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់សេវាសាធារណៈផងដែរ។
- បច្ចេកវិទ្យាឌីជីថលនឹងបង្កើនអោយមានគម្រោងអាជីវកម្មបែបថ្មី ដែលបង្កើនអោយមានការច្នៃប្រឌិតនិងការកើនឡើងនូវគុណភាពផលិតផលរបស់ខ្លួនដែលអាចជម្រុញអោយមានការកើនឡើងនៃការលក់ទទួលបានចំណូលបានកាន់តែប្រសើរឡើងក្នុងការអភិវឌ្ឍទៅមុខទៀតផងដែរ។ ជាពិសេស អាចធ្វើអោយទំនិញឬសេវាកម្មរបស់ខ្លួនត្រូវបានអតិថិជនស្គាល់នៅក្នុងទីផ្សារតាមរយៈបច្ចេកវិទ្យាឌីជីថលផងដែរ។
- រដ្ឋាភិបាលនឹងអាចធ្វើអោយសេដ្ឋកិច្ចឌីជីថល កាន់តែមានការកម្រើកឡើងដែលធ្វើអោយការផ្តល់សេវាកម្ម កាន់តែមានភាពងាយស្រួល និងលើកកំពស់នៃសុខុមាលភាពសង្គម។ ពិសេសជាងនេះទៅទៀតឌីជីថលូបនីយកម្មអាចបង្កើនអោយមានប្រសិទ្ធភាពការងារផ្សេងៗនៅក្នុងសេវាកម្មសាធារណៈ ដូចជាការប្រមូលនិងគ្រប់គ្រងទិន្នន័យ ការសម្គាល់ និងការកាត់បន្ថយការឆបោកនិងការប្រើប្រាស់មិនត្រឹមត្រូវនៅក្នុងសេវាកម្មសាធារណៈ និងងាយស្រួលនៅក្នុងការទាក់ទងជាមួយនឹងប្រជាពលរដ្ឋនិងសហគ្រាសផងដែរ។

---

[12] OECD, *Harnessing the digital economy for developing countries (២០១៦)*

[13] GMS Association, *Embracing the Digital Revolution (២០១៧)*

## ១. ៣. ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថល

បរិវត្តកម្មឌីជីថលនៅក្នុងសង្គមពិតជាមានសារៈសំខាន់ណាស់សម្រាប់ការធ្វើអោយមានកំណើនសេដ្ឋកិច្ច។ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល មិនទាន់ត្រូវបានកំណត់នៅក្នុងការប្រើប្រាស់ជារួមសម្រាប់មូលដ្ឋាននៃសេដ្ឋកិច្ចឌីជីថលនៅឡើយទេ ហេតុនេះហើយ ស្ថាប័នបានចែងនូវហេដ្ឋារចនាសម្ព័ន្ធនៃសេដ្ឋកិច្ចឌីជីថល អាស្រ័យលើបទពិសោធន៍ និងស្ថានភាពជាក់ស្តែងនៅក្នុងស្ថាប័ន ឬ តំបន់របស់គេ។

នៅក្នុងចំណុចនេះ យើងនឹងធ្វើការលើកឡើងនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលត្រូវបានកំណត់ដោយស្ថាប័នមួយចំនួនដូចជា អាជ្ញាធរខាងរូបិយវត្ថុនៃសិង្ហបុរី គណៈកម្មការអឺរ៉ុប និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។

### ១. ៣.១. អាជ្ញាធរខាងរូបិយវត្ថុនៃសិង្ហបុរី

ដោយយោងទៅតាមអាជ្ញាធរខាងរូបិយវត្ថុនៃសិង្ហបុរី (Monetary Authority of Singapore) បានចែងថាសសរស្តម្ភនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថលមានបួនធំៗគឺ អត្តសញ្ញាណឌីជីថល សេចក្តីអនុញ្ញាត និងការយល់ព្រម ការទូទាត់បែបអន្តរប្រតិបត្តិការ ( ទៅវិញទៅមក) និង ការផ្លាស់ប្តូរទិន្នន័យ។[14]

#### ១.៣.១.១. អត្តសញ្ញាណឌីជីថល

អត្តសញ្ញាណឌីជីថល ជាហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលសំខាន់បំផុតនៅក្នុងសេដ្ឋកិច្ចឌីជីថលដែលធ្វើអោយបុគ្គល អាជីវកម្ម និងស្ថាប័នរដ្ឋធ្វើការបង្ហាញខ្លួន និងធ្វើសកម្មភាពដោយមានសេចក្តីអនុញ្ញាតត្រឹមត្រូវនៅក្នុងសេដ្ឋកិច្ចឌីជីថល។

អត្តសញ្ញាណឌីជីថល ត្រូវបានគេពណ៌នាថាជាវិធីដែលសាមញ្ញ មានការទុកចិត្ត និងអាចប្រើប្រាស់ជាថ្មីបាន ដោយសារតែវាមិនទាមទារអោយមានលេខសម្ងាត់ច្រើនដង និងនីតិវិធីនៅក្នុងការផ្ទៀងផ្ទាត់ឡើងវិញច្រើនលើកច្រើនសារនោះឡើយ។ លើសពីនេះវាធ្វើអោយយើងអាចប្រើប្រាស់មធ្យោបាយតែមួយនៅក្នុងការបញ្ជាក់ថាពិតប្រាកដនៅក្នុងសេវាកម្មជាច្រើន (ដូចជា វេបសាយ កម្មវិធី ឬគ្រឿងឧបករណ៍) ដោយសារតែមានការរួមបញ្ចូលនូវលក្ខណៈបែបឌីជីថល និង ឯកសារដែលបញ្ជាក់អត្តសញ្ញាណ។

#### ១.៣.១.២. សេចក្តីអនុញ្ញាត និងការយល់ព្រម

សហប្រតិបត្តិការឌីជីថលគួរតែមានតម្លាភាព សុវត្ថិភាព និងមានប្រសិទ្ធភាព។ តាមរយៈការផ្តល់ជូននូវសហប្រតិបត្តិការដែលសម្គាល់អត្ថប្រយោជន៍នៃការប្រើប្រាស់ទិន្នន័យដែលត្រូវបានអនុញ្ញាតប្រកបដោយតម្លាភាព រួមទាំងការដែលទទួលបានការយល់ព្រមពីបុគ្គល នោះទិន្នន័យនឹងអាចយកមកប្រើប្រាស់បាននិងចែករំលែកដោយយោងទៅតាម គោលបំណងដែលគេបានយល់ព្រមផ្តល់ជូន និងនៅក្នុងកម្រិតមួយដែលបុគ្គលអាចទទួលយកបាន។

---

[14] អាជ្ញាធរខាងរូបិយវត្ថុនៃសិង្ហបុរី, *Foundational Digital Infrastructures for Inclusive Digital Economy (២០២០)*

#### ១.៣.១.៣.ការទូទាត់បែបអន្តរប្រតិបត្តិការ

ដើម្បីអោយការទូទាត់មានលក្ខណៈជាសកល នោះត្រូវតែមានការបង្កើតយន្តការដែលធានាអោយមានអន្តរប្រតិបត្តិការនៃប្រព័ន្ធ។ ការទូទាត់បែបអន្តរប្រតិបត្តិការមានការជាប់ពាក់ព័ន្ធជាមួយនឹងយន្តការដែលធនាគារពីរត្រូវទូទាត់រវាងអតិថិជនរបស់គេ។

#### ១.៣.១.៤. ការផ្លាស់ប្តូរទិន្នន័យ

ការផ្លាស់ប្តូរទិន្នន័យធ្វើអោយមានការទូទាត់ ការរៀបចំគម្រោងហិរញ្ញវត្ថុ និងការបង្កើតឡើងនៃអត្តសញ្ញាណឌីជីថល រួមទាំងសេវាកម្មផ្សេងទៀតដែលមានភាពចាំបាច់នៅក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល។ វាជំរុញអោយអ្នកប្រើប្រាស់ចុងក្រោយ(end-user) បង្កើនអោយទិន្នន័យរបស់គេ អាចរកបាន និងអាចចូលទៅប្រើប្រាស់បាន សម្រាប់រយៈពេលកំណត់ណាមួយ ឬ ក្នុងគោលបំណងណាមួយ។

### ១.៣.២. គណៈកម្មការអឺរ៉ុប

យោងតាមសន្ទស្សន៍សេដ្ឋកិច្ច និងសង្គមឌីជីថល( Digital Economy and Society Index) ដែលត្រូវបានបង្កើតឡើងដោយ គណៈកម្មការអឺរ៉ុប (European Commission) បាននិយាយថា ហេដ្ឋារចនាសម្ព័ន្ធឌីជីថលមានដូចជា ការតភ្ជាប់បណ្តាញអ៊ិនធើណេត ធនធានមនុស្សដែលប្រកបដោយជំនាញ ការដាក់បញ្ចូលឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដោយបុគ្គល អាជីវកម្ម និងស្ថាប័នសាធារណៈ។[15]

#### ១.៣.២.១. បណ្តាញអ៊ីនធើណេត

នៅពេលដែលគេលើកឡើងពីបណ្តាញអ៊ិនធើណេតនៅក្នុងសន្ទស្សន៍សេដ្ឋកិច្ចនិងសង្គមឌីជីថល គឺគេធ្វើការគិតគូរទៅលើទាំងផ្នែកតម្រូវការ និងការផ្គត់ផ្គង់នូវអ៊ីនធើណេតល្បឿនលឿនអចល័តនិងចល័ត។ សម្រាប់អ៊ិនធើណេតល្បឿនលឿនអចល័ត គឺគេវាយតម្លៃទៅលើសេវាកម្មដែលផ្គត់ផ្គង់ផ្នែកអ៊ិនធើណេតទាំងមូល និងសេវាអ៊ិនធើណេតដែលដំណើរការលឿន ភាពដែលអាចរកបាននូវប្រព័ន្ធអ៊ិនធើណេតដែលដំណើរការលឿន និងគិតពីតម្លៃនៃអ្នកដែលកំណត់ថ្លៃក្នុងការផ្គត់ផ្គង់ប្រព័ន្ធអ៊ីនធើណេតដែលអាចមានលទ្ធភាពក្នុងការចំណាយប្រើប្រាស់ផងដែរ។

#### ១. ៣.២.២. ធនធានមនុស្ស

ស្ថានភាពកូវីដ-១៩ បានសបញ្ជាក់អោយកាន់តែច្បាស់ថា បច្ចេកវិទ្យាឌីជីថលមានសារៈសំខាន់ខ្លាំងយ៉ាងណានៅក្នុងសេដ្ឋកិច្ច ជាពិសេសគឺកម្រិតដែលជំនាញមូលដ្ឋាន និងជំនាញខ្ពស់ផ្នែកឌីជីថលចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើអោយមាននិរន្តភាពផ្នែកសេដ្ឋកិច្ច និងសង្គម។ ហេតុនេះហើយ ប្រសិនបើមានតែបណ្តាញអ៊ិនធើណេតមួយមុខ គឺមិនគ្រប់គ្រាន់នៅឡើយទេ វាត្រូវមានការរួមបញ្ចូលជំនាញដែលសមរម្យនៅក្នុងការទាញ

[15] European Commission, *The Digital Economy and Society Index (២០២០)*

យកផលប្រយោជន៍ពីសង្គមដែលមានការពេញនិយមប្រើប្រាស់ឌីជីថល។ ជំនាញឌីជីថល មានលំដាប់ពីជំនាញដែលអាចប្រើប្រាស់ជាមូលដ្ឋានដែលធ្វើអោយបុគ្គលអាចចូលរួមនៅក្នុងសេដ្ឋកិច្ចឌីជីថល និងប្រើប្រាស់សេវាកម្មនិងទំនិញឌីជីថល ទៅកាន់ជំនាញដែលខ្ពស់ដែលអាចធ្វើការប្រើប្រាស់សមត្ថភាព និងកម្លាំងពលកម្មរបស់ខ្លួននៅក្នុងការអភិវឌ្ឍទំនិញនិងសេវាកម្មឌីជីថលថ្មីបន្ថែមទៀត។

**១. ៣.២.៣. ការប្រើប្រាស់អ៊ីនធើណេត**

ប្រជាពលរដ្ឋដែលមានប្រើប្រាស់បណ្តាញអ៊ីនធើណេត និងមានជំនាញឌីជីថលដែលចាំបាច់ក្នុងការទាញយកផលប្រយោជន៍ពីបណ្តាញអ៊ីនធើណេតអាចធ្វើការចូលរួមជាមួយនឹងសកម្មភាពជាច្រើនតាមបណ្តាញអ៊ីនធើណេត ។ នៅក្នុងសន្ទស្សន៍សេដ្ឋកិច្ច និងសង្គមឌីជីថល គេធ្វើការវាស់វែងសំខាន់ទៅលើរបៀបដែលមនុស្សប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត និងសកម្មភាពដែលគេធ្វើតាមអនឡាញ។

សកម្មភាពទាំងនោះអាចមានដែលមានបីធំៗ គឺ មាតិកា ការទំនាក់ទំនងគ្នា និងការធ្វើប្រតិបត្តិការតាមអនឡាញ។ ប្រើប្រាស់មាតិកាអនឡាញ ដូចជាការកម្សាន្តផ្សេងៗ ប្រើប្រាស់ក្នុងការទំនាក់ទំនងបែបទំនើបទាន់សម័យដូចជាការខលជួបមុខគ្នាតាមអនឡាញ ( Video Call) និងធ្វើប្រតិបត្តិការតាមអនឡាញដូចជាការទិញទំនិញ និងទូទាត់ជាមួយនឹងធនាគារតាមប្រព័ន្ធអនឡាញ។

**១.៣.២.៤. ការដាក់បញ្ចូលនូវបច្ចេកវិទ្យាឌីជីថល**

នៅក្នុងសន្ទស្សន៍នេះគេផ្តោតសំខាន់ទៅលើការបង្កើនអោយអាជីវកម្មប្រើប្រាស់ប្រព័ន្ធឌីជីថល ។ បច្ចេកវិទ្យាព័ត៌មានវិទ្យាមានតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើអោយសហគ្រាសទទួលបាននូវអត្ថប្រយោជន៍ប្រកួតប្រជែង អភិវឌ្ឍសេវាកម្ម និងផលិតផលរបស់ខ្លួន និងពង្រីកទីផ្សាររបស់ខ្លួន។បរិវត្តកម្មឌីជីថលនៃសហគ្រាស ផ្តល់ឱកាស និងធ្វើអោយកាន់តែលូតលាស់នៅការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាកាន់តែមានទំនុកចិត្ត។

**១.៣.២.៥. សេវាសាធារណៈដោយប្រើឌីជីថល**

បច្ចេកវិទ្យាឌីជីថលធ្វើអោយមានការកើនឡើងនូវតម្រូវការ និងការរំពឹងទុកនៅក្នុងវិស័យសាធារណៈ។ ការដែលទទួលស្គាល់ពីសក្តានុពលនៃបច្ចេកវិទ្យាព័ត៌មានវិទ្យា គឺជាកូនសោរដែលប្រឈមមួយសម្រាប់ស្ថាប័នរដ្ឋ។ រដ្ឋាភិបាលឌីជីថលដែលមានប្រសិទ្ធភាពអាចផ្តល់ផលប្រយោជន៍បានច្រើនដែលរួមមានគុណសម្បត្តិ និងការសន្សំសម្រាប់ស្ថាប័នរដ្ឋ និងសហគ្រាស។ វាអាចធ្វើអោយមានការកើនឡើងនូវតម្លាភាព និងទិដ្ឋភាពបើកចំហ។ នៅក្នុងផ្នែកនេះ គេធ្វើការវាស់វែងទៅលើតម្រូវការនិងការផ្គត់ផ្គង់នៅក្នុងសេវាសាធារណៈឌីជីថល រួមទាំងទិន្នន័យដែលបើកចំហ។

**១.៣.៣. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

ដោយយោងទៅតាម ក្របខណ្ឌគោលនយោបាយនៃសេដ្ឋកិច្ចនិងសង្គមឌីជីថល ដែលត្រូវបានរៀបចំឡើងដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិបានសម្គាល់អោយឃើញថាហេដ្ឋារចនាសម្ព័ន្ធនៃឌីជីថលមាន ដូចជា ការតភ្ជាប់ឌីជីថល ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និងឡូហ្សីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ។[16]

**១.៣.៣.១. ការតភ្ជាប់ឌីជីថល**

ការតភ្ជាប់ឌីជីថលនឹងមិនផ្តោតសំខាន់ត្រឹមតែការអភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍នោះទេ ប៉ុន្តែនឹងគ្របដណ្តប់លើទិដ្ឋភាពនៃការតភ្ជាប់ឌីជីថលទៅកាន់ស្ទើរគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និងការរស់នៅរបស់ប្រជាពលរដ្ឋដែលមានរួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ ដែលគាំទ្រដល់ការរស់នៅបែបឆ្លាតរបស់ប្រជាពលរដ្ឋ។ នៅក្នុងការតភ្ជាប់ឌីជីថល រចនាសម្ព័ន្ធអគ្គិសនីដែលមានតម្លៃសមរម្យ ភាពដែលអាចទុកចិត្តបាន និងមានវិសាលភាពគ្របដណ្តប់គ្រប់ទីកន្លែង មានសារៈសំខាន់ជាយុទ្ធសាស្ត្រដែលអាចជួយទាក់ទាញដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថលផងដែរ។

**១.៣.៣.២. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល**

នៅក្នុងការបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងបែបឌីជីថលអោយកាន់តែមានលក្ខណៈបរិយាប័ន្នដែលត្រូវបានរំពឹងទុកថានឹងចូលរួមជំរុញ និងបង្កើតផលិតផលនិងសេវាកម្មកាន់តែសម្បូរបែប មានតម្លៃសមរម្យ និងមានគុណភាពជូនប្រជាពលរដ្ឋ ទន្ទឹមនឹងការធ្វើឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថលវិស័យហិរញ្ញវត្ថុ ជាពិសេសការទូទាត់សងប្រាក់ឌីជីថល ដែលកម្ពុជាធ្វើការផ្តោតសំខាន់ទៅលើ៖

- ការបង្កើតប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលអោយបានពេញលេញនិងគ្រប់ជ្រុងជ្រោយទាំងសម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុមិនមែនធនាគារ
- ការគាំទ្រដល់ការអភិវឌ្ឍ ក៏ដូចជាការការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីផ្តល់ផលិតផល និងសេវាហិរញ្ញវត្ថុដែលមានភាពបត់បែន ប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់
- ការបន្តលើកកម្ពស់ការប្រើប្រាស់ និងការទទួលបានសេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិចទាំងក្នុងវិស័យរដ្ឋ និងវិស័យឯកជន
- ការបង្កើនការយល់ដឹង និងភាពជឿជាក់នៅក្នុងការប្រើប្រាស់ និងទូទាត់សងប្រាក់ឌីជីថល។

**១.៣.៣.៣ ឡូហ្សីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ**

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឡូហ្សីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយផ្តោតទៅលើ៖

[16] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)

- ការកសាងហេដ្ឋារចនាសម្ព័ន្ធចម្បងនៃវិស័យឡូហ្សីស្ទិក ជាពិសេសហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីសម្រួលដល់វិស័យនេះ ដែលអាចធានាបាននូវប្រសិទ្ធភាព ចីរភាព និងបរិយាបន្នកម្ម។
- ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ ដែលគាំទ្រដល់វិស័យឡូហ្សីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ រួមមានប្រព័ន្ធអាស័យដ្ឋានរូបវន្ត (Physical address) និងលេខកូដប្រៃសនីយ៍ (Postal code) ជាដើម។
- និង ការបង្កើតប្រព័ន្ធអេកូឡូស៊ីនៃវិស័យដឹកជញ្ជូនគោលដៅចុងក្រោយ ដែលមានភាពគ្រប់ជ្រុងជ្រោយ ប្រសិទ្ធភាព និងចីរភាព ដោយគិតគូរលើទិដ្ឋភាពគតិយុត្តិបច្ចេកទេស និងភាពអាចអនុវត្តបាន។

## ១.៤. ផលប៉ះពាល់អវិជ្ជមាននៃបរិវត្តកម្មឌីជីថលទៅលើសេដ្ឋកិច្ចនិងសង្គម

### ១.៤.១. ផលប៉ះពាល់មកលើសេដ្ឋកិច្ច

យើងសង្កេតឃើញថា នាពេលបច្ចុប្បន្នវិស័យឌីជីថលបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការរស់នៅប្រចាំរបស់ប្រជាជនកម្ពុជា ដែលវិស័យនេះបានជួយសម្រួលដល់ការធ្វើបរអាជីកម្ម រៀនសូត្រ ប្រកបការងារតាមស្ថាប័នឯកជន ការទំនាក់ទំនងជាដើម ជាពិសេសកំឡុងពេលមានវិបត្តិជម្ងឺកូវីដ១៩។ យ៉ាងណាមិញ ប្រសិនបើយើងវិភាគបន្ថែមទៅលើការជ្រៀតចូលនៃវិស័យឌីជីថលមកលើសេដ្ឋកិច្ច ក៏បានបង្ហាញអោយឃើញថាវាបានធ្វើអោយមានផលប៉ះពាល់មួយចំនួនដូចជា ការផ្លាស់ប្តូររចនាសម្ព័ន្ធពលកម្ម និងការងារ ការប្រែប្រួលមូលដ្ឋាននៃការប្រមូលពន្ធ និងការបង្វែរអាទិភាពវិនិយោគសាធារណៈ។[17] បន្ថែមពីនេះទៅទៀត វាក៏បានបង្កើតអោយមានគម្លាតឌីជីថលនៅក្នុងសេដ្ឋកិច្ចសង្គមផងដែរ។

#### ១. ៤.១.១. ការផ្លាស់ប្តូររចនាសម្ព័ន្ធពលកម្ម និងការងារ

ខណៈពេលដែលវិស័យសេដ្ឋកិច្ចឌីជីថលកំពុងនឹងបង្កើតប្រភេទការងារថ្មីបន្ថែមទៀតដែលទាមទារអោយមានចំណេះដឹងខ្ពស់និងមានជំនាញខ្ពស់ជាមុន វាក៏បានធ្វើការអោយការងារបែបប្រពៃណីមួយចំនួនអាចនឹងប្រឈមនឹងការបាត់បង់ដូចគ្នា។ ការជ្រៀតចូលវិស័យនេះបានធ្វើអោយមានការប្តូរយ៉ាងខ្លាំងទៅលើរបៀបការងារ ដោយមានការជំនួសពីការប្រើកម្លាំងមនុស្ស ប្តូរទៅជាការប្រើម៉ាស៊ីន និងគ្រឿងយន្តជំនួសវិញ ដោយសារតែការប្រើជាគ្រឿងយន្ត និងម៉ាស៊ីនអាចបង្កើនកំណើនផលិតកម្មបានលឿន និងកាត់បន្ថយចំណាយទៅលើពលករ ឬ កម្មករ។ ក្នុងន័យនេះ សម្រាប់ប្រភេទពលកម្មអាចសម្របសមត្ថភាពជាមួយនឹងវិស័យឌីជីថល នឹងទទួលបានអត្ថប្រយោជន៍ ក៏ដូចជាឱកាសការងារច្រើនជាង ប្រភេទពលកម្មដែលប្រើកម្លាំងពលកម្មគ្មានជំនាញ ឬមានជំនាញទាប ត្រូវចាប់យកជំនាញឌីជីថលកម្រិតមូលដ្ឋាន ដើម្បីរក្សាការងារ ឬមុខរបររបស់ខ្លួន។ ឧទាហរណ៍ អ្នក

[17] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)

ប្រកបរបរអាជីវកម្មខ្នាតតូចមួយចំនួន ចាប់ផ្ដើមធ្វើការប្ដូររបៀបនៃការទូទាត់ប្រាក់តាមការប្រព័ន្ធអេឡិចត្រូនិច ដោយការផ្ទេរប្រាក់ពីគណនីធនាគារមួយទៅគណនីធនាគារមួយទៀតតាមរយៈកម្មវិធីធនាគារទូរស័ព្ទ (Mobile Banking) ឬការទូទាត់ប្រាក់ដោយការស្កេន QR Code និងការចេះប្រើប្រាស់កុំព្យូទ័រជាដើម។ សម្រាប់ប្រជាជនដែលប្រកបរបរដូចជា អ្នករត់ម៉ូតូឌុប ឬម៉ឺកកង់បី (Passapp ឬ Grab) គឺតម្រូវអោយគាត់ចេះប្រើកម្មវិធីផែនទី (Google Map) ជាដើម។ ជាងនេះទៅទៀត ការវិវឌ្ឍន៍ និងការប្រកួតប្រជែងគ្នាក្នុងវិស័យបច្ចេកវិទ្យាបានធ្វើអោយមានការបង្កើនចំណេះដឹង និងជំនាញជាច្រើន ដែលវានឹងធ្វើអោយមានគម្លាតកាន់តែរីកធំឡើង ចំពោះអ្នកដែលមិនសូវមានសមត្ថភាពមានឱកាសការងារតិចតួចនៅក្នុងទីផ្សារការងារ។

**១.៤.១.២. ការប្រែប្រួលមូលដ្ឋាននៃការប្រមូលពន្ធ**

ថ្វីត្បិតតែបរិវត្តឌីជីថលនៅក្នុងសេដ្ឋកិច្ចអាចបង្កើនឡើងនូវឱកាសនៃចំណូលពន្ធរបស់រាជរដ្ឋាភិបាលតាមរយៈការជម្រុញ និងកំណើនសកម្មភាពសេដ្ឋកិច្ចក៏ដោយ តែវាក៏នៅតែមានផលអវិជ្ជមានមួយចំនួនដល់ការប្រមូលពន្ធ ក្នុងរូបភាពមួយចំនួនដូចជា ៖

(១). ការបាត់បង់ចំណូលពន្ធ និងមូលដ្ឋានពន្ធ ដោយសារអវត្តមានរូបវន្តបុគ្គល ឬអាជីកម្មក្នុងស្រុកពីព្រោះថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចមិនមានដែនកំណត់ឡើយ

(២). ការកំណត់និយមន័យចំនូល មិនទាន់មានភាពច្បាស់លាស់ ខណៈពុំមានយន្តការប្រសើរនៅក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមាន

(៣). យន្តការប្រមូលអាករលើតម្លៃបន្ថែមមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមិនទាន់មានប្រសិទ្ធភាពខ្ពស់ ក្នុងបរិការណ៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។

**១.៤.១.៣. ការបង្វែរអាទិភាពវិនិយោគសាធារណៈ**

សម្រាប់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល រាជរដ្ឋាភិបាលបានដើរតួយ៉ាងសំខាន់ក្នុងការដឹកនាំ និងជំរុញអោយមានការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីធ្វើការឆ្លើយតបទៅនឹងតម្រូវការ ដើម្បីទាមទារអោយមានការកើនឡើងធនធានសម្រាប់ការវិនិយោគ។ ដែលជាលទ្ធផល វានឹងក្លាយទៅជាបន្ទុកសម្រាប់ការប្រមូលចំណូលដើម្បីបំពេញតម្រូវការវិនិយោគ ព្រមទាំងក្លាយទៅជាសម្ពាធនៃការចែករំលែកធនធានដែលមានកំណត់សម្រាប់ការអភិវឌ្ឍវិស័យនេះ ដែលតម្រូវអោយមានការថ្លឹងថ្លែងលើអាទិភាពវិនិយោគសាធារណៈទាំងមូល។

**១.៤.១.៤. គម្លាតឌីជីថល**

គម្លាតឌីជីថល សំដៅលើគម្លាតឱកាសនៅក្នុងការអាចប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ( ICTs) និងការប្រើប្រាស់បណ្ដាញអ៊ីនធើណេតសម្រាប់សកម្មភាពផ្សេងៗ រវាងបុគ្គល គ្រួសារ សហគ្រាស និង តំបន់ភូមិសាស្ត្រ

ដែលមានកម្រិតសេដ្ឋកិច្ចសង្គមខុសគ្នា ។ គម្លាតឌីជីថល ឆ្លុះបញ្ចាំងពីភាពខុសគ្នា ក្នុងចំណោមប្រទេសមួយទៅប្រទេសមួយ ឬតំបន់ផ្សេងគ្នានៅក្នុងប្រទេសមួយ។ ការដែលអាចចូលទៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន គឺជាមូលដ្ឋានសំខាន់បំផុតនៅក្នុងការចំណោមបញ្ហាប្រឈមផ្សេងទៀតទាំងអស់ ដោយសារតែវាសំខាន់ជាងគេលើសពីការដែលអាចប្រើអ៊ីនធើណេតបានតែមួយមុខ។[18]

ឌីជីថលូបនីយកម្មនឹងនាំមកនូវគម្លាតឌីជីថល ពោលគឺអ្នកដែលមានលទ្ធភាពគ្រប់គ្រាន់អាចប្រើប្រាស់បានដោយងាយស្រួលចំណែកឯអ្នកដែលមិនមានលទ្ធភាពគ្រប់គ្រាន់នឹងមិនបានចូលប្រើប្រាស់នូវកម្មវិធីដែលត្រូវប្រើប្រព័ន្ធបច្ចេកវិទ្យានោះឡើយ។ អ្នកដែលមានជំនាញឌីជីថល នឹងកាន់តែមានឱកាសច្រើនជាងមុននៅក្នុងការចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល មិនថាការប្រើប្រាស់ ការបម្រើការងារ ការបើកអាជីវកម្ម ឬប្រើប្រាស់សេវាកម្មសាធារណៈ ដែលមានរហ័ស និងងាយស្រួលជាងមុន។ ផ្ទុយទៅវិញ អ្នកដែលមិនសូវមានជំនាញឌីជីថល នឹងជួបបញ្ហាប្រឈមនៅក្នុងការទទួលបានឱកាសបន្ថែមពីសង្គម និងសេដ្ឋកិច្ចឌីជីថល ដោយសារតែកង្វះនូវការយល់ដឹងពីបច្ចេកវិទ្យាឌីជីថលថ្មីនេះ និងពេលខ្លះអាចឈានទៅរកការជួបបញ្ហាប្រឈម និងមិនទទួលបានឱកាសដែលបានផ្តល់អោយផងដែរ។[19]

### ១.៤.២. ផលប៉ះពាល់លើសង្គម

កំឡុងពេលដែលមនុស្សកំពុងតែមានភាពមមាញឹកក្នុងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច ដែលយើងបានឃើញហើយថា វិស័យឌីជីថលបានកំពុងតែបានរីកលូតលាស់នៅក្នុងប្រទេសកម្ពុជា និងបានកំពុងតែជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ វាក៏មានផលប៉ះពាល់ថ្មីៗ មួយចំនួនផងដែរមកលើសង្គមដូចជាផលប៉ះពាល់ទៅលើប្រពៃណី វប្បធម៌ និងការប្រាស្រ័យទាក់ទង ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន និងឧក្រិដ្ឋកម្ម និងការគម្រាមគំហែងតាមប្រព័ន្ធបច្ចេកវិទ្យា។

#### ១.៤.២.១. ផលប៉ះពាល់ទៅលើប្រពៃណី វប្បធម៌ និងការប្រាស្រ័យទាក់ទង

ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បានធ្វើអោយមានការជ្រាបចូលនូវប្រពៃណី និងវប្បធម៌របស់បរទេសធ្វើអោយមានផលប៉ះពាល់ដល់ប្រពៃណីនិងវប្បធម៌បុរាណរបស់កម្ពុជា ដែលបានធ្វើអោយមានការផ្លាស់ប្តូរប្រតិកម្មសង្គម(Backlash) ប្រសិនបើមិនមានការរៀបចំទប់ស្កាត់ទៅលើបញ្ហានេះនោះទេ។ យើងបានសង្កេតឃើញថាការជ្រៀតចូលនៃវិស័យឌីជីថលបានធ្វើការអោយមានការផ្លាស់ប្តូររបៀបរបបរស់នៅប្រចាំថ្ងៃស្ទើរតែទាំងស្រុងរបស់ប្រជាពលរដ្ឋ ជាពិសេសក្នុងវិបត្តិកូវីដ១៩ ទៅលើការធ្វើសកម្មភាពប្រចាំថ្ងៃដូចជា ការទំនាក់ទំនង ការផ្សព្វផ្សាយ ការកម្សាន្ត ការទទួលយកចំណេះដឹង និងការធ្វើអាជីវកម្មជាដើម។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា

[18] OECD (២០០១)

[19] Annika Hedberg និង Stefan Šipka (២០២០)

ក្នុងកម្រិតមួយហួសប្រមាណ អាចធ្វើអោយមានការផលអាក្រក់ដូចជា មានការថមថយបំណិនសង្គម ការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយនឹងក្រុមគ្រួសារ មិត្តភ័ក្តិ ឬមិត្តរួមការងារជាដើម ដែលធ្វើអោយមានផលលំបាកក្នុងការទំនាក់ទំនងជាមួយគ្នា និងធ្លាក់ចុះនៃសីលធម៌ក្នុងការប្រាស្រ័យទាក់ទង។ ជាលទ្ធផល ផលប៉ះពាល់ទាំងនេះអាចបង្កជាហានិភ័យដល់អត្តសញ្ញាណជាតិ។

**១.៤.២.២. ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន**

បរិវត្តកម្មឌីជីថលអាចធ្វើអោយយើងអាចឈានទៅរកការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន ព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ។ ជារៀងរាល់ថ្ងៃ យើងម្នាក់ៗមិនបានដឹងទេថាទិន្នន័យផ្ទាល់ខ្លួនជាច្រើនរបស់យើងត្រូវបានប្រមូលនិងដោះដូរ ជាពិសេសតាមរយៈប្រព័ន្ធអ៊ីនណេតនៃវត្ថុ (Internet of Thing) ខណៈពេលដែលបុគ្គលជាម្ចាស់ទិន្នន័យមិនបានដឹងឬមិនអាចគ្រប់គ្រងទៅលើលំហូរនៃទិន្នន័យនេះដោយការប្រើប្រាស់កម្មវិធី ឬឧបករណ៍ឌីជីថល ដូចជាការប្រើប្រាស់បច្ចេកវិទ្យាសម្គាល់មុខ(Facial Recognition) ការធ្វើអន្តរកម្មលើប្រព័ន្ធសង្គម ការប្រើប្រាស់ម៉ាស៊ីនស្វែងរក(Search Engine) និងប្រើប្រាស់ឧបករណ៍ឆ្លាតផ្សេងៗ។ ក្រុមហ៊ុនគ្រប់គ្រងប្រព័ន្ធ និងបច្ចេកវិទ្យាទាំងនេះអាចតាមដានរាល់ប្រតិបត្តិការ និងទំនាក់ទំនងដែលកើតមានឡើងដែលនេះជាការរំលោភបំពានលើឯកជនភាពរបស់អ្នកប្រើប្រាស់។ លើសពីនេះទៅទៀត ការចែករំលែកព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយតាមប្រព័ន្ធបច្ចេកវិទ្យានេះជាបញ្ហាប្រឈមដែលធំមួយ ធ្វើអោយអ្នកប្រើប្រាស់ទទួលបានព័ត៌មានមិនច្បាស់លាស់ និងបង្កអោយមានការភាន់ច្រឡំ ដែលពេលខ្លះអាចឈានទៅរកការខាតបង់ពេលវេលា ឬថវិកា និងអាចប៉ះពាល់ដល់អារម្មណ៍ផ្លូវចិត្តរបស់ប្រជាពលរដ្ឋទូទៅ ឬអាចបង្កជាភាពចលាចលនិងបាតុភាពនៅក្នុងសង្គមផងដែរ។

**១.៤.២.៣.ឧក្រិដ្ឋកម្ម និងការគម្រាមគំហែងតាមប្រព័ន្ធបច្ចេកវិទ្យា**

ឧបករណ៍ដែលបានភ្ជាប់ជាមួយនឹងប្រព័ន្ធអ៊ីនធើណេតអាចជាគោលដៅសម្រាប់ប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈការហេក (Hacking) ។ អ្នកហេក (Hacker) អាចចូលទៅធ្វើការមើល លួច ឬ ក្លែងបន្លំព័ត៌មានសំខាន់ៗរបស់បុគ្គល ឬ អង្គភាព ក្នុងរូបភាពជាអាទ៍ ការរំលោភបំពានលើឯកជនភាព, ការលួចអត្តសញ្ញាណ (Identity Theft), ការក្លែងបន្លំអត្តសញ្ញាណ (Identity Fraud)។ សកម្មភាពឧក្រិដ្ឋកម្មទាំងអស់នេះអាចធ្វើអោយមានការប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល ទាំងផ្នែកហិរញ្ញវត្ថុ និងផ្ទាល់ខ្លួន ព្រមទាំងធ្វើអោយបាត់បង់ភាពជឿជាក់របស់អ្នកប្រើប្រាស់។

លើសពីនេះទៅទៀត ការធ្វើបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមអាចនឹងធ្វើអោយមានបញ្ហាទាក់ទងនឹងសុវត្ថិភាព ដូចជា ការវាយប្រហារតាមអ៊ីនធើណេត មកលើបុគ្គលឯកជន តាមរយៈការផ្ញើសារគំរាមដោយផ្ទាល់ ឬដោយប្រយោលដែលអាចធ្វើអោយប៉ះពាល់ដល់សតិអារម្មណ៍ និងអាចបង្ករជាហានិភ័យដល់

សុខភាពផ្លូវចិត្ត និងផ្លូវកាយ។ ក្រៅពីនេះ វាអាចធ្វើអោយមានការបារម្ភកាន់តែខ្លាំងឡើងអំពីកម្រិតដែលឌីជីថលធ្វើអោយប៉ះពាល់ដល់សុខភាពមនុស្ស ដោយសារតែការកើនឡើងនៃវិទ្យុសកម្ម និងសារធាតុគ្រោះថ្នាក់។ ឌីជីថលូបនីយកម្ម ដែលមានការពឹងផ្អែកទៅលើបច្ចេកវិទ្យាឌីជីថលនឹងបន្សល់ទុកនូវស្នាមនៃអាកាសធាតុនិងបរិស្ថានដែលមិនអាចមើលរំលង ។

## ១.៥. កត្តាដែលឈានទៅរកសេដ្ឋកិច្ចឌីជីថល

កត្តាចម្បងដែលនាំអោយឈានទៅរកសេដ្ឋកិច្ចឌីជីថលត្រូវបានកំណត់ខុសៗគ្នាទៅតាមអ្នកស្រាវជ្រាវផ្សេងគ្នា និងប្រទេសនីមួយៗផងដែរ។ ក៏ប៉ុន្តែបើរៀបរាប់ជារួមទៅភាគច្រើនគេតែងកំណត់កត្តានោះជាកត្តាបីធំៗ គឺ ពលរដ្ឋឌីជីថល ធុរកិច្ចឌីជីថល និងរដ្ឋាភិបាលឌីជីថល។ ដែលក្នុងនោះផងដែរ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីល ក៏បានបញ្ជាក់យ៉ាងច្បាស់ថា សសរស្តម្ភនៃការកសាង សេដ្ឋកិច្ច និងសង្គមឌីជីថលមាន ពលរដ្ឋឌីជីថល រដ្ឋាភិបាលឌីជីថល និងធុរកិច្ចឌីជីថល។[20]

### ១.៥.១. ពលរដ្ឋឌីជីថល

ពលរដ្ឋឌីជីថល សំដៅលើប្រជាពលរដ្ឋដែលចាប់យកការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការងារ ការរស់នៅប្រចាំថ្ងៃ។ ដើម្បីធ្វើការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីភាគលាភប្រជាសាស្ត្រ ចាំបាច់ត្រូវទាមទារនូវការវិនិយោគគ្រប់គ្រាន់ ចំគោលដៅ និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការអភិវឌ្ឍចំណេះដឹង និងជំនាញឌីជីថលនឹងផ្តោតលើចំណុចបីធំៗ គឺ ភាពជាអ្នកដឹកនាំឌីជីថល (Digital leadership) បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ( Digital Talent Pool) , និង ពលរដ្ឋឌីជីថល។

- **ភាពជាអ្នកដឹកនាំឌីជីថល**

ការអភិវឌ្ឍធនធានមនុស្សដែលមានភាពជាអ្នកដឹកនាំឌីជីថលត្រូវបានចាត់ទុកថាជានិន្នាការថ្មីមួយដែលមានការទាមទារអោយអ្នកដឹកនាំបង្កើនការទទួលយក និងការសម្របខ្លួនទៅនឹងការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មីដែលផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថល សម្រាប់ការធ្វើអភិបាលកិច្ច ការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត ឬ ការដោះស្រាយបញ្ហានានា។ សម្រាប់ទិសដៅអនាគត ការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និងការកសាងភាពជាអ្នកដឹកនាំឌីជីថលនឹងគិតគូរទៅលើទិដ្ឋភាពធំៗចំនួន ២ ដែលរួមមាន៖

  - ទី១៖ ការអភិវឌ្ឍធនធានមនុស្សដែលជាអ្នកដឹកនាំឌីជីថលក្នុងចំណោមអ្នកដឹកនាំនៅក្នុងវិស័យរដ្ឋ ដោយធានាបាននូវជំនាញឌីជីថលក្នុងកម្រិតសមស្រប ព្រមទាំងជម្រុញការកសាងផ្នត់គំនិត និងភាពជាអ្នកដឹកនាំឌីជីថល។

[20] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)

- ទី២៖ ការលើកទឹកចិត្ត និងការបង្កើនកិច្ចសហការជាមួយនឹងវិស័យឯកជន ព្រមទាំងបង្កើនការយល់ដឹង និងការបណ្តុះផ្នត់គំនិត ក៏ដូចជាភាពដឹកនាំឌីជីថលនៅតាមសហគមន៍មូលដ្ឋានក៏ដូចជាសង្គមទាំងមូល។

- **បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល**

ធនធានមនុស្សដែលមានទេពកោសល្យឌីជីថល គឺជាតួអង្គដ៏សំខាន់នៅក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថលដែលចូលរួមធានាបាននូវការបង្កើតថ្មី និងនវានុវត្តន៍ រាប់ទាំងការបង្កើតធុរកិច្ចថ្មីៗ ការដោះស្រាយបញ្ហាបានឆាប់រហ័សក្នុងប្រព័ន្ធព័ត៌មានវិទ្យា និងការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល។

ជាពិសេស ដើម្បីឈានទៅរកការកសាងនូវធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ទាមទារអោយមានការចូលរួមពីវិស័យឯកជនលើការជំរុញការបំពាក់បំប៉នជំនាញ ឬផ្លាស់ប្តូរជំនាញរបស់កម្លាំងពលកម្មទៅរកវិស័យឌីជីថល ព្រមទាំងការគាំទ្រដល់ការអនុវត្តយន្តការនានារបស់រដ្ឋាភិបាលអោយកាន់តែមានប្រសិទ្ធភាព។

ការកសាងបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថលនឹងគិតគូរទៅលើ៖

- ការបន្តកែលម្អប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីពង្រឹងគុណភាពនៃជំនាញឌីជីថល។
- ការកសាងលក្ខខណ្ឌអំណោយផលដល់ធនធានមនុស្សដែលមានទេពកោសល្យឌីជីថលនៅក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ និង
- ការផ្តល់ឱកាសអោយបានច្រើនដល់ធនធានមនុស្សដែលមានទេពកោសល្យឌីជីថលចូលរួមបម្រើការងារក្នុងស្ថាប័នរដ្ឋ។

- **ពលរដ្ឋឌីជីថល**

ក្នុងការប្រែក្លាយប្រជាពលរដ្ឋអោយទៅជាពលរដ្ឋឌីជីថលដែលមានសមត្ថភាពក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលមកប្រើប្រាស់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ គេត្រូវធ្វើការផ្តោតសំខាន់ និងយកចិត្តទុកដាក់ទៅលើការធានាបាននូវការកសាងអក្ខរកម្មឌីជីថលដល់ប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងបណ្តុះបណ្តាលនូវជំនាញទន់ចាំបាច់ រួមទាំងភាពជាអ្នកដឹកនាំឌីជីថល ដើម្បីជម្រុញអោយការធ្វើអន្តរកម្មរបស់ប្រជាពលរដ្ឋ នៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និងសង្គមឌីជីថល កាន់តែមានប្រសិទ្ធភាព។

### ១.៥.២. ធុរកិច្ចឌីជីថល

ធុរកិច្ចឌីជីថល ដែលរួមមានពាណិជ្ជកម្មតាមប្រព័ន្ធអេលិចត្រូនិច និងបច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅលើការធ្វើសកម្មភាពធុរកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីលើកកម្ពស់ការប្រកួតប្រជែង ការពង្រីកទីផ្សារ និងផលិតភាពគួបផ្សំនឹងប្រសិទ្ធភាពសេដ្ឋកិច្ច នឹងជួយអោយមានការបង្កើតនូវធុរកិច្ចថ្មី។

កិច្ចការចាំបាច់នៅក្នុងការអភិវឌ្ឍធុរកិច្ចឌីជីថល ផ្តោតលើទិដ្ឋភាពសំខាន់ចំនួន ៣ដែលរួមមាន៖

- **ការជំរុញបរិវត្តកម្មឌីជីថលសហគ្រាស**

ការចូលរួមរបស់សហគ្រាសនៅក្នុងការចាប់យកឌីជីថល អាចសម្រួលដល់ការចែករំលែកបច្ចេកវិទ្យា ការស្វែងរកវត្ថុធាតុដើម និងការកំណត់គោលដៅក្នុងការលក់ផលិតផល ឬ សេវាកម្មរបស់ខ្លួន។ ការដាក់ដំណើរការនូវការប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា ជាជំហានវិជ្ជមានមួយដែលជម្រុញក្នុងការធ្វើឌីជីថលូបនីយកម្មរបស់សហគ្រាសជារួម ក៏ដូចជាជម្រុញទម្រង់នីយកម្មនៃព័ត៌មាននៃសហគ្រាសទាំងអស់ផងដែរ។

- **ការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងធុរកិច្ចថ្មី**

ក្នុងទិសដៅបង្កើតនូវបរិយាកាសគាំទ្រដល់ការបង្កើតធុរកិច្ចថ្មី សំដៅជំរុញការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្ត លើបច្ចេកវិទ្យាឌីជីថល រាជរដ្ឋាភិបាលចាំបាច់បន្តខិតខំ និងដាក់ចេញនូវវិធានការដោះស្រាយនូវបញ្ហាប្រឈមនានា ដែលបង្អាក់ដល់ការអភិវឌ្ឍសហគ្រិនភាព និងការបង្កើតធុរកិច្ចថ្មី។ ដើម្បីធ្វើការបន្ត និងពន្លឿនការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងធុរកិច្ចថ្មី ត្រូវផ្តោតលើ ៖

  - ការជម្រុញការប្រើប្រាស់បច្ចេកវិទ្យាដើម្បីដោះស្រាយបញ្ហា និងការបង្កើតធុរកិច្ចថ្មីៗ ដែលមានទម្រង់ជាការបង្កើតថ្មី ( Creative destruction) សំដៅជម្រុញផលិតភាពនៃធុរកិច្ចដែលមានស្រាប់
  - ការពង្រឹង និងពង្រីកវិសាលភាពនៃកម្មវិធីផ្តួចផ្តើមនានា ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និងកំពុងអនុវត្តនាពេលបច្ចុប្បន្ន។

- **ការលើកកម្ពស់ខ្សែច្រវាក់តម្លៃឌីជីថល**

សម្ទុះកំណើននៃការចាប់យកឌីជីថល នឹងជំរុញអោយមានតម្រូវការជំរុញនូវផលិតផល និងសេវាឌីជីថលស្ទើរគ្រប់វិស័យ ដោយក្នុងនោះ បច្ចេកវិទ្យាឌីជីថលនឹងវិវឌ្ឍខ្លួនទៅជាកត្តាគន្លឹះដ៏សំខាន់ក្នុងការបង្កើតតម្លៃបន្ថែមសម្រាប់ផលិតផល និងសេវាកម្មដែលមានស្រាប់ ។ ម្យ៉ាងវិញទៀត ការវិវឌ្ឍខ្លួនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យានឹងអាចធ្វើអោយគំរូធុរកិច្ចនៃសហគ្រាសនៅក្នុងវិស័យមួយចំនួន ត្រូវបាត់បង់តម្លៃ និងតម្រូវការផងដែរ។ និន្នាការនេះជម្រុញអោយសហគ្រាសនៅក្នុងគ្រប់វិស័យពិចារណាគិតគូរក្នុងការទាញយកអត្ថប្រយោជន៍ និងការបង្កើតតម្លៃបន្ថែមពីនវានុវត្តន៍នៃបច្ចេកវិទ្យា ក៏ដូចជា រក្សាបាននូវមូលដ្ឋានអាជីវកម្ម ក្នុងបរិការណ៍បរិវត្តកម្មឌីជីថល តាមរយៈការបង្កើតច្រវាក់តម្លៃឌីជីថល ដែលមានភាពឆ្លើយតបទៅនឹងការវិវឌ្ឍនៃសេដ្ឋកិច្ច និងសង្គម និងតម្រូវការរបស់អ្នកប្រើប្រាស់។

ជាទូទៅការបង្កើតច្រវាក់តម្លៃឌីជីថលមានលទ្ធភាពក្នុងការបង្កើនតម្លៃបន្ថែមសម្រាប់ផលិតផល និងសេវាកម្មដែលមានស្រាប់ ក៏ដូចជាសម្រាប់គំរូអាជីវកម្មរបស់សហគ្រាសតាមរយៈទម្រង់នៃការផ្តល់ការគាំទ្រដល់អ្នកប្រើប្រាស់ដោយប្រើប្រាស់សេវាឌីជីថល និងការស្វែងយល់បន្ថែមអំពីអ្នកប្រើប្រាស់ដោយផ្អែកលើទិន្នន័យ។

ជាក់ស្តែង ការប្រើប្រាស់ថ្នាលឌីជីថលសម្រាប់តភ្ជាប់តួអង្គពាក់ព័ន្ធក្នុងខ្សែច្រវាក់ផលិតកម្ម និងការផ្គត់ផ្គង់ដោយចែករំលែកទិន្នន័យអោយគ្នាទៅវិញទៅមកទាន់ពេលវេលា និងសម្រួលខ្សែច្រវាក់តម្លៃនិងខ្សែច្រវាក់ផលិតកម្មទាំងមូលអោយដំណើរការទៅដោយរលូន បង្កើនតម្លៃបន្ថែមកាន់តែខ្ពស់ និងបង្កើតឱកាសអោយមាននវានុវត្តន៍សម្រាប់ធុរកិច្ចនានា។

ជានិន្នាការ សម្រាប់ថ្ងៃអនាគត សហគ្រាសនៅក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច មានភាពចាំបាច់ក្នុងការកែប្រែគំរូធុរកិច្ចរបស់ខ្លួន អោយមានលក្ខណៈសមស្របទៅនឹងតម្រូវការ និងចលនានៃបរិវត្តកម្មឌីជីថល តាមរយៈការបង្កើតច្រវាក់ឌីជីថល ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់សម្រួលដល់ប្រតិបត្តិការ និងលើកកម្ពស់ប្រសិទ្ធភាព ក៏ដូចជាពង្រឹងភាពពេញចិត្តរបស់អ្នកប្រើប្រាស់។ ដើម្បីធ្វើការជម្រុញអោយសហគ្រាសទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ទិសដៅគោលនយោបាយចាំបាច់ត្រូវផ្តោតលើ ៖

- ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងសហគ្រាសដើម្បីអាចមានលទ្ធភាពចូលទៅកាន់ថ្នាលឌីជីថលនៃខ្សែច្រវាក់តម្លៃ និងខ្សែច្រវាក់ផលិតកម្ម និង
- ការជម្រុញនវានុវត្តន៍ក្នុងការរៀបចំថ្នាលឌីជីថល ក៏ដូចជា បច្ចេកវិទ្យាថ្មីៗដែលបង្កើនប្រសិទ្ធភាពនៃខ្សែច្រវាក់តម្លៃផលិតកម្មនៅក្នុងស្រុក និងឱកាសតភ្ជាប់ទៅនឹងខ្សែច្រវាក់ផលិតកម្មនៅក្នុងប្រទេស តំបន់ និងសកល។

### ១.៥.៣. រដ្ឋាភិបាលឌីជីថល

ធុរកិច្ចឌីជីថលសំដៅលើការពង្រឹងសេវាសាធារណៈអោយកាន់តែមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

រដ្ឋាភិបាលឌីជីថល ជាតួអង្គដែលចាំបាច់នៅក្នុងការឈានទៅរកសេដ្ឋកិច្ច និងសង្គមឌីជីថល ដែលត្រូវឈានមុខគេនៅក្នុងការប្រើប្រាស់ឌីជីថល ដើម្បីបង្កើតអោយមានតម្រូវការផ្ទាល់ និងដើម្បីអោយធុរជន និងប្រជាពលរដ្ឋធ្វើការចាប់យកឌីជីថលផងដែរ។ ប្រសិនបើរដ្ឋាភិបាលធ្វើការសម្រេចចិត្តបោះជំហានយឺតនៅក្នុងដំណាក់កាលនៃការចាប់យកឌីជីថល នោះវាអាចនឹងធ្វើអោយវិស័យនេះរីកលូតលាស់ក្នុងកម្រិតមួយដែលយឺតទៅតាមនោះដែរ។ ដោយសារតែវិស័យសាធារណៈមានតួនាទីយ៉ាងសំខាន់ នៅក្នុងការផ្តល់ជូននូវសេវាសាធារណៈសម្រាប់ប្រជាពលរដ្ឋជារួម ហេតុនេះហើយទើបការធ្វើឌីជីថលូបនីយកម្មនៃសេវាសាធារណៈ ក៏ដូចជាការធ្វើបរិវត្តកម្មប្រព័ន្ធសាធារណៈ ចាំបាច់ត្រូវតែឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ការផ្លាស់ប្តូរទៅជារដ្ឋាភិបាលឌីជីថល មានគោលបំណងនៅក្នុងការកសាងរដ្ឋាភិបាលរឹងមាំ ឆ្លាតវៃ និងស្អាតស្អំ តាមរយៈបច្ចេកវិទ្យាឌីជីថល និងជាឃ្នាស់នៃសេដ្ឋកិច្ចឌីជីថល ពោលគឺធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធអភិបាលកិច្ច តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាឧបករណ៍ក្នុងការជម្រុញល្បឿនទាំងលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិកសំដៅផ្តល់

សេវាសាធារណៈដែលគ្រប់ជ្រុងជ្រោយនិងឆ្លើយតបទៅនឹងតម្រូវការប្រជាជន ប្រកបដោយប្រសិទ្ធភាព ចំណាយពេលវេលាតិច និងកាន់តែងាយស្រួលជាងមុន។

កិច្ចការចាំបាច់នឹងផ្តោតលើទិដ្ឋភាពសំខាន់ៗបីគឺ៖

- **រដ្ឋាភិបាល និងសេវាសាធារណៈឌីជីថល**

ការកើនឡើងនូវការធ្វើបរិវត្តកម្មឌីជីថលជាសញ្ញាមួយល្អ ប៉ុន្តែក៏មានចំណុចអវិជ្ជមានមួយចំនួនដែលត្រូវគិតគូរដើម្បីអាចឈានទៅរករដ្ឋាភិបាលឌីជីថលពេញលេញមួយ។ ទំនាក់ទំនងសាធារណៈរវាងក្រសួង ស្ថាប័ន និងប្រជាពលរដ្ឋត្រូវបានពង្រឹងតាមរយៈប្រព័ន្ធឌីជីថល ដែលរួមមានដូចជា ការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញសង្គម។ ការប្រើប្រាស់ប្រព័ន្ធទាំងនេះមិនត្រឹមតែជាការផ្លាស់ប្តូរ និងការផ្សព្វផ្សាយ គឺថែមទាំងជាការគ្រប់គ្រងព័ត៌មានដែលចៀសវាងនូវព័ត៌មានមិនពិត ព័ត៌មានញុះញង់និងព័ត៌មានដែលមិនបានធ្វើបច្ចុប្បន្នភាព។ ការអភិវឌ្ឍរដ្ឋាភិបាល និងសេវាសាធារណៈឌីជីថលនឹងផ្តោតលើ៖

  - ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងស្រុង រួមទាំងនីតិវិធីនៃការអនុវត្តការងារ ផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិច និងការផ្តល់ព័ត៌មាននានា
  - ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា
  - ការលើកកម្ពស់ការយល់ដឹងនិងជំនាញឌីជីថលដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ រួមទាំងនៅថ្នាក់មូលដ្ឋាន។

- **គន្លឹះជំរុញការអនុវត្តឌីជីថល**

ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់មុខងារស្នូលរបស់ស្ថាប័នរដ្ឋ និងសេវាសាធារណៈពុំគ្រប់គ្រាន់សម្រាប់ប្រែក្លាយជារដ្ឋាភិបាលឌីជីថលពេញលេញឡើយ ព្រោះប្រព័ន្ធទាំងនេះត្រូវការថ្នាលបច្ចេកវិទ្យាមូលដ្ឋាន និងបទបញ្ញត្តិមួយចំនួនសម្រាប់គាំទ្រ ដែលខ្វះខាតនៅឡើយ។ ថ្នាលបច្ចេកវិទ្យាមូលដ្ឋានទាំងនោះមានដូចជា បច្ចេកវិទ្យាក្លោដលើមជ្ឈមណ្ឌលទិន្នន័យរួមរបស់រដ្ឋាភិបាល ថ្នាលផ្លាស់ប្តូរទិន្នន័យសម្រាប់អន្តរប្រតិបត្តិការ និងសន្ទានកម្ម អត្តសញ្ញាណឌីជីថល និងប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មានជាដើម។

បច្ចេកវិទ្យាក្លោដ គឺជាសេវាហេដ្ឋារចនាសម្ព័ន្ធរួម ដែលអនុញ្ញាតអោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នធ្វើប្រតិបត្តិការនៅកន្លែងរួមគ្នាបាន និងជាបច្ចេកទេសដែលចែករំលែកធនធានបណ្តាញ និងម៉ាស៊ីនមេអោយមានប្រសិទ្ធភាព សំដៅកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋលើការអភិវឌ្ឍការគ្រប់គ្រង និងការថែទាំ។ ចំណែកអត្តសញ្ញាណឌីជីថល គឺជាមូលដ្ឋាននៃការកំណត់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល នៅពេលប្រើប្រាស់ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់ស្ថាប័នរដ្ឋ។

កត្តាគន្លឹះសម្រាប់ជម្រុញការអនុវត្តឌីជីថល នឹងផ្តោតសំខាន់ទៅលើ៖

- ការរៀបចំក្របខណ្ឌ និងផែនការច្បាស់លាស់ រួមទាំងធនធាន និងសមត្ថភាព
- ការអភិវឌ្ឍថ្នាលបច្ចេកវិទ្យាជាមូលដ្ឋាននានាដែលការណ៍នេះនឹងជម្រុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្ថាប័ននានាដោយបំពេញមុខងារអោយគ្នាទៅវិញទៅមក និងមានសង្គតិភាពជាប្រព័ន្ធរួមរបស់រដ្ឋាភិបាល សំដៅធានានូវប្រសិទ្ធភាព និងសុវត្ថិភាពរបស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថលទាំងមូល។

- **អភិបាលកិច្ចផ្អែកលើទិន្នន័យ**

ការសម្រេចចិត្តផ្អែកលើទិន្នន័យ អាចជួយដល់រដ្ឋាភិបាលអោយមានការឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន។ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់ រដ្ឋាភិបាលអាចប្រមូលទិន្នន័យមួយចំនួនសម្រាប់វិភាគ ប៉ុន្តែដោយភាពមានកម្រិតនៃការចែករំលែក និងប្រើប្រាស់ទិន្នន័យ បានកម្រិតគុណភាពទិន្នន័យ លទ្ធផលរំពឹងទុកក៏ត្រូវបានរំពឹងទុកថានឹងនៅមានកម្រិតផងដែរ។

ដើម្បីធ្វើការទាញយកអត្ថប្រយោជន៍ពីទិន្នន័យធំ រាជរដ្ឋាភិបាលនឹងជ្រើសរើសយកវិធីសាស្ត្រពង្រីកវិសាលភាព ដោយធ្វើការគិតគូរទៅលើ៖

- ការបង្កើតថ្នាលជាតិសម្រាប់រក្សាទុក និងចែករំលែកទិន្នន័យ
- ការបង្កើតសេវាឌីជីថលជាសាធារណៈ និងការលើកកម្ពស់ការយល់ដឹងពីសេវាឌីជីថល
- ការកសាងប្រព័ន្ធអភិបាលកិច្ចដោយផ្អែកលើទិន្នន័យ គួបផ្សំនឹងការកសាងធនធានគណនា ជាទម្រង់មជ្ឈមណ្ឌលទិន្នន័យ, ធនធានមនុស្សដើម្បីសម្អាតទិន្នន័យ និងក្បួនវិភាគដោះស្រាយ ដោយប្រើបញ្ញាសិប្បនិម្មិត (AI) ដែលផ្តល់នូវលទ្ធផលភ្លាមៗ ។ ការរៀបចំអភិបាលកិច្ចផ្អែកលើទិន្នន័យត្រូវការពេលវេលា និងធនធានជាច្រើន ដែលនឹងត្រូវគិតគូរក្នុងក្របខណ្ឌរយៈពេលមធ្យម និងវែង។

## ១.៦. ឧបសគ្គនៃការឈានទៅរកសេដ្ឋកិច្ចឌីជីថល

មានកត្តាពីរយ៉ាងដែលត្រូវបានចាត់ទុកថាជាឧបសគ្គធំនៅក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថលនៅក្នុងប្រទេសកម្ពុជា គឺកង្វះហេដ្ឋារចនាសម្ព័ន្ធ និងអក្ខរកម្មឌីជីថលនៅមានកម្រិត ដែលត្រូវបានបកស្រាយលម្អិតដូចខាងក្រោម។[21]

### ១.៦.១. កង្វះហេដ្ឋារចនាសម្ព័ន្ធឌីជីថល

កង្វះខាតនៃការហេដ្ឋារចនាសម្ព័ន្ធឌីជីថល គឺជាកត្តាមួយយ៉ាងសំខាន់ដែលមានការប៉ះពាល់ទៅលើការឈានទៅរកសេដ្ឋកិច្ចឌីជីថលអាចមានការវិវឌ្ឍទៅមុខបានឆាប់រហ័ស។

[21] Mekong Connect, *Post-Covid-19 Economic Recovery in The Mekong Region (២០២១)*

- បណ្ដាញអ៊ីនធើណេតគុណភាពមិនសូវល្អ៖ កាលណាតែសេវាកម្មអ៊ីនធើណេតមិនសូវមានគុណភាព និងល្បឿនលឿនសមស្របទៅនឹងតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ តម្លៃសេវាកម្មអ៊ីនធើណេតមានសេវាថ្លៃ សេវាអ៊ីនធើណេតមិនទាន់មានគ្រប់ទីតាំងដែលប្រជាជនរស់នៅ នោះបញ្ហាជាច្រើននឹងចោទឡើងបង្កើតអោយមានឧបសគ្គនៅក្នុងសេដ្ឋកិច្ចឌីជីថល ដែលបណ្ដាលអោយមានគម្លាតឌីជីថល។
- ធនធានមនុស្សមានកម្រិត៖ ចំណេះដឹងនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យារបស់ប្រជាពលរដ្ឋ ពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការជំរុញសេដ្ឋកិច្ចអោយកាន់តែមានភាពជឿនលឿន ហេតុនេះហើយនៅពេលដែលធនធានមនុស្សនៅមានកម្រិត នោះវាក៏ជាកត្តាមួយដែលរាំងស្ទះទៅកាន់ការរីកចម្រើនមួយដែលប្រកបដោយនិរន្តភាព។ ជាពិសេស នៅពេលដែលមិនបានយល់ដឹងពីមូលដ្ឋាននៃឌីជីថលសោះតែម្ដង ជាបញ្ហាមួយដែលចោទខ្លាំងទៅលើការចូលរួមពីប្រជាពលរដ្ឋនៅក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល។សម្រាប់បុគ្គល ឬយុវជនដែលធ្លាប់បានសិក្សាពីបច្ចេកវិទ្យាខ្លះៗ ក៏ដូចជាបានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាប្រចាំ គឺពួកគេមានភាពងាយស្រួល ងាយនឹងឆាប់ចាប់យក ក៏ដូចជារៀនឆាប់ចេះនៃការចូលមកដល់នៃបច្ចេកវិទ្យាទំនើបថ្មីៗ។ ដោយឡែកសម្រាប់បុគ្គលមួយចំនួនដែលមិនទាន់អាចចាប់យកបានភ្លាម និងសម្របខ្លួនបានភ្លាមៗ ដោយសារតែមូលហេតុផ្សេងៗដូចជា នៅតាមតំបន់ដាច់ស្រយាលគឺមិនសូវមានការចែករំលែកចំណេះដឹងនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ផលវិបាកសម្រាប់មនុស្សចាស់ដែលគាត់មិនសូវបានយកចិត្តទុកដាក់ទៅលើការផ្លាស់ប្ដូរនៃការឈានទៅរកវិស័យឌីជីថល ដែលភាគច្រើនគាត់តែផ្ដោតទៅលើការរស់នៅជាបែបប្រពៃណី ដោយសារតែមិនទាន់អាចសម្របខ្លួនទៅតាមការផ្លាស់ប្ដូរថ្មីនេះ ដែលភាគច្រើនការប្រើប្រាស់បច្ចេកវិទ្យា ក៏ដូចជាឧបករណ៍ឌីជីថលមានភាពស្មុគស្មាញច្រើនសម្រាប់ពួកគាត់។
- ការប្រើប្រាស់អ៊ីនធើណេតនៅមានកម្រិត៖ បើទោះបីជាមានចំនួនអ្នកប្រើប្រាស់បណ្ដាញតភ្ជាប់ច្រើននាក់យ៉ាងណាក៏ដោយ ប្រសិនបើការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេតនៅមានកម្រិតនោះវាអាចជាឧបសគ្គមួយផងដែរ ជាក់ស្ដែងដូចជាការដែលមិនចេះរក្សាព័ត៌មានសម្ងាត់របស់ខ្លួន ការដែលប្រើក្នុងគោលដៅមិនល្អ មិនត្រឹមតែមិនបានជួយជម្រុញសេដ្ឋកិច្ចឌីជីថលតែប៉ុណ្ណោះទេ គឺថែមទាំងធ្វើអោយមានផលប៉ះពាល់ទៅកាន់បុគ្គល ឬសង្គមផងដែរ។ ឧទាហរណ៍ដូចជាការបំផ្លើសព័ត៌មានមិនពិត បង្កើតភាពចលាចល ដើម្បីអោយមានការបះបោរ ឬការបោកប្រាស់តាមប្រព័ន្ធអ៊ីនធើណេត ទាំងនេះសុទ្ធសឹងតែជាទង្វើដែលបង្អាក់អោយមានការបាត់បង់ទំនុកចិត្តនៅក្នុងការប្រើប្រាស់សេវាកម្មឌីជីថល។
- ការដាក់បញ្ចូលនូវបច្ចេកវិទ្យាឌីជីថលនៅមានកម្រិតទាប៖ នៅពេលដែលសហគ្រាសមិនទាន់បានសូវយល់ដឹងពីសក្ដានុពលនៃឌីជីថលូបនីយកម្មនៅក្នុងអាជីវកម្ម សហគ្រាសនឹងមិនបានទាញយកផល

ប្រយោជន៍ពេញលេញដូចដែលសហគ្រាសដែលបានចាប់យកប្រព័ន្ធឌីជីថលបានលឿនជាងនោះឡើយ។ នៅពេលដែលសហគ្រាសផ្សេងចាប់យកឌីជីថលបានមុន ហើយមានសេវាកម្មប្រហាក់ប្រហែលគ្នា នោះអ្នកដែលចូលចិត្តសាកល្បងប្រើប្រាស់អ្វីដែលថ្មីនឹងមានការទោរទន់ទៅកាន់ការគាំទ្រសេវាកម្មដែលថ្មី និងប្រកបដោយទំនើបកម្មឌីជីថល ។ ដូចនេះ ការចាប់យកឌីជីថលនៃសហគ្រាស ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ប្រសិនបើសហគ្រាសធ្វើការឈានជើងយឺតទៅកាន់ឌីជីថល នោះកម្រិតនៃការប្រកួតប្រជែងនឹងមានភាពទោរទន់ទៅតាមនោះដែរ។

- សេវាកម្មសាធារណៈឌីជីថលនៅមានកម្រិត៖ ប្រសិនបើរាជរដ្ឋាបាលចាប់យកវិស័យឌីជីថលយឺត នោះវានឹងអាចធ្វើអោយមានការរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ដោយសារតែរដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍទៅកាន់សេដ្ឋកិច្ចឌីជីថល និងប្រៀបដូចជាអ្នកមគ្គុទេសន៍ដែលនាំផ្លូវប្រជាពលរដ្ឋ និងសហគ្រាសឈានទៅរកដំណាក់កាលបន្តទៀតដែលអាចទាញយកផលប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថល។

**១.៦.២. អក្ខរកម្មឌីជីថលនៅមានកម្រិត**

សមាគមន៍បណ្ណាល័យអាមេរិកាំង(The American Library Association=ALA) បានកំណត់និយមន័យអក្ខរកម្មឌីជីថលថាជាសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ដើម្បីស្វែងរក ការវាយតម្លៃ បង្កើត និងប្រាស្រ័យទាក់ទងព័ត៌មានដែលទាមទារទាំងជំនាញការយល់ដឹងនិងបច្ចេកទេស។ ពោលគឺ អក្ខរកម្មឌីជីថលពាក់ព័ន្ធនឹងការប្រើឧបករណ៍ឌីជីថលប្រកបដោយប្រសិទ្ធភាពដើម្បីដោះស្រាយបញ្ហាផលិតភាព ធ្វើការសហការ បង្កើតមាតិកា។[22]

នៅពេលដែលអក្ខរកម្មឌីជីថលនៅមានកម្រិត នោះបណ្តាលអោយមនុស្សមិនអាចទាញយកផលប្រយោជន៍បានពេញលេញពីឌីជីថលនោះឡើយ ពោលគឺមិនបានប្រើប្រាស់អោយអស់ពីលទ្ធភាពនៅក្នុងការស្រាវជ្រាវសិក្សាអ្វីដែលថ្មីទូទាំងសាកលលោក ដែលបណ្តាលអោយគំនិតនៅមិនទាន់ស៊ីជម្រៅទាន់សម័យកាលឌីជីថល ហើយនឹងមានគម្លាតកាន់តែឆ្ងាយនៅក្នុងការសម្របខ្លួនទទួលយកបរិវត្តកម្មឌីជីថលដែលជាឧបសគ្គរារាំងនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលអោយមានប្រសិទ្ធភាព។

ប្រសិនបើយើងនិយាយពីកម្រិតនៃការយល់ដឹងអំពីវិស័យឌីជីថលនៅក្នុងប្រទេសកម្ពុជាវិញនៅមានកម្រិតទាបនៅឡើយដោយសារតែប្រជាជនកម្ពុជាភាគច្រើនប្រើប្រាស់វិស័យឌីជីថលលើសលប់សម្រាប់ការកម្សាន្តជាជាងការស្វែងរកព័ត៌មានដែលផ្តល់ជាចំណេះដឹង និងការអភិវឌ្ឍជំនាញថ្មីបន្ថែម។ អត្រាកំណើននៃការ

---

[22] BiZKhmer, *ជំនាញទន់ចំនួន៤ ប្រសិនបើអ្នកចង់អោយអាជីពការងាររបស់អ្នកលូតលាស់ទៅមុខបន្ត (២០២០)*

ប្រើប្រាស់អ៊ីនធើណេតមានការកើនឡើងជាលំដាប់ក៏ពិតមែន តែកង្វះចំណេះដឹងនៃវិស័យឌីជីថលនៅតែស្ថិតនៅក្នុងម្រិតមួយដែលត្រូវការអភិវឌ្ឍអោយកាន់តែមានភាពប្រសើរឡើងនាពេលខាងមុខ។ នៅពេលដែលអក្ខរកម្មឌីជីថលមានកម្រិតទាប មិនត្រឹមតែជាឧបសគ្គារាំងដល់ការឈានទៅរកសេដ្ឋកិច្ចឌីជីតែមួយមុខទេ ពោលគឺវាធ្វើអោយសហគ្រាសពិបាកនៅក្នុងការជ្រើសរើសបុគ្គលិកដែលមានជំនាញឌីជីថលពិតប្រាកដដែលអាចបំពេញតួនាទីនៅក្នុងការធ្វើអោយសហគ្រាសរីកចម្រើនទៅតាមសម័យកាលឌីជីថល ។

# ជំពូកទី ២

# ស្ថានភាពទូទៅនៃសេដ្ឋកិច្ចឌីជីថល

# នៃប្រទេសកម្ពុជា

# ជំពូកទី ២

# ស្ថានភាពទូទៅនៃសេដ្ឋកិច្ចឌីជីថលនៃប្រទេសកម្ពុជា

## ២.១. ស្ថានភាពសេដ្ឋកិច្ចឌីជីថលនៃប្រទេសកម្ពុជា

ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាជាប្រទេសមួយដែលកំពុងអភិវឌ្ឍដែលមានការរីកចម្រើនលឿនបំផុតជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុបជាមធ្យមប្រមាណ ៨,១% ក្នុងរយៈពេលពីរទសវត្សមកនេះ។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ កម្ពុជាបានសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧.៥% ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ ជាមួយនឹងកំណើនដ៏រឹងមាំនេះឆ្នាំ២០១៩ សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅតែបន្តមានវឌ្ឍនភាពប្រសើរឡើងជាមួយនឹងកំណើន៧.១%។ ក៏ប៉ុន្តែមកដល់ឆ្នាំ២០២០ ដូចប្រទេសដទៃទៀតនៅទូទាំងសកលលោកដែរ ប្រទេសកម្ពុជាបានជួបប្រទះនូវការរាតត្បាតនៃជំងឺកូវីដ១៩ ដែលជាហេតុធ្វើអោយស្ថាប័នជាច្រើនត្រូវផ្អាកដំណើរអាជីវកម្មរបស់ខ្លួន រួមទាំងបង្កអោយមានការបាត់បង់ការងារជាច្រើនស្របពេលជាមួយគ្នានោះដែរ ដែលជាហេតុបណ្តាលអោយកំណើនសេដ្ឋកិច្ចមានកម្រិតអវិជ្ជមាន -៣.១%។ ជាមួយនឹងការប៉ះទង្គិចដ៏ខ្លាំងក្លានេះ ប្រទេសកម្ពុជាមិនអាចនៅតែពឹងផ្អែកទៅលើវិស័យដូចពីមុននោះទេ គឺត្រូវសម្របខ្លួន និងចាប់យកអ្វីដែលថ្មីដែលអាចចូលរួមជម្រុញអោយមានកំណើនសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ បច្ចេកវិទ្យាឌីជីថលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្របសម្រួលសកម្មភាពសេដ្ឋកិច្ចនានានៅទូទាំងសកលលោក រួមទាំងកម្ពុជា។ ការរៀបចំខ្លួនទៅកាន់សេដ្ឋកិច្ចឌីជីថលនឹងចូលរួមចំណែកយ៉ាងខ្លាំងក្លាសម្រាប់កម្ពុជាដើម្បីអាចស្តារសេដ្ឋកិច្ចរបស់ខ្លួនមកវិញនៅក្នុងស្ថានភាពកូវីដ១៩នេះ។

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានមូលដ្ឋានប្រសើរមួយនៅក្នុងការកសាងសេដ្ឋកិច្ចឌីជីថលដោយសារតែមានប្រជាសាស្ត្រមានយុវជនវ័យក្មេងច្រើន ពោលគឺប្រជាជនសរុបនៃប្រទេសកម្ពុជាមានប្រមាណ ១៦ លាននាក់ តែមានរហូតដល់ ៥៣% នៃប្រជាជនសរុបដែលមានអាយុក្រោម ២៥ ឆ្នាំ។ លើសពីនេះទៅទៀត អ្នកដែលប្រើប្រាស់ទូរស័ព្ទចល័តមានចំនួនលើសពីចំនួនប្រជាជនសរុបទៅទៀត។ បើគិតត្រឹមឆ្នាំ ២០២០ មានរហូតដល់ ១២៤%នៃប្រជាជនសរុបកំពុងតែប្រើប្រាស់ទូរស័ព្ទចល័ត។

វាពិតជាមានសារៈសំខាន់ណាស់នៅក្នុងការលើកយកសេដ្ឋកិច្ចឌីជីថលមកនិយាយ និងពិភាក្សា ដោយសារតែយើងមិនមែនផ្តោតសំខាន់ត្រឹមតែព្យាយាមដើរអោយទាន់សម័យកាលជឿនលឿនដូចប្រទេសផ្សេងទៀតទូទាំងសកលលោកទេ ក៏ប៉ុន្តែថែមទាំងព្យាយាមសម្របខ្លួនចាប់យកផលប្រយោជន៍ពីសេដ្ឋកិច្ចបែបសម័យថ្មីផងដែរ។ បើយើងក្រឡេកទៅមើលកាលពីរយៈពេលពីរបីឆ្នាំមុន ភាគច្រើនគេតែងនិយាយថា ប្រទេសកម្ពុជាត្រូវការពេលវេលាយូរទៅមុខទៀតមិនថាក្នុងការដើរទៅមុខអោយទាន់សម័យកាលនៃបដិវត្តឧស្សាហកម្ម រឺនៅក្នុងការឈានទៅរកសេដ្ឋកិច្ចបែបឌីជីថលមួយដែលពេញលេញ។ កាលពីឆ្នាំ២០១៩ មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុមានប្រសាសន៍ថា ប្រទេសកម្ពុជាត្រូវការពេលវេលាយ៉ាងហោចណាស់ ១០ឆ្នាំ តទៅមុខទៀតដើម្បីធ្វើការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ខ្លួនទៅជាសេដ្ឋកិច្ចឌីជីថល។[23]

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានប្រជាពលរដ្ឋវ័យក្មេងច្រើន បូកផ្សំជាមួយនឹងការកើនឡើងនូវសេវាកម្មហិរញ្ញវត្ថុ បណ្តាញតភ្ជាប់ទូរស័ព្ទមានកម្រិតខ្ពស់ ភាគរយនៃអ្នកដែលប្រើប្រាស់ទូរស័ព្ទដៃមានការកើនឡើង និងការលូតលាស់ជាលំដាប់នៃការចាប់យកបច្ចេកវិទ្យាឌីជីថលធ្វើអោយការឈានទៅរកសេដ្ឋកិច្ចបែបឌីជីថលកាន់តែមានល្បឿនមួយដែលអាចទទួលយកបាននាពេលខាងមុខនេះ។ លើសពីនេះទៅទៀត ស្ថានភាពកូវីដ១៩បានធ្វើការចូលរួមក្នុងការពន្លឿនអោយមានការឈានទៅរកសេដ្ឋកិច្ចឌីជីថលកាន់តែដំណើរការបានកាន់តែលឿនជាងមុនទៅទៀត។[24]

### ២.១.១.សន្ទស្សន៍នៃការត្រៀមខ្លួនទៅកាន់ឌីជីថល

សន្ទស្សន៍នៃការត្រៀមខ្លួនទៅកាន់ឌីជីថល (Networked Readiness Index) ជាសន្ទស្សន៍មួយដែលត្រូវបានគេប្រើប្រាស់ទូទាំងសាកលលោក ដើម្បីធ្វើការវាស់វែងពីការដាក់ប្រើប្រាស់និងឥទ្ធពលនៃបច្ចេកវិទ្យាព័ត៌មាននៅក្នុងសេដ្ឋកិច្ចទូទាំងសកលលោក។ សន្ទស្សន៍នៃការត្រៀមខ្លួនទៅកាន់ឌីជីថលនេះ ត្រូវបានវាស់វែងដោយសសរស្តម្ភ៤ធំៗ គឺ បច្ចេកវិទ្យា(Technology) ពលរដ្ឋ(People) រដ្ឋាភិបាល(Governane) និងឥទ្ធិពល(Impact)។ កាលពីឆ្នាំ ២០១៩ ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ ១០៧ ក្នុងចំណោមប្រទេសចំនួន ១២១ នៅក្នុងរបាយការណ៍ដែលស្តីពីសន្ទស្សន៍នៃការត្រៀមខ្លួនទៅកាន់ឌីជីថល ដែលចំណុចប្រសើរនោះគឺបច្ចេកវិទ្យា (ចំណាត់ថ្នាក់៨២ ក្នុងចំណោម១២១ប្រទេស) តែចំណុចដែលគួរតែមានអភិវឌ្ឍអោយកាន់តែមានភាពប្រសើរឡើងនោះគឺពាក់ព័ន្ធនឹងរដ្ឋាភិបាល (ចំណាត់ថ្នាក់១១៦ ក្នុងចំណោម១២១ប្រទេស)។[25] រហូតមកដល់ឆ្នាំ២០២០ ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាកលេខ១០៤ នៅក្នុងចំណោមសេដ្ឋកិច្ចចំនួន១៣៤ប្រទេស។ អ្វីដែលបានកើនឡើងគួរអោយកត់សម្គាល់នៅឆ្នាំ២០២០ គឺពាក់ព័ន្ធជាមួយនឹងបច្ចេកវិទ្យា (ចំណាត់ថ្នាក់៨៣ ចំណោម១៣៤ ប្រទេស) ដែលមានរួមបញ្ចូលនូវការចូលប្រើប្រាស់(access) មាតិកា(content) និងការប្រើប្រាស់បច្ចេកវិទ្យានាពេលខាងមុខ(Future technology)។ ក៏ប៉ុន្តែនៅមានចំណុចមួយដែលត្រូវតែធ្វើការអភិវឌ្ឍអោយមានភាពប្រសើរឡើងជាងនេះគឺ ផ្នែករដ្ឋាភិបាល(ចំណាត់ថ្នាក់១១៣ ចំណោម១៣៤ ប្រទេស) ដែលរួមបញ្ចូលការជឿទុកចិត្ត(trust) ច្បាប់(regulation) និងបរិយាប័ន្ន(inclusion)។[26]

[23] Xinhua, *Cambodia needs a decade to grow digital economy (២០១៩)*

[24] Mekong Strategic Partners, *Cambodia's Fintech 2021 Report (២០២០)*

[25] Portulans Institute, *Network Readiness Index (២០១៩)*

[26] Portulans Institute, *Network Readiness Index (២០២០)*

### ២.១.២. សន្ទស្សន៍នៃការប្រកួតប្រជែងពិភពលោក

សន្ទស្សន៍នៃការប្រកួតប្រជែងពិភពលោក ជាសន្ទស្សន៍ដែលធ្វើការវាស់វែងទៅលើកម្រិតនៃការប្រកួតប្រជែងនៅប្រទេសមួយដែលកំណត់ពីផលិតភាពរបស់ខ្លួន។ សន្ទស្សន៍នេះត្រូវបានវាស់វែងតាមរយៈសសរស្តម្ភចំនួន ១២ ដែលរួមមាន ស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ ការចាប់យកឌីជីថល ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សុខភាព ជំនាញ ទីផ្សារផលិតផល ទីផ្សារពលកម្ម ប្រព័ន្ធហិរញ្ញវត្ថុ ទំហំទីផ្សារ ថាមពលនៃអាជីវកម្ម និងសមត្ថភាពនៅក្នុងការបង្កើតអ្វីដែលថ្មី។ កាលពីឆ្នាំ ២០១៨ ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ ១១០ នៅក្នុងចំណោមប្រទេសចំនួន១៤០។ ចំណោមសសរស្តម្ភទាំង១២ សសរស្តម្ភដែលកម្ពុជាមានលេខរៀងលំដាប់ល្អជាងសសរស្តម្ភផ្សេងទៀតរបស់ខ្លួននោះគឺ ទីផ្សារកម្លាំងពលកម្ម ដែលមានលេខរៀងទី៦៥ ក្នុងចំណោមប្រទេសចំនួន ១៤០។ ចំណែកសសរស្តម្ភដែលមានលំដាប់មានកម្រិតជាងគេនោះគឺស្ថាប័នរដ្ឋាភិបាល (Institution) ដែលមានលេខរៀង ១២៦ ក្នុងចំណោមប្រទេសចំនួន ១៤០។[27] មកដល់ឆ្នាំ ២០១៩ ក៏បានជាប់ចំណាត់ថ្នាក់លេខ ១០៦ ក្នុងចំណោមប្រទេសចំនួន ១៤១ ដែលបានបង្ហាញពីលទ្ធផលមួយដែលល្អគួរសមបើប្រៀបធៀបនឹងឆ្នាំ ២០១៨។ ឆ្នាំ២០១៨ ប្រទេសកម្ពុជានៅតែរក្សាជំហររបស់ខ្លួនគឺសសរស្តម្ភដែលមានភាពប្រសើរជាងសសរស្តម្ភដទៃរបស់ខ្លួននោះគឺ ទីផ្សារកម្លាំងពលកម្ម ហើយក៏បានកែប្រែបានខ្លះនូវលំដាប់លេខរៀងនៃសសរស្តម្ភរដ្ឋាភិបាលមកត្រឹមលេខ ១២៣ ក្នុងចំណោម ១៤១ប្រទេស។ ផ្ទុយទៅវិញ សសរស្តម្ភដែលមានលំដាប់លេខរៀងមានកម្រិតជាងគេនៅក្នុងចំណោមសសរស្តម្ភទាំង១២ នោះគឺ ថាមពលនៃអាជីវកម្ម (Business Dynamism) ដែលមានចំណាត់ថ្នាក់លេខ ១២៧ ក្នុងចំណោមប្រទេសចំនួន១៤១។[28]

### ២.១.៣. សូចនាករឆ្លុះបញ្ចាំងពីសេដ្ឋកិច្ចឌីជីថលកម្ពុជា

#### ២.១.៣.១. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា

- **ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័ត ( Mobile phone subscription)**

ដោយយោងទៅតាមគេហទំព័រផ្លូវការរបស់និយ័តករទូរគមនាគមន៍កម្ពុជា បានបង្ហាញអោយឃើញថាចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័តនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ ២០១៨ មានរហូតដល់ប្រមាណ ១៩.៤ លាន ក្រោយមកទៀតមកដល់ឆ្នាំ២០១៩ មានការកើនឡើងមកដល់ចំនួន ២១.៦លាន។អ្វីដែលគួរអោយកត់សម្គាល់នោះមកដល់ឆ្នាំ២០២០មានការធ្លាក់ចុះមកត្រឹមចំនួន ២០.៨លាន។ បើយោងតាមអ្វីដែលគេហទំព័រ Khmertimes បានបញ្ជាក់ មូលហេតុនៅពីក្រោយការថយចុះនៃអ្នកប្រើប្រាស់នេះ គឺដោយសារតែមានការហាម

[27] ផ្ទិកាសេដ្ឋកិច្ចពិភពលោក, *Global Competitiveness Index Report 2018 (២០១៨)*

[28] ផ្ទិកាសេដ្ឋកិច្ចពិភពលោក, *Global Competitiveness Index Report 2019 (២០១៩)*

ឃាត់ក្នុងការធ្វើដំណើរពីបរទេសព្រោះតែមានវិបត្តិកូវីដ១៩ ដែលបណ្ដាលអោយមានការថយចុះចំនួនភ្ញៀវទេសចរណ៍មកកាន់ប្រទេសកម្ពុជានៅក្នុងការជាវសេវាកម្មសម្រាប់ការប្រើប្រាស់នេះ។[29]

ក្រាហ្វិកទី១៖ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័ត




ប្រភព៖ និយ័តករទូរគមនាគមន៍កម្ពុជា

- **ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទអចល័ត (Fixed phone subscription)**

ចំនួននៃអ្នកប្រើប្រាស់ទូរស័ព្ទអចល័តកាលពីឆ្នាំ២០១៨ មានចំនួន ៨៨១៥៧ ហើយមកដល់ឆ្នាំ ២០១៩ មានចំនួន ៥៧៤៣៨ រហូតមកដល់ឆ្នាំ២០២០ មានចំនួន ៤៩៣៨១ ។

ក្រាហ្វិកទី២៖ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទអចល័ត




ប្រភព៖ និយ័តករទូរគមនាគមន៍កម្ពុជា

[29] Khmertimes, *Cambodia records 14.8 million mobile internet subscribers as of May, down 2.36 percent* (២០២០)

- **ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេត (Internet subscription)**
  - **អ៊ីនធើណេតចល័ត**

បើរាប់ត្រឹមខែឧសភា ឆ្នាំ២០២១ សម្រាប់អ្នកប្រើប្រាស់អ៊ីនធើណេតចល័តមានការកើនឡើងរហូតដល់ចំនួនប្រមាណ ១៧.២ លាន ដែលបានឆ្លុះបញ្ចាំងចំនួននៃការកើនឡើងជាខ្លាំង បើប្រៀបធៀបជាមួយនឹង ឆ្នាំមុនៗ ។ លោក អ៊ីម វុត្ថា ជាអ្នកនាំសារនៃនិយ័តករទូរគមនាគមន៍កម្ពុជាបានរាយការណ៍មកកាន់ Khmertimes ថា ការកើនឡើងនេះបណ្តាលមកពីមានការលូតលាស់នូវចំនួននៃសហគ្រាសធុនតូចនិងមធ្យម អាជីវកម្មតាមប្រព័ន្ធអនឡាញ និងការសិក្សាតាមប្រព័ន្ធអនឡាញដោយសារតែស្ថិតនៅក្នុងបរិបទកូវីដ១៩ ។

ក្រាហ្វិកទី៣៖ ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេតចល័ត




ប្រភព៖ និយ័តករទូរគមនាគមន៍កម្ពុជា

  - **អ៊ីនធើណេតអចល័ត**

សេវាអ៊ីនធើណេតអចល័ត មានការកើនឡើងក្នុងចន្លោះមួយដែលខ្ពស់ បើរាប់តាំងពីឆ្នាំ២០១៩ រហូតមកដល់ឆ្នាំ ២០២០។ បើរាប់ត្រឹមខែឧសភា ឆ្នាំ២០២១ គេឃើញថាចំនួនមានការកើនឡើងគួរអោយកត់សម្គាល់ ដែលឆ្លុះបញ្ចាំងពីកំណើននៃអ្នកដែលប្រើប្រាស់អ៊ីនធើណេត កាន់តែមានការកើនឡើងយ៉ាងក្នុងរយៈពេលដ៏ខ្លី ដោយសារតែភាគច្រើននៃការងារត្រូវបានផ្លាស់ប្តូរមកជាការធ្វើអ្វីគ្រប់យ៉ាងស្ទើរតែប្រើប្រាស់តាមអនឡាញមិនថា ការលក់ដូរទំនិញ ការអប់រំ ការប្រជុំ ឬការរៀបចំកម្មវិធីសិក្ខាសាលាផ្សេងៗ។

ក្រាហ្វិកទី៤៖ ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេតអចល័ត




ប្រភព៖ និយ័តករទូរគមនាគមន៍កម្ពុជា

សេវាកម្មទូរស័ព្ទចល័ត និងអចល័ត ដែលមានភាពពេញនិយមបំផុតនៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាមានដូចជា Cellcard, Metfone, Smart Axiata , Cootel, និង Seatel។ សេវាកម្មទូរស័ព្ទអចល័តមាន Camintel, និងទូរគមនាគមន៍កម្ពុជា។

### ២.១.៣.២. ការសម្របខ្លួននៅនឹងបច្ចេកវិទ្យា

- **ការអប់រំតាមប្រព័ន្ធអនឡាញ**

តាំងពីឆ្នាំ២០២០រហូតមកដល់ពេលនេះសិស្សានុសិស្សគ្រប់ជាន់ថ្នាក់មិនថាថ្នាក់បឋមសិក្សា វិទ្យាល័យ ឬ សាកលវិទ្យាល័យក្តីបានផ្លាស់ប្តូរឥរិយាបទពីការសិក្សាផ្ទាល់នៅសាលា មកជាការសិក្សាតាមប្រព័ន្ធអនឡាញវិញដោយសារតែបរិបទកូវីដ១៩ សាលាគ្រប់ជាន់ថ្នាក់ មិនថារដ្ឋ ឬឯកជនក្តីមិនទាន់អាចធ្វើការបើកអោយមានការសិក្សាដោយជួបមុខផ្ទាល់ដូចពីមុននៅឡើយ។ ការដែលផ្លាស់ប្តូរបែបនេះ គឺក្នុងគោលបំណងរក្សាគម្លាត និងសុវត្ថិភាពសម្រាប់កុលបុត្រកុលធីតាជំនាន់ក្រោយដែលជាទំពាំងស្នងឬស្សី។ ថ្វីត្បិតតែដំបូងឡើយសិស្សានុសិស្សគ្រប់ជាន់ថ្នាក់បានជួបបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធនឹងការសិក្សាដោយប្រព័ន្ធអនឡាញនេះ ក៏ប៉ុន្តែសិស្សគ្មានជម្រើសនោះឡើយ ព្រោះថាស្ថានភាពនេះបានកើតឡើងទូទាំងសាកលលោកទៅហើយ មានតែការព្យាយាមសម្របខ្លួនសិក្សាតាមបែបថ្មី ដើម្បីមានឱកាសទទួលបានការអប់រំក្នុងពេលដ៏លំបាកនេះទើបអាចជំនះសិក្សារហូតដល់ទីបញ្ចប់បាន។ ការដែលសិក្សាតាមប្រព័ន្ធអនឡាញបែបនេះ បានបើកផ្លូវអោយយុវជនកម្ពុជាកាន់តែពង្រឹងសមត្ថភាពរបស់ខ្លួននៅក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដែលជាស្ពានឈានទៅរកការវិវត្តនៃការអប់រំបែបឌីជីថលបែបពេញលេញនាពេលអនាគត ដោយសារតែការបន្សាំខ្លួនជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យា

នៅក្នុងការរៀនសូត្រ មិនថាការសិក្សាតាម ZOOM, Google Meet, ឬ Google Classroom នោះឡើយ វាសុទ្ធតែបានបង្រៀនអោយពួកគេបង្កើនសមត្ថភាពរបស់ខ្លួន នៅក្នុងការប្រើប្រាស់កម្មវិធីទាំងនោះនៅក្នុងរយៈពេលវែងដោយសារតែភាពមិនច្បាស់ការថាតើពេលណាទើបស្ថានភាពកូវីដនឹងបានធូរស្រាល។

- **ការទិញ និងទូទាត់តាមប្រព័ន្ធអនឡាញ**

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រជាជនកម្ពុជាមានការពេញនិយមប្រើប្រាស់គណនីធនាគារ និងកាបូបអេឡិចត្រូនិចផ្សេងៗដូចជា Wing, Pipay, និង Truemoney ជាដើម ដោយសារតែវាមានភាពងាយស្រួលនៅក្នុងការទុកដាក់ប្រាក់ ទូទាត់ប្រាក់មិនថានៅក្នុងការទិញកាតទូរស័ព្ទ ការទូទាត់ទឹកភ្លើង ឬសេវាកម្មផ្សេងៗ ។ អ្វីដែលពិសេសជាងនេះទៅទៀត ការដាក់និងដកប្រាក់នៅក្នុងវិស័យធនាគារកាន់តែមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។

បើរាប់ពីខែមករា ឆ្នាំ២០១៩ មានតែប្រជាជនចំនួន 0.៦០ ភាគរយតែប៉ុណ្ណោះដែលធ្វើការជាវទំនិញ និងទូទាត់តាមប្រព័ន្ធអនឡាញ ក៏ប៉ុន្តែបើប្រៀបធៀបត្រឹមរបាយការណ៍ដែលចេញកាលពីខែមករា ឆ្នាំ២០២១ នេះបានបង្ហាញអោយឃើញថា បច្ចុប្បន្ននេះមានការកើនឡើងនូវភាគរយនៃអ្នកធ្វើការជាវនិងទូទាត់តាមប្រព័ន្ធអនឡាញរហូតដល់ ៣.៨ភាគរយនៃប្រជាជនសរុបប្រមាណ១៦.៨៣លាននាក់។[30] កម្រិតនៃអ្នកប្រើប្រាស់បណ្តាញសង្គមមានការកើនឡើងប្រមាណ ២.៣ លាននាក់ ត្រឹមចន្លោះដើមឆ្នាំ២០២០ និងដើមឆ្នាំ២០២១។ ជាមួយនឹងការកើនឡើងនៃអ្នកប្រើប្រាស់អ៊ីនធើណេតនិងទូរស័ព្ទដៃ គួបផ្សំជាមួយនឹងពលរដ្ឋភាគច្រើនស្ថិតនៅក្នុងវ័យក្មេងបណ្តាលអោយមានការកើនឡើងអ្នកដែលធ្វើការទិញទំនិញតាមប្រព័ន្ធអនឡាញដោយចូលតាមរយៈគេហទំព័រមួយចំនួនដូចជា Khmer24 , Little Fashion, និង MyPhsar ជាដើម។ មិនតែប៉ុណ្ណោះ ក៏មានការកើនឡើងនៃការទិញទំនិញតាមរយៈកម្មវិធីបណ្តាញសង្គមផ្សេងៗដូចជា ហ្វេសប៊ុក ឬ Instagram ជាដើម។

- **ការដឹកជញ្ជូនរហ័ស**

ការដឹកជញ្ជូនកាន់តែមានភាពជឿនលឿនដែលបង្កអោយមានភាពងាយស្រួល សម្រាប់អ្នកប្រកបរបរអាជីវកម្មចំណេញពេលវេលា និងអាចដឹកជញ្ជូនបានរហ័សជាងមុនដែលអាចបំពេញតម្រូវការអតិថិជនបានទាន់ពេលវេលា និងការលក់កាន់តែមានប្រសិទ្ធភាព។ លើសពីនេះទៅទៀត ភាគច្រើនយុវជនប្រើប្រាស់នូវកម្មវិធីទូរស័ព្ទដៃសម្រាប់ការជាវទំនិញ មិនថាជាភេសជ្ជៈ ចំណីអាហារ ឬឧបករណ៍ផ្សេងទៀតនៅក្នុងការរស់នៅប្រចាំថ្ងៃ ជាពិសេសនៅក្នុងចំណោមអ្នកដែលរវល់ជាមួយនឹងការងារច្រើន និងសិស្សនិស្សិត ព្រោះថាវាបង្កើនភាពងាយស្រួល និងសុវត្ថិភាព ចំណេញពេលវេលា ដោយមិនចាំបាច់ត្រូវទៅកាន់ទីតាំងផ្ទាល់ តែមានការដឹកដល់ទី

[30] Data reportal (២០២១)

តាំង ដែលគ្រាន់តែចាំនៅពេលដែលគេដឹកមកដល់ ចេញទៅទទួលតែប៉ុណ្ណោះ។ កម្មវិធីដែលមានការពេញនិយមភាគច្រើននៅក្នុងចំណោមមនុស្សបច្ចុប្បន្នក្នុងការទិញរបស់សម្រាប់បរិភោគមានដូចជាFoodpanda Nham24 E-Get និងMuuve ជាដើម។

មិនតែប៉ុណ្ណោះ ការដឹកជញ្ជូនទំនិញផ្សេងៗពីអ្នកលក់អនឡាញ ក៏កាន់តែមានការកើនឡើងជាលំដាប់ ដោយសារតែប្រជាជនកម្ពុជាបច្ចុប្បន្នកាន់តែមានទំនោរនៅក្នុងការជាវតាមប្រព័ន្ធអនឡាញ ដែលជំរុញអោយអ្នកផ្គត់ផ្គង់សេវាកម្មនេះកាន់តែមានការកើនឡើងទៅតាមនោះផងដែរ។ ភាគច្រើន អ្នកដែលប្រកបអាជីវកម្មអនឡាញបច្ចុប្បន្ន មានភាគតិចណាស់ដែលដឹកទំនិញដោយខ្លួនឯង ព្រោះថាភាគច្រើនគេប្រើប្រាស់សេវាកម្មដឹកជញ្ជូនរហ័សដែលមានដូចជា J&T, Grab, VBT, និងសេវាកម្មដឹកជញ្ជូនរហ័សផ្សេងទៀតជាច្រើន។

## ២.២.ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការកសាងសេដ្ឋកិច្ចឌីជីថល

### ២.២.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

នៅក្នុងចតុកោណទី២ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃនីតិកាលទី៦ ដែលបានបង្កើតឡើងកាលពីឆ្នាំ២០១៨ ធ្វើការផ្តោតសំខាន់ទៅលើការធ្វើពិពិធកម្មសេដ្ឋកិច្ច ក្នុងនោះមានមុំទី៣ ដែលមានការគាំទ្រទៅលើការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤។ ដោយសារតែបដិវត្តន៍ឧស្សាហកម្មបានធ្វើអោយមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវស្ថានភាពសេដ្ឋកិច្ច និងសង្គមទូទាំងសាកលលោក បានជម្រុញអោយរដ្ឋាភិបាលកម្ពុជាយក ចិត្តទុកដាក់នៅក្នុងការរៀបចំខ្លួនចាប់យកកាលានុវត្តភាព និងការត្រៀមខ្លួនឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្សេងៗដែលអាចកើតមានឡើងនៅក្នុងដំណើរការឈានទៅរកសេដ្ឋកិច្ចឌីជីថលនេះ។

ដោយឈរលើមូលដ្ឋាននេះ រដ្ឋាភិបាលនៅក្នុងនីតិកាលទី ៦ កំពុងតែផ្តោតអាទិភាពលើះ

- ទី១ ការរៀបចំ និងអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈពេលវែង និងដាក់វិស័យឌីជីថលជាអនុវិស័យនៅក្នុងប្រព័ន្ធគណនីជាតិ។
- ទី២ ការបន្តធ្វើបច្ចុប្បន្នភាព និងអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ការរៀបចំ និងអនុវត្តក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។
- ទី៣ ការបន្តពង្រឹង និងពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់ រួមមាន៖ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ និងដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក

ព្រមទាំងឡូជីស្ទិក និងហេដ្ឋារចនាសម្ព័ន្ធទូទាត់សងប្រាក់អេឡិកត្រូនិច ព្រមទាំងពិនិត្យលទ្ធភាពកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ ចូល ប្រព័ន្ធអ៊ីនធើណេតថ្នាក់ជាតិ។

- ទី៤ ការជម្រុញ និងការបង្កើតមូលដ្ឋានគតិយុត្តគាំទ្រដល់វិស័យអភិវឌ្ឍវិស័យឌីជីថល ដោយរួមមានការជំរុញការអនុវត្តយុទ្ធសាស្ត្ររដ្ឋាភិបាលឌីជីថល និងសន្តិសុខព័ត៌មាន ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលគាំទ្រ និងជម្រុញការរីកចម្រើន និងការការពារហានិភ័យនៅក្នុងវិស័យនេះ។
- ទី៥ ការអភិវឌ្ឍជំនាញ និងការអប់រំ ការបណ្តុះបណ្តាល ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលអោយបានទូលាយ និងបញ្ចូលការប្រើប្រាស់និងការយល់ដឹងពីបច្ចេកវិទ្យាព័ត៌មានទៅក្នុងកម្មវិធីសិក្សា ស្របតាមតម្រូវការទីផ្សារការងារ រួមទាំងបង្កើតយន្តការភាពជាដៃគូរវាងធុរកិច្ច និងគ្រឹះស្ថានអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតការអភិវឌ្ឍ និងបណ្តុះបណ្តាលជំនាញឌីជីថលថ្មីៗ។
- ទី៦ ការអភិវឌ្ឍសហគ្រិនភាព និងប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ ការជម្រុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងធុរកិច្ច និងការបង្កើតយន្តការសហប្រតិបត្តិការសហគ្រិនភាព ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល ឬ ភាពជាដៃគូជាមួយវិស័យឯកជន។[31]

### ២.២.២. ផែនការមេបច្ចេកវិទ្យាគមនាគមន៍ ២០២០

ផែនការមេបច្ចេកវិទ្យាគមនាគមន៍ ២០២០ បានលេចរូបរាងឡើងកាលពីឆ្នាំ ២០១៤ ដែលមានគោលបំណងនៅក្នុងការធ្វើអោយប្រទេសកម្ពុជាក្លាយទៅជាប្រទេសវៃឆ្លាត (intelligent nation) តាមរយៈយុទ្ធសាស្ត្រ៤ ធំៗ ដែលមានរួមបញ្ចូលនូវការអភិវឌ្ឍធនធានមនុស្ស(empowering people) , បង្កើនបណ្តាញតភ្ជាប់( ensuring connectivity) បង្កើនសមត្ថភាព (enhancing capacity) និងបង្កើនអោយមានសេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិច (enriching e-services)។ ផែនការមេនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការបង្កើតក្របខណ្ឌគោលនយោបាយសម្រាប់វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាននៅក្នុងប្រទេសកម្ពុជា។[32]

### ២.២.៣. គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០

គោលនយោបាយនេះត្រូវបានរៀបចំនិងធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការដាក់ចេញនូវវិធានការជាអាទិភាពមួយក្នុងចំណោមវិធានការទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជានាអាណត្តិ៥ដើម្បីបន្តចូលរួមអភិវឌ្ឍ

[31] យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៨)

[32] KOICA, *Summary on Cambodian ICT Master Plan 2020 (២០១៤)*

បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន(ប.គ.ព) អោយមានលក្ខណៈបែបទំនើប ទាន់សម័យ មានគុណភាពខ្ពស់ ស្របតាមស្តង់ដាអន្តរជាតិ មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់ទូទាំងប្រទេសដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះ។ ជាការសន្និដ្ឋាន ការរៀបចំនិងការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន(ទ.ប.គ.ព)នេះ ឡើងគូសបញ្ជាក់អំពីភាពចាំបាច់និងភាពបន្ទាន់ក្នុងការបង្កើននូវ "យុទ្ធសាស្ត្រផ្លាស់ប្តូរមូលដ្ឋានសេដ្ឋកិច្ចថ្មី" ដែលឆ្លើយតបទៅនឹងការប្រែប្រួលសេចក្តីត្រូវការក្នុងស្រុក និងសភាពការណ៍ថ្នាក់តំបន់និងពិភពលោកដែលកំពុងវិវត្តន៍ឥតឈប់ឈរនិងឆាប់រហ័ស។

គោលនយោបាយអភិវឌ្ឍន៍វិស័យ ទ.ប.គ.ព មានគោលបំណងផ្តល់នូវចក្ខុវិស័យ ក្របខណ្ឌគោលនយោបាយ ក្របខណ្ឌសម្របសម្រួលក្នុងការអនុវត្តនិងការរៀបចំយន្តការស្ថាប័ន សម្រាប់ជម្រុញការអភិវឌ្ឍវិស័យ ទ.ប.គ.ព នៅកម្ពុជា។ គោលនយោបាយនេះមានកម្មវត្ថុសំខាន់ៗគឺ ទី១ ការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ និងការធ្វើអោយកាន់តែប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងការវិនិយោគលើវិស័យ ទ.ប.គ.ព ប្រកបដោយបរិយាប័ន្ន ចីរភាព និងប្រសិទ្ធភាព ទាំងផ្នែករូបវន្ត និងផ្នែកទន់ អោយសមស្របតាមសក្តានុពលឧត្តមភាពប្រកួតប្រជែង និងសភាពការណ៍វិវត្តន៍ឥតឈប់ឈរនៃបច្ចេកវិទ្យា។ ទី២ គឺការដាក់ចេញនូវវិធានការប្រទាក់ក្រឡាគ្នានិងអន្តរាគមន៍ជាក់លាក់តាមតម្រូវការជាក់ស្តែងនិងមានវិសាលភាពគ្របដណ្តប់សម្រាប់រហូតដល់ឆ្នាំ២០២០ ។ លើសពីនេះ ដើម្បីសម្រេចចក្ខុវិស័យ និងគោលបំណងខាងលើ រាជរដ្ឋាភិបាលសម្រេចយកគោលដៅចំនួនបីគឺ៖

- ការពង្រឹងនិងពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាកម្មទូរគមនាគមន៍ តាមរយៈការពង្រីកវិសាលភាពអ៊ីនធើណេតល្បឿនគ្របដណ្តប់លើទីប្រជុំជន និងតាមទីជនបទ ព្រមទាំងបង្កើនអត្រាប្រើប្រាស់ទូរស័ព្ទដៃអ៊ីនធើណេតនិងការប្រើប្រាស់កុំព្យូទ័រ។
- ការជម្រុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការបង្កើនអត្រានៃមន្ត្រីរាជការថ្នាក់កណ្តាល មន្ត្រីរាជការថ្នាក់មូលដ្ឋានអោយចេះប្រើប្រាស់សូហ្វវែរ(software)មូលដ្ឋាន អត្រាសិស្សានុសិស្សដែលបញ្ចប់ការសិក្សាថ្នាក់ទុតិយភូមិទាំងអស់មានបំណិនវិជ្ជាជីវៈ ប.គ.ព និងបង្កើនអត្រាធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈ ប.គ.ព ។

- ការអភិវឌ្ឍឧស្សាហកម្ម ប.គ.ព អោយមានភាពសម្បូរបែបដោយពង្រឹងយន្តការគ្រប់គ្រង ការរៀបចំចំណាត់ថ្នាក់ និងការចុះបញ្ជីនៃក្រុមហ៊ុនផលិត និងផ្ដល់សេវាកម្ម ប.គ.ព តាមរយៈការជម្រុញការប្រើប្រាស់សារអេឡិចត្រូនិច និងគេហទំព័រតាមស្ថាប័នរដ្ឋាភិបាល។[33]

### ២.២.៤. ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច

ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចត្រូវបានអនុម័តកាលពីថ្ងៃទី ៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃ ១៨ ខែតុលា ឆ្នាំ២០១៩។[34] ច្បាប់នេះមានគោលបំណងគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិច និងផ្ដល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិច។

ច្បាប់នេះមានគោលដៅដូចខាងក្រោម៖

- កំណត់អំពីយថានុភូតភាព សុក្រឹតភាព និងភាពអាចទុកចិត្តបាននៃទម្រង់អេឡិចត្រូនិច។
- ជម្រុញការអភិវឌ្ឍក្របខណ្ឌគតិយុត្តនិងធុរកិច្ចដើម្បីអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចប្រកបដោយសុវត្ថិភាព។
- បង្ការនិងបង្ក្រាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យនិងប្រព័ន្ធព័ត៌មាន។
- លុបបំបាត់ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតឃាលាយលក្ខណ៍អក្សរនិងហត្ថលេខា
- សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិច ជាមួយស្ថាប័នសាធារណៈនិងលើកកម្ពស់ការផ្ដល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈតាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិចដែលអាចជឿទុកចិត្តបាន។
- បង្កើតវិធានការ បទប្បញ្ញត្តិ និងស្តង់ដា ដែលទាក់ទងនឹងយថាភូតភាពនិងសុក្រិតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិច។

ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធតាមប្រព័ន្ធអេឡិចត្រូនិច មានចំនួន១២ ជំពូក ដែលមានស្ដីអំពី បទប្បញ្ញត្តិទូទៅ សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិច ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិច កំណត់ត្រាអេឡិចត្រូនិច និងហត្ថលេខាអេឡិចត្រូនិចដែលមានសុវត្ថិភាព អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាម

[33] គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០ (២០១៦)

[34] ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច (២០១៩)

ប្រព័ន្ធអេឡិចត្រូនិច កិច្ចការពារអ្នកប្រើប្រាស់ សកម្មភាព និងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិច ភស្តុតាងអេឡិចត្រូនិច ការទូទាត់ និង/ឬ ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច សមត្ថកិច្ច ការប្តឹងតវ៉ា និងនីតិវិធីនៃការផាកពិន័យ ទោសប្បញ្ញត្តិ និង អវសានប្បញ្ញត្តិ។

### ២.២.៥. ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលត្រូវបានរៀបចំដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិរួចរាល់កាលពីខែឧសភាឆ្នាំ២០២១។ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលមានចក្ខុវិស័យ "កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថលនៅគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ ទាំងធុរជន ដើម្បីជម្រុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី" ។

ទន្ទឹមនឹងនេះផងដែរ គោលបំណងនៃគោលនយោបាយនេះផ្តោតលើ "ការកសាងសេដ្ឋកិច្ចឌីជីថលឱ្យក្លាយជាចន្ទល់សេដ្ឋកិច្ចថ្មីផង និងជាប្រព័ន្ធអេកូឡូស៊ីរួមចំណែកបង្កើនផលិតភាព និង ប្រសិទ្ធិភាពសេដ្ឋកិច្ច និង លើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋរបស់សង្គមឌីជីថលផង" ។

ក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា តាមចក្ខុវិស័យ និងគោលបំណងខាងលើ មានក្របខណ្ឌគោលនយោបាយកំណត់យកគោលដៅចម្បងចំនួន៥ ដែលមានដូចជា៖

- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល
- ការកសាងពលរដ្ឋឌីជីថល
- ការកសាងរដ្ឋាភិបាលឌីជីថល
- ការជំរុញធុរកិច្ចឌីជីថល

គោលដៅទាំង៥នេះនឹងត្រូវបានអនុវត្តក្រោមយន្តការសម្របសម្រួលរួមដើម្បីធានាបាននូវកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីបុរេសកម្ម ការវិនិយោគ និងការចូលរួមពីតួអង្គដែលពាក់ព័ន្ធ។ ក្របខណ្ឌគោលនយោបាយនេះកំណត់ផងដែរនូវតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ដំណើរការការងារ ការសម្របសម្រួល និងទំនាក់ទំនង ក្នុងការអនុវត្តវិធានការ និងផែនការសកម្មភាព។

ការធ្វើបរិវត្តកម្មឌីជីថលចាប់ផ្តើមពីស្នូលនៃការធ្វើកំណែទម្រង់ស្ថាប័នដោយឈរលើមូលដ្ឋានឌីជីថលដែលក្នុងនោះរួមមានការរៀបចំថ្នាលឌីជីថល និងការប្រើប្រាស់ទិន្នន័យដែលកើតចេញពីការធ្វើអន្តរសកម្មនៃតួអង្គសំខាន់ៗក្នុងជម្រុញនិងអភិវឌ្ឍសង្គមឌីជីថល។

ដើម្បីពន្លឿនការចាប់យក និងការទាញយកផលប្រយោជន៍ជាអតិបរមាពីការវិវឌ្ឍនៃបច្ចេកវិទ្យាឌីជីថល សំដៅជំរុញ និងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល រដ្ឋាភិបាលកម្ពុជាបានធ្វើការកំណត់គោលនយោបាយធំៗចំនួន៣ ដែលរួមមាន ការកសាងមូលដ្ឋានគ្រឹះឌីជីថល ការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល។[35]

- ការកសាងមូលដ្ឋានគ្រឹះឌីជីថល និងការចាប់យកឌីជីថល៖ សំដៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែកទន់ និងរឹង ក៏ដូចជាការតភ្ជាប់ និង ការរៀបចំ និងការបង្កើតនូវប្រព័ន្ធអេកូឡូស៊ី តាំងពីក្របខណ្ឌស្ថាប័នក្របខណ្ឌច្បាប់ ធនធានមនុស្សរហូតដល់សុវត្ថិភាព និងសន្តិសុខ ដើម្បីជាមូលដ្ឋានរឹងមាំក្នុងការគាំទ្រ និង បង្កើនភាពជឿជាក់ក្នុងការទទួលយក និង ការចាប់យកបច្ចេកវិទ្យាឌីជីថល ទៅប្រើប្រាស់ក្នុងគ្រប់ទិដ្ឋភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ សកម្មភាពអាជីវកម្មរបស់វិស័យឯកជន សកម្មភាពនៃការផ្តល់និងទទួលសេវាកម្មសាធារណៈ និងសកម្មភាពនៃអន្តរកម្មរបស់គ្រប់តួអង្គ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ច និងសង្គម។
- ការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល៖ សំដៅកសាង និងអភិវឌ្ឍសមត្ថភាពរបស់តួអង្គសំខាន់ៗរបស់ប្រព័ន្ធសេដ្ឋកិច្ច និងសង្គម អោយកាន់តែប្រសើរឡើងតាមរយៈបទពិសោធន៍នៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ការបន្តអភិវឌ្ឍធនធានមនុស្ស ការពង្រឹងការស្រាវជ្រាវ និង អភិវឌ្ឍន៍ ការបន្តធ្វើទំនើបកម្មប្រព័ន្ធរដ្ឋ និង សេវាសាធារណៈ ការពង្រឹង និង ការពង្រីកសហប្រតិបត្តិការទាំងនៅក្នុងប្រទេស តំបន់ និង សកល ដើម្បីអោយការត្រៀមខ្លួនរបស់តួអង្គសំខាន់ៗកាន់តែប្រសើរឡើង ក្នុងការជម្រុញបរិវត្តិកម្មឌីជីថល។
- ការធ្វើបរិវត្តកម្មឌីជីថល៖ សំដៅលើការពន្លឿនការធ្វើបរិវត្តិកម្មសេដ្ឋកិច្ច និងសង្គម ឆ្ពោះទៅរកសេដ្ឋកិច្ច និងសង្គមឌីជីថលដ៏រស់រវើកដោយសារមានមូលដ្ឋានគ្រឹះរឹងមាំ ធនធានមនុស្សដែលកាន់តែមានសមត្ថភាព បរិយាកាសប្រព័ន្ធអេកូឡូស៊ីកាន់តែអំណោយផល និងសង្គមឌីជីថលដែលមានការចូលរួម និងការប្រើប្រាស់បច្ចេកវិទ្យាកាន់តែខ្ពស់ ដើម្បីជាមាគ៌ា និងទិសដៅជាក់លាក់សម្រាប់កម្ពុជាក្នុងការជម្រុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គមតាមកន្លងប្រក្រតីភាពថ្មីដោយបច្ចេកវិទ្យាឌីជីថល។

ក្របខណ្ឌគោលនយោបាយនេះ ជាឯកសាររស់ ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធមានលទ្ធភាពដាក់ចេញនូវផែនការសកម្មភាពបន្ថែមដែលមានពាក់ព័ន្ធ និងការឆ្លើយតបទៅនឹងការជម្រុញ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលទៅតាមភាពចាំបាច់ និងតម្រូវការជាក់ស្តែង។ ផ្អែកលើគ្រឹះទាំង២ និងសសរសម្តទាំង៣ ដែល

[35] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)

បានកំណត់មូលដ្ឋានអាទិភាពសម្រាប់ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា គួបផ្សំនឹងការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានមួយចំនួននៃបច្ចេកវិទ្យាឌីជីថលទៅលើសេដ្ឋកិច្ច និងសង្គមគេបានចាត់វិធានការគោលនយោបាយជាគោលការណ៍មូលដ្ឋានរួមមាន៖

- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល
- ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល
- ការកសាងពលរដ្ឋឌីជីថល
- ការកសាងរដ្ឋាបាលឌីជីថល
- ការជម្រុញធុរកិច្ចឌីជីថល
- ការកាត់បន្ថយផលប៉ះពាល់

វិធានការដែលបានកំណត់ក្នុងផ្នែកនេះនឹងត្រូវបានកំណត់លម្អិតនូវក្របខណ្ឌពេលវេលាជាក់លាក់ដែលរួមមាន រយៈពេលខ្លី មធ្យម និងវែង ព្រមទាំងការកំណត់សមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ។

## ២.៣. ចំណុចរបត់នៃសេដ្ឋកិច្ចឌីជីថលក្នុងបរិបទកូវីដ១៩

ថ្វីត្បិតតែប្រទេសកម្ពុជានៅមានកម្រិតនៅក្នុងការសម្រេចបំណងឈានទៅរកសេដ្ឋកិច្ចបែបឌីជីថលពេញលេញក៏ពិតមែន ស្ថានភាពកូវីដ១៩បានបង្កើតអោយមានចំណុចរបត់នៃសេដ្ឋកិច្ចដោយសារតែមានការកើនឡើងនៅក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត ការកម្សាន្តបែបអនឡាញ អាជីវកម្មបែបអនឡាញ ការដាក់បញ្ចូលនូវបច្ចេកវិទ្យាចូលទៅក្នុងសហគ្រាស ការសម្របខ្លួនជាមួយនឹងការទូទាត់បែបឌីជីថល និងការគាំទ្រពីរដ្ឋាភិបាលដោយយកចិត្តទុកដាក់ផងដែរ។[36]

ស្ថានភាពកូវីដ១៩ប្រៀបដូចជាកាតាលីករនៅក្នុងការជំរុញអោយមានការរីកចំរើនផ្នែកសេដ្ឋកិច្ចឌីជីថលមិនថានៅក្នុងប្រទេសកម្ពុជា ឬប្រទេសផ្សេងទៀតជាច្រើន។ ថ្វីត្បិតតែស្ថានភាពកូវីដ១៩ បានធ្វើអោយមានបញ្ហាប្រឈមផ្សេងៗ ដូចជាមានការប៉ះពាល់ទៅលើការធ្វើពាណិជ្ជកម្មជាមួយនឹងបរទេស ការហាមឃាត់ការធ្វើដំណើរក្នុងស្រុក និងក្រៅប្រទេស និងប៉ះពាល់ដល់វិស័យទេសចរណ៍ជាខ្លាំង ដោយសារតែមានការហាមឃាត់ការធ្វើដំណើរកម្សាន្តផ្សេងៗ ក្នុងគោលបំណងការពារប្រជាជនរបស់ខ្លួនពីការឆ្លងរីករាលដាលពីអ្នកធ្វើដំណើរមកពីក្រៅប្រទេស បណ្តាលអោយសេដ្ឋកិច្ចមានការធ្លាក់ចុះកាលពីឆ្នាំ២០២០ កន្លងទៅនេះ តែវាក៏បានបង្កអោយមានឱកាសទទួលបាននូវផលប្រយោជន៍ជាមួយគ្នានោះដែរ ពោលគឺស្ថានភាពនេះធ្វើអោយមនុស្សភាគច្រើនត្រូវ

[36] Mekong Connect, *Post-COVID-19 Economic Recovery In The Mekong Region* (២០២១)

ធ្វើចត្តាឡីស័ក រក្សាគម្លាតសង្គម និងត្រូវបានហាមឃាត់ក្នុងការធ្វើដំណើរក្នុងលក្ខខណ្ឌផ្សេងៗ ក៏ប៉ុន្តែវាជាឱកាសមួយដែលធ្វើអោយមនុស្សភាគច្រើនងាកមករកការរស់នៅបែបថ្មី ដែលមានការពឹងផ្អែកទៅលើវិស័យឌីជីថល ដែលជាវិស័យមួយធ្វើអោយកាន់តែមានភាពងាយស្រួល រហ័ស និងសុវត្ថិភាពដែលចៀសវាងការជួបមុខផ្ទាល់មិនថាការងារ ការសិក្សា ឬការប្រកបរបរអាជីវកម្ម។ ជាហេតុបណ្តាលអោយ ឌីជីថលូបនីយកម្មត្រូវបានបញ្ចូលទៅក្នុងវិស័យខុសៗគ្នានៅក្នុងសង្គម និងសេដ្ឋកិច្ច ដូចជាកំណើននៃអ្នកប្រើប្រាស់បណ្តាញអ៊ីនធើណេត ពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញ និងការដឹកជញ្ជូន ការដាក់បញ្ចូលបច្ចេកវិទ្យានៅក្នុងសហគ្រាស ការកើនឡើងនៃអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុជាដើម ។

ឌីជីថលូបនីយកម្ម ជាដំណើរការនៃការកែសម្រួលការធ្វើអភិបាលកិច្ច ឬធុរកិច្ច ឬ ដំណើរការសកម្មភាពអ្វីមួយអោយមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។[37]

### ២.៣.១. អ្នកប្រើប្រាស់បណ្តាញអ៊ីនធើណេត

អ្វីដែលគួរអោយកត់សម្គាល់នោះគឺ ស្ថានភាពកូវីដ១៩នេះបានជម្រុញអោយមានការកើនឡើងនៃអ្នកប្រើប្រាស់អ៊ីនធើណេត និងអ្នកប្រើបណ្តាញសង្គមជាច្រើនដែលជាផ្នែកមួយនៅក្នុងការជម្រុញអោយ មានការយល់ដឹងបន្ថែមពីការប្រើប្រាស់បច្ចេកវិទ្យាដើម្បីទាញយកផលប្រយោជន៍ផងដែរ។ទោះបីជាចំនួននៃអ្នកប្រើប្រាស់បណ្តាញអ៊ីនធើណេត និងបណ្តាញសង្គមមិនអាចឆ្លុះបញ្ចាំងទំនាក់ទំនងស៊ីជម្រៅពីកម្រិតដែលវាចូលរួមក្នុងការបង្កើនអោយមានសេដ្ឋកិច្ចឌីជីថលកើនឡើងកម្រិតណាមួយក៏ពិតមែន ក៏ប៉ុន្តែវាបានចូលរួមតំណាងកម្រិតនៃការកើនឡើងពីការយល់ដឹង និងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងជីវិតប្រចាំថ្ងៃ និងសមត្ថភាពដែលអាចធ្វើអោយមានឌីជីលូបនីយកម្ម។

តាំងពីមានការកើតឡើងនូវស្ថានភាពកូវីដ១៩ រហូតមកដល់ឆ្នាំ២០២១ ខែ មករា ទិន្នន័យបានបង្ហាញអោយឃើញថា ភាគរយនៃប្រជាជនដែលមានការប្រើប្រាស់អ៊ីនធើណេតមានរហូតដល់ ៥០ភាគរយនៃចំនួនប្រជាជនសរុបនៅក្នុងប្រទេសកម្ពុជា ខណៈពេលដែលភាគរយនៃការប្រើប្រាស់ទូរស័ព្ទ (Mobile Connection) មានការកើនឡើងរហូតដល់ ១២៥.៨ភាគរយ ដោយសារតែភាគច្រើនពលរដ្ឋម្នាក់មានការប្រើប្រាស់ទូរស័ព្ទលើសពីមួយ។ ក្នុងរយៈពេលនៃស្ថានភាពកូវីដ១៩ មួយឆ្នាំកន្លងទៅនេះ បានឆ្លុះបញ្ចាំង អោយឃើញថា មានការកើនឡើងយ៉ាងរហ័សនៃប្រជាពលរដ្ឋដែលប្រើប្រាស់អ៊ីនធើណេត ជាងប្រមាណ ១លាននាក់ ដែលជាសរុបទៅពលរដ្ឋសរុបដែលប្រើប្រាស់អ៊ីនធើណេត មានរហូតដល់ ៨.៨៦លាននាក់ ក្នុងចំណោមប្រជាជនចំនួន ១៦លាននាក់នៅក្នុងប្រទេសកម្ពុជា។

[37] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)

### ២.៣.២. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងការដឹកជញ្ជូន

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចនិងការដឹកជញ្ជូនហ៏សបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រប សម្រួលប្រជាពលរដ្ឋនៅក្នុងស្ថានភាពកូវីដ១៩នេះ។ ស្ថានភាពកូវីដ១៩នេះបានជម្រុញអោយសហគ្រាសភាគច្រើនត្រូវបង្វែររបៀបនៅក្នុងការធ្វើអាជីវកម្មរបស់ខ្លួនទៅជាការប្រកបតាមអនទ្បាញបន្ថែម ដើម្បីរក្សាជំហរអាជីវកម្មរបស់ខ្លួនក្នុងស្ថានភាពលំបាកនេះ និងឆ្លងកាត់ទៅមុខបាន។ ដោយសារតែស្ថានភាពនេះ តម្រូវអោយមានការរក្សាគម្លាតសង្គម និងមានការដាក់គោលការណ៍ហាមឃាត់ការធ្វើដំណើរ មានការបិទខ្ទប់ ហេតុនេះហើយ សហគ្រាសទាំងឡាយណាដែលមានបំណងក្នុងការបន្តអាជីវកម្មរបស់ខ្លួនត្រូវតែធ្វើទំនើបភាវូបនីយកម្មនៃអាជីវកម្មរបស់ខ្លួន ដោយមានការផ្លាស់ប្តូរពីការប្រកបអាជីវកម្មបែបបម្រើសេវាកម្ម ឬលក់នៅក្នុងហាងមកជាការធ្វើអាជីវកម្មតាមបណ្តាញសង្គម និងប្រភេទកម្មវិធីឌីជីថលផ្សេងៗ។ ឧទាហរណ៍ដូចជា សហគ្រាសមានការបង្កើតគេហទំព័រហ្វេសប៊ុករបស់ខ្លួនដើម្បីបង្កើនការលក់របស់ខ្លួនក្នុងស្ថានភាពកូវីដ១៩។ ក្នុងពេលនេះផងដែរ អាជីវកម្មភាគច្រើនបង្កើតភាពជាដៃគូជាមួយនឹងក្រុមហ៊ុនដឹកជញ្ជូនផ្សេងៗ ដើម្បីសម្រួលដល់ការដឹកជញ្ជូនទំនិញរបស់ខ្លួនទៅកាន់អតិថិជនដែលបានជាវតាមប្រព័ន្ធអនទ្បាញ។ ជាពិសេសសម្រាប់ហាងឬភោជនីយដ្ឋានភាគច្រើនធ្វើការដាក់លក់នូវទំនិញរបស់ខ្លួននៅក្នុងកម្មវិធីទូរស័ព្ទដៃ ដូចជា Foodpanda, Nham24, Grab និងកម្មវិធីផ្សេងៗទៀត។

### ២.៣.៣. កន្លែងការងារ និងឌីជីថលូបនីយកម្ម

លើសពីនេះទៅទៀត យើងកត់សម្គាល់ឃើញថា សូម្បីតែរបៀបនៃការធ្វើការក៏មានការប្រែប្រួលផងដែរ ដែលរួមមានដូចជា ការធ្វើការពីចម្ងាយនៅផ្ទះរបស់ខ្លួន បានក្លាយទៅជារបៀបនៃការធ្វើការបែបធម្មតាទៅហើយ នៅក្នុងកំឡុងពេលបិទខ្ទប់ និងកំឡុងពេលមានការហាមឃាត់ការធ្វើដំណើរ។ ម្យ៉ាងវិញទៀត ដើម្បីធ្វើការអនុវត្តតាមគោលការណ៍ដែលរដ្ឋាភិបាលបានកំណត់ ដើម្បីឆ្លើយតបទៅនឹងការរាលដាលឆ្លងសហគមន៍ព្រឹត្តិការណ៍ ២០ កុម្ភៈ ឆ្នាំ២០២១ ដែលតម្រូវអោយមានការកាត់បន្ថយការជួបជុំគ្នានៅក្នុងការិយាល័យកន្លែងធ្វើការ ការធ្វើការងារពីផ្ទះ គឺជាការសម្របខ្លួនថ្មីសម្រាប់ការការពារសុវត្ថិភាពរបស់ខ្លួនមិនថា នយោជិក ឬ នយោជកនៅក្នុងស្ថាប័នរដ្ឋ ឬឯកជន។ ដោយសារហេតុនេះហើយ ដើម្បីរក្សាស្ថិរភាពនៅក្នុងដំណើរការប្រកបអាជីវកម្មរបស់ខ្លួន និងការផ្តល់សេវាកម្ម និងផលិតផលរបស់ខ្លួន សហគ្រាសត្រូវធ្វើការផ្លាស់ប្តូរមកជាការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅក្នុងការសម្របសម្រួលការងាររបស់ខ្លួន ដែលរួមមានដូចជាការប្រជុំតាមរយៈអនទ្បាញដោយកាត់បន្ថយការជួបមុខផ្ទាល់ ការផ្ញើអ៊ីមែលនិងការធ្វើរបាយការណ៍តាមអនទ្បាញ ការប្រើប្រាស់ប្រព័ន្ធចែករំលែកដើម្បីអោយបុគ្គលិកអាចធ្វើការរួមគ្នាបានក្នុងពេលតែមួយតាមប្រព័ន្ធអនទ្បាញ មិនថានៅឆ្ងាយពីគ្នាយ៉ាងណាក៏ដោយ។ការដែលធ្វើបែបនេះធ្វើអោយមានការពង្រីកនូវចំណេះដឹងផ្នែកអក្ខរកម្មឌីជីថលនៃកម្លាំងពលកម្ម បង្កើនការប្រើ

ប្រាស់បច្ចេកវិទ្យានៅក្នុងការសម្របសម្រួលក្នុងដំណើរការអាជីវកម្ម និងជាជំហានមួយដែលឈានទៅរកការសម្របខ្លួនជាមួយនឹងបច្ចេកវិទ្យាបានកាន់តែច្រើន និងប្រសើរឡើងនាពេលអនាគត។

### ២.៣.៤.ស្ថានភាពកូវីដ១៩ជម្រុញអោយមានការកើនឡើងអ្នកប្រើប្រាស់e-WALLET

ស្ថានភាពកូវីដ១៩ ថែមទាំងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជម្រុញអោយប្រជាជនផ្លាស់ប្តូរទម្លាប់ និងវិធីនៅក្នុងការទូទាត់ប្រាក់ ពីការទូទាត់ជាក្រដាសប្រាក់មកជាការទូទាត់ដោយមិនប្រើក្រដាសប្រាក់ ដូចជាការទូទាត់ដោយការស្កេន QR ការប្រើប្រាស់កាតធនាគារ ឬការផ្ទេរប្រាក់តាមគណនីជាដើម។ ដោយយោងតាមរបាយការណ៍ដែលចេញផ្សាយដោយ Mekong Strategic Partner បានបញ្ជាក់ថា វិធីដែលពេញនិយមខ្លាំងបំផុតសម្រាប់អតិថិជនក្នុងការទូទាត់ប្រាក់បច្ចុប្បន្ននេះគឺការទូទាត់ដោយការស្កេន QR ដោយសារតែវាមានភាពងាយស្រួល រហ័ស និងសុវត្ថិភាព ហើយថែមទាំងចៀសវាងការកាន់ក្រដាសប្រាក់ដែលអាចជាប្រភពមួយនៃការការពារខ្លួនពីមេរោគកូវីដ១៩ តាមរយៈក្រដាសប្រាក់ទៀតផង។ ការដែលមានការផ្លាស់ប្តូរទម្លាប់ និងរបៀបនៅក្នុងការទូទាត់បែបនេះបានសបញ្ជាក់អោយឃើញពីការដែលប្រជាជនកម្ពុជាកំពុងតែសម្របខ្លួន ប្រើប្រាស់ និងចាប់យកនូវបច្ចេកវិទ្យាថ្មីទាក់ទងនឹងសេវាហិរញ្ញវត្ថុកាន់តែមានការកើនឡើង។ ការចាប់យកឌីជីថលបែបថ្មីនេះនឹងបន្តទៅនៅក្នុងរយៈពេលវែងទៅមុខទៀត ដោយសារតែវាមានភាពងាយស្រួល និងសុវត្ថិភាព ព្រោះថាគេមិនចាំបាច់កាន់ក្រដាសប្រាក់នៅនឹងដៃ តែគេអាចធ្វើការទូទាត់តាមប្រព័ន្ធឌីជីថលនៅពេលណាក៏បាន រូបិយប័ណ្ណណាក៏បាននិងចំណាយពេលវេលាតិចជាងមុនទៀតផងតាមរយៈសេវាកម្មហិរញ្ញវត្ថុបែបបច្ចេកវិទ្យានេះ។

### ២.៣.៥. ឌីជីថលូបនីយកម្មជាផ្លូវទៅកាន់ភាពដូចដើមវិញ

ឌីជីថលូបនីយកម្ម ជាកាតាលីករដ៏សំខាន់មួយនៅក្នុងការជម្រុញអោយមានកំណើនសេដ្ឋកិច្ច និងចូលរួមនៅក្នុងការធ្វើអោយប្រទេសកម្ពុជាឈានទៅរកសេដ្ឋកិច្ចឌីជីថល ដើម្បីតាមទាន់សម័យកាលបដិវត្តឧស្សាហកម្ម ៤.0 និងទាញយកផលប្រយោជន៍ជាអតិបរមានៅក្នុងសេដ្ឋកិច្ច។ ឌីជីថលូបនីយកម្ម ប្រៀបដូចជាឱសថមួយដែលព្យាបាលប៉ះប៉ូវនូវការបំផ្លិចបំផ្លាញដែលកើតឡើងដោយសារតែវិបត្តិកូវីដ១៩ និងបង្កើតអោយមានភាពប្រសើរឡើងនាពេលអនាគត។ នៅក្នុងកំឡុងពេលកូវីដ១៩នេះ មនុស្សត្រូវបានហាមឃាត់មិនអោយមានការជួបជុំគ្នាដោយផ្ទាល់ច្រើននាក់នោះឡើយ។ ការបិទខ្ទប់ ការហាមឃាត់មិនអោយមានធ្វើដំណើរ បណ្តាលអោយមានការធ្លាក់ចុះនូវចំនួនអតិថិជន ការថយចុះនូវការជាវផ្សេងៗមិនថាផលិតផល ឬសេវាកម្ម រួមទាំងសេដ្ឋកិច្ចមានការធ្លាក់ចុះផងដែរ។ អាស្រ័យហេតុនេះ ដើម្បីអោយអាជីវកម្មនៅតែអាចបន្តដំណើរការទៅមុខបាន ការងារអាចប្រព្រឹត្តទៅបានជោគជ័យ និងអាចបំពេញនូវតម្រូវការរបស់ខ្លួន តម្រូវអោយមានវត្តមានបច្ចេកវិទ្យាឌីជីថលក្នុងការបំពេញតួនាទីជាជំនួយការនៅក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះបានសម្រេចទៅបាន។

អាជីវកម្មអាចបន្តដំណើរការរបស់ខ្លួនតាមរយៈការពង្រឹងការធ្វើទីផ្សារ ការលក់ ការទូទាត់ ការដឹកជញ្ជូន ដោយប្រើប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដែលមានន័យថា ទោះបីជាមិនមានការជួបផ្ទាល់ ក៏ទំនិញ និងសេវាកម្មនៅតែអាចត្រូវបានបញ្ជូនទៅកាន់អតិថិជនតាមប្រព័ន្ធអនឡាញនេះ ហើយការផ្សព្វផ្សាយទំនិញ ឬសេវាកម្មនៅតែអាចត្រូវបានធ្វើឡើង និងទៅដល់មនុស្សជាច្រើននៅតាមប្រព័ន្ធអនឡាញនេះ។ សម្រាប់ការទូទាត់វិញ គេអាចធ្វើការទូទាត់តាមបច្ចេកវិទ្យាឌីជីថល ដោយការផ្ទេរប្រាក់តាមគណនី ឬកាបូបអេឡិចត្រូនិចដូចជា វីង ឬ ទ្រូម៉ាន់នៅជាដើម។ ការប្រជុំអាចប្រព្រឹត្តទៅបានតាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់កម្មវិធីផ្សេងៗដូចជា ហ្ស៊ូម( ZOOM) ហ្គូកហ្គលមីត (Google Meet) ឬ Microsoft Team ជាដើម។ អាស្រ័យហេតុនេះហើយ សកម្មភាពទាំងនេះហើយ ដែលអាចចូលរួមចំណែកនៅក្នុងការធ្វើអោយសេដ្ឋកិច្ចកម្ពុជាអាចងើបឡើងវិញនាពេលខាងមុខមិនថាស្ថិតនៅក្នុងបរិបទកូវីដ១៩ក៏ដោយ។

# ជំពូកទី ៣

# ពលរដ្ឋឌីជីថល

# ជំពូកទី ៣
# ពលរដ្ឋឌីជីថល

## ៣.១. និយមន័យពលរដ្ឋឌីជីថល

ពលរដ្ឋឌីជីថល ជាប្រជាពលរដ្ឋដែលចាប់យកការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការងារ ការរស់នៅប្រចាំថ្ងៃ។[38]

## ៣.២. ជំនាញដែលពលរដ្ឋឌីជីថលត្រូវការក្នុងសេដ្ឋកិច្ចឌីជីថល

### ៣.២.១. ជំនាញទូទៅនៅក្នុងសេដ្ឋកិច្ចឌីជីថល

នៅក្នុងចំណុចនេះ នឹងមានការលើកឡើងជំនាញទូទៅដែលសំខាន់នៅក្នុងសេដ្ឋកិច្ចឌីជីថល ដែលត្រូវបានកំណត់ដោយធនាគារពិភពលោក និងវេទិកាសេដ្ឋកិច្ចពិភពលោក។

#### ៣.២.១.១. ធនាគារពិភពលោក

បច្ចេកវិទ្យាឌីជីថល បានកំពុងតែធ្វើអោយមានការផ្លាស់ប្តូរទម្រង់នៃការធ្វើអាជីវកម្មនិងការគ្រប់គ្រងធនធានមនុស្សនៅតាមសហគ្រាស និងស្ថាប័នផ្សេងៗ។ នាពេលអនាគត មានជំនាញផ្សេងៗគ្នាជាច្រើននឹងបានក្លាយទៅជាជំនាញដែលចាំបាច់នៅក្នុងវិស័យឌីជីថល។ ជំនាញដែលគេត្រូវការមានដូចជាជំនាញបច្ចេកវិទ្យា (technical skill) ដែលមានជាការបង្កើត Software, ការគ្រប់គ្រងវេបសាយ ( web management) ជាដើម ប៉ុន្តែសម្រាប់ជំនាញមួយផ្សេងទៀតគឺមិនសូវជាមានតម្រូវការខ្លាំងទាក់ទងទៅនឹងបច្ចេកវិទ្យាទេ។ ឧទាហរណ៍ នៅតាមបណ្តាស្ថាប័នក្រុមហ៊ុនមួយចំនួនត្រូវការជំនាញដែលបុគ្គល ឬនិយោជកម្នាក់ជំនាញក្នុងការរៀបចំគម្រោងផែនការ ពូកែខាងចរចារ និងសហការជាមួយនឹងដៃគូពាណិជ្ជកម្មឬមិត្តរួមក្រុម និងជាអ្នកដឹកនាំល្អ។ បើយោងទៅតាមធនាគារពិភពលោកបានកំណត់ថាបុគ្គលម្នាក់ត្រូវមានជំនាញ៣ដែលចាំបាច់បំផុតសម្រាប់ការចាប់យកសេដ្ឋកិច្ចឌីជីថលនាពេលអនាគតដែលមាន ជំនាញក្នុងការយល់ដឹងទូទៅ ជំនាញខាងបច្ចេកវិទ្យា និងជំនាញខាងសង្គមនិងអាកប្បកិរិយា។

- ជំនាញក្នុងការយល់ដឹងទូទៅ(cognitive skill)៖ តម្រូវអោយបុគ្គលម្នាក់អាចស្វែងយល់នូវបញ្ហាស្មុគស្មាញ ចេះដោះស្រាយបញ្ហាដែលមានភាពស្មុគស្មាញ ចេះសម្របខ្លួនបានល្អនៅក្នុងបរិយាកាសការងារ អាចរៀនពីបទពិសោធន៍ មានសមត្ថភាពក្នុងការដោះស្រាយឧបសគ្គដោយមានការគិតស៊ីជម្រៅបែបពិចារណា។
- ជំនាញខាងបច្ចេកវិទ្យា (Technical Skill) មានរាប់បញ្ចូលទាំងជំនាញ ICT ៖ ជំនាញនេះគឺតម្រូវអោយចេះធ្វើការប្រើប្រាស់ឧបករណ៍ឌីជីថល និងរបៀបជួសជុលគ្រឿងអេឡិចត្រូនិចផងដែរ ដូចជាការស្វែង

[38] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១)

រកពីមូលហេតុនៃម៉ាស៊ីនដែលមិនដំណើរការ និងជួសជុលរកឬសគល់នៃបញ្ហាដើម្បីអាចដំណើរការម៉ាស៊ីនឡើងវិញ ឬស្វែងរកបញ្ហាដែលបានកើតឡើង និងមូលហេតុដែលបណ្តាលអោយមានភាពរអាក់រអួលទាក់ទងទៅនឹងប្រព័ន្ធSoftware ជាដើម។ ជំនាញICT សំដៅទៅលើការដែលអាចប្រើប្រាស់ប្រព័ន្ធនិងឧបករណ៍បច្ចេកវិទ្យាព័ត៌មានដែលមានចន្លោះលំដាប់ពីអ្នកឯកទេសICT ដែលមានសមត្ថភាពក្នុងការអភិវឌ្ឍ ដំណើរការ និងថែទាំប្រព័ន្ធបច្ចេកវិទ្យាទៅដល់ អ្នកប្រើប្រាស់ ICT មូលដ្ឋាន ដែលជាអ្នកប្រើប្រាស់មានសមត្ថភាពនៅក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថលក្នុងការប្រកបមុខរបរប្រចាំថ្ងៃ។

- ជំនាញខាងសង្គម និងអាកប្បកិរិយា(Social and Behavioral)៖ សំដៅទៅលើជំនាញដែលបុគ្គលម្នាក់មានភាពចេះបត់បែន សម្របខ្លួនតាមកាលៈទេសៈ និងមានអត្តចរិកងាយស្រួលនៅក្នុងការបង្កើតទំនាក់ទំនង និងឆ្លើយតបទៅនឹងស្ថានភាពសង្គមជាក់ស្តែងយ៉ាងមានប្រសិទ្ធភាព។[39]

### ៣.២.១.២. វេទិកាសេដ្ឋកិច្ចពិភពលោក

ដោយយោងទៅតាមរបាយការណ៍ដែលស្តីអំពីការងារនាពេលអនាគត(Future of Jobs) ដែលត្រូវបានចងក្រងដោយវេទិកាសេដ្ឋកិច្ចពិភពលោកបានបញ្ជាក់អោយឃើញថា ជំនាញច្បាស់លាស់(content skill) សមត្ថភាពក្នុងការយល់ដឹងទូទៅ (cognitive skill) និងជំនាញវិធីការ (process skill) នឹងក្លាយជាជំនាញស្នូលដ៏សំខាន់នៅក្នុងសហគ្រាសនាពេលអនាគត។[40]

- ជំនាញច្បាស់លាស់(Content skill) ៖ មានរួមបញ្ចូលអក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន (ICT literacy) និងការរៀនស្ទាត់ជំនាញ (Active learning)។
  - អក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន គឺជាការដែលអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឧបករណ៍ទំនាក់ទំនង និងបណ្តាញសម្រាប់ចូលទៅកាន់ គ្រប់គ្រង បញ្ចូល វាយតម្លៃនិងបង្កើតព័ត៌មាន។
  - ការរៀនស្ទាត់ជំនាញ គឺជាការយល់ដឹងអំពីលទ្ធផលនៃព័ត៌មានថ្មីៗ សម្រាប់ធ្វើការដោះស្រាយបញ្ហា និងធ្វើការសម្រេចចិត្តទាំងនៅក្នុងពេលបច្ចុប្បន្ន និងអនាគត។
- ជំនាញក្នុងការយល់ដឹងទូទៅ(cognitive skill)៖ រួមមាន ប្រឌិតញាណ( creativity),និង ការរកហេតុផលតាមបែបគណិតសាស្ត្រ(Mathematical Reasoning)។
  - ប្រឌិតញាណ គឺជាសមត្ថភាពក្នុងការផ្តល់ជាគំនិតដែលមានភាពខុសប្លែក និងភាពវៃឆ្លាតអំពីប្រធានបទដែលបានលើកឡើង ឬនៅក្នុងស្ថានភាពជាក់ស្តែងមួយ ឬបង្កើតដំណោះស្រាយដែលភាពច្នៃប្រឌិតក្នុងឆ្លើយតបទៅនឹងបញ្ហា។

[39] ធនាគារពិភពលោក, *Digital Divident (២០១៦)*

[40] វេទិកាសេដ្ឋកិច្ចពិភពលោក, *The Future of Jobs (២០១៦)*

- ការរកហេតុផលបែបគណិតសាស្ត្រគឺសមត្ថភាពនៅក្នុងជ្រើសរើសវិធីសាស្ត្រឬរូបមន្តបែបគណិតវិទ្យានៅក្នុងការដោះស្រាយបញ្ហា។

- ជំនាញវិធីការ(process skill)៖ រួមមាន ការស្តាប់បែបស្ទាត់ជំនាញ (Active Listening) ការគិតបែបពិចារណា(critical thinking) ។
  - ការស្តាប់បែបស្ទាត់ជំនាញ គឺជាការយកចិត្តទុកដាក់ទៅអ្វីដែលគេកំពុងនិយាយ យកពេលពិចារណាទៅលើអ្វីដែលត្រូវបានលើកឡើងនិងចេះសួរសំណួរក្នុងកាលទេសៈដែលសមស្របមួយ។
  - ការគិតបែបពិចារណា គឺការចេះប្រើប្រាស់តក្កវិជ្ជា និងការស្វែងរកហេតុផល ដើម្បីចង្អុលបង្ហាញពីភាពខ្លាំងនិងភាពខ្សោយនៃជម្រើសដំណោះស្រាយ សេចក្តីសន្និដ្ឋាន ឬវិធីសាស្ត្រសម្រាប់បញ្ហាមួយជាក់លាក់។

### ៣.២.២. ជំនាញឌីជីថល

ជាកត្តាចាំបាច់ ធនធានមនុស្សត្រូវមានចំណេះដឹងមូលដ្ឋាន និងជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងគំនិតច្នៃប្រតិដ្ឋ និងភាពបត់បែនខ្ពស់ដើម្បីអាចចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មនៃសេដ្ឋកិច្ច និងសង្គមឌីជីថល និងបង្កើនភាពប្រកួតប្រជែងជាមួយនឹងប្រទេសក្នុងតំបន់ផងដែរ។

យោងតាមរបាយការណ៍មួយដែលធនាគារពិភពលោកស្តីអំពីការទទួលបានផលប្រយោជន៍ពីសេដ្ឋកិច្ចឌីជីថលបានធ្វើការលើកឡើងថា ជំនាញឌីជីថលដែលត្រូវការចាំបាច់នៅក្នុងសេដ្ឋកិច្ចឌីជីថលមានបីធំៗគឺ ជំនាញឌីជីថលមូលដ្ឋាន (Basic Digital Skill) ជំនាញបន្ទាប់បន្សំផ្នែកឌីជីថល (Digital Complementary Skill) និងជំនាញខ្ពស់និងឯកទេស(Advanced and Specialist Skill)។[41]

#### ៣.២.២.១. ជំនាញឌីជីថលកម្រិតមូលដ្ឋាន

ជំនាញដែលត្រូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដូចជាការផ្ញើអ៊ីមែល ការស្វែងរកព័ត៌មានតាមអ៊ីនធើណេត សមត្ថភាពនៅក្នុងការប្រើប្រាស់កម្មវិធីឌីជីថល និងការយល់ដឹងពីសុវត្ថិភាពនៅក្នុងការការពារទិន្នន័យនៅក្នុងប្រព័ន្ធអនឡាញ។

#### ៣.២.២.២.ជំនាញបន្ទាប់បន្សំផ្នែកឌីជីថល

ជំនាញទន់ដែលតម្រូវអោយអនុវត្តការងារនៅក្នុងបរិស្ថានដែលសំបូរទៅដោយបច្ចេកវិទ្យាទំនើប និងដើម្បីធ្វើការប្រឈមទៅនឹងការកើនឡើងនៅឱកាសដែលបានកើតឡើងដោយប្រព័ន្ធបច្ចេកវិទ្យា ឧទាហរណ៍ដូចជាការទំនាក់ទំនងតាមបណ្តាញសង្គម ការបង្ហាញផលិតផលនិងសេវាកម្មតាមបច្ចេកវិទ្យាឌីជីថល ឬ វិភាគទិន្នន័យដែលប្រមូលបានតាមរយៈគេហទំព័រ។

---

[41] ធនាគារពិភពលោក, *Benefiting From Digital Economy (២០១៨)*

#### ៣.២.២.៣. ជំនាញខ្ពស់ និងឯកទេស

ជំនាញខ្ពស់និងឯកទេស ជាជំនាញដែលត្រូវការក្នុងការបង្កើតនវានុវត្តន៍ និងគាំទ្រហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការដើរតួនាទីនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចបែបឌីជីថល។ ឧទាហរណ៍ ដូចជា កម្មវិធី Software បង្កើតកម្មវិធី គ្រប់គ្រងបណ្ដាញ និងវិភាគទិន្នន័យ។

## ៣.៣. អក្ខរកម្មឌីជីថល

អក្ខរកម្ម សំដៅលើសមត្ថភាពឬជំនាញនៅក្នុងការអាន និងសរសេរ។ ក៏ប៉ុន្តែនៅពេលដែលយើងប្រើពាក្យឌីជីថលពីក្រោយអក្ខរកម្ម យើងបានពាក្យមួយ អក្ខរកម្មឌីជីថល ដែលពាក្យនេះនឹងឆ្លុះបញ្ចាំងនូវនិយមន័យថ្មីពីពាក្យអក្ខរកម្មមួយម៉ាត់។ អក្ខរកម្មឌីជីថល សំដៅលើសមត្ថភាពនៅក្នុងការចូលប្រើប្រាស់ គ្រប់គ្រង យល់ដឹង ដាក់បញ្ចូល ទាក់ទង វាយតម្លៃ និងការបង្កើតព័ត៌មានដោយសុវត្ថិភាព និងមានភាពសមរម្យតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល សម្រាប់ការប្រកបការងារ និងសហគ្រិនភាពដែលមានភាពសមរម្យ។ វារាប់បញ្ចូលដូចជា អក្ខរកម្មផ្នែកកុំព្យូទ័រ ផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន ផ្នែកព័ត៌មាន ឬទិន្នន័យ និងអក្ខរកម្មផ្នែកផ្សព្វផ្សាយ។[42]

នៅក្នុងនិយមន័យអក្ខរកម្មឌីជីថលមានបង្កប់នូវផ្នែកមួយចំនួនដូចខាងក្រោម៖

- មូលដ្ឋាននៃផ្នែករឹង និងផ្នែកទន់ ៖ ចំណេះដឹងផ្នែកដំណើរការនៃផ្នែករឹង និងផ្នែកទន់ ដូចជាការបើក បិទការសាកថ្ម ការចាក់សោរ និងការកំណត់នូវឯកជនភាព។ល។
- អក្ខរកម្មផ្នែកព័ត៌មាន និងទិន្នន័យ៖ ជាសមត្ថភាពនៅក្នុងការចេះស្វែងរក ជ្រើសរើស និងវាយតម្លៃមាតិកាឌីជីថល។
- ទំនាក់ទំនងនិងសហប្រតិបត្តិការ៖ ជាសមត្ថភាពនៅក្នុងការទាក់ទង ចែករំលែក និងការចូលរួមចំណែក
- ការបង្កើតមាតិកាឌីជីថល៖ សមត្ថភាពនៅក្នុងការអភិវឌ្ឍ ការរួមបញ្ចូល ការពិនិត្យពិច័យមាតិកាឌីជីថលជាមួយនឹងការយល់ដឹងពីកម្មសិទ្ធបញ្ញា និងអាជ្ញាប័ណ្ណ។
- សុវត្ថិភាព៖ ជាសមត្ថភាពនៅក្នុងការការពារឧបករណ៍ឌីជីថល ព័ត៌មានផ្ទាល់ខ្លួន ឯកជនភាព សុខភាពបរិយាកាស និងសុខុមាលភាពរបស់ខ្លួន។
- ការដោះស្រាយបញ្ហា៖ សមត្ថភាពក្នុងការដោះស្រាយបញ្ហាបច្ចេកទេស វិភាគពីតម្រូវការនិងការឆ្លើយតបបែបបច្ចេកទេសតាមរយៈការប្រើប្រាស់គំនិតច្នៃប្រឌិតនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងការគិតបែបវិភាគ។

[42] UNDP, *Digital Literacy for Employability and Entrepreneurship among Cambodian Youths (២០២០)*

- សមត្ថភាពពាក់ព័ន្ធនឹងការងារៈ សមត្ថភាពនៅក្នុងការដំណើរការជាមួយនឹងផ្នែករឹង និងផ្នែកទន់នៅក្នុងការងារអ្វីមួយជាក់លាក់។

## ៣.៤. គម្លាតជំនាញនៅក្នុងប្រទេសកម្ពុជា

ដោយយោងទៅតាមរបាយការណ៍ធនធានមនុស្សកាលពីឆ្នាំ២០១៧របស់វេទិកាសេដ្ឋកិច្ចពិភពលោក ( WEF's Human Capital Report 2017) ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់ទាបបំផុត នៅក្នុងការអប់រំ និងហ្វឹកហាត់ប្រជាពលរដ្ឋរបស់ខ្លួនអោយមានកម្លាំងពលកម្មដែលមានផលិតភាព និងការប្រកួតប្រជែងខ្ពស់ បើធៀបនឹងបណ្តាប្រទេសផ្សេងទៀតនៅក្នុងអាស៊ាន។ ដោយយោងតាមសន្ទស្សន៍ធនធានមនុស្សប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាកលេខ៩២ ក្នុងចំណោម ១៣០ប្រទេស។ ជាមួយគ្នានោះផងដែរ ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ១៤៦ ក្នុងចំណោមប្រទេស១៨៩ នៅក្នុងសន្ទស្សន៍អភិវឌ្ឍមនុស្ស (UNDP's Human Development Index 2019) ដែលជាលេខរៀងទាបបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលរាប់បន្ទាប់ពីប្រទេសមីយ៉ាន់ម៉ា។ ដោយយោងទៅតាម National Employment Agency 2018 នៅក្នុងការវាស់ស្ទង់មតិនិយោជកចំនួន៦០៥នាក់នៅក្នុងប្រទេសកម្ពុជាពីបណ្តាសហគ្រាសផ្សេងៗគ្នា។ មួយភាគបីនៃអ្នកដែលបានមកសម្ភាសបានលើកឡើងថាពួកគេបានជួបប្រទះបញ្ហាគម្លាតជំនាញរួមមានដូចជាកង្វះជំនាញភាសាបរទេស ជំនាញបច្ចេកទេស និងជំនាញខាងទំនាក់ទំនងក៏ដូចជាជំនាញនូវក្នុងការសហការ និងជំនាញក្នុងការដោះស្រាយបញ្ហា។

នៅក្នុងរបាយការណ៍វេទិកាសេដ្ឋកិច្ចពិភពលោកកាលពីឆ្នាំ២០១៦ ដែលស្តីអំពីការងារនាពេលអនាគតបានបញ្ជាក់អោយឃើញថាជំនាញប្រមាណ៣៥ ភាគរយ ដែលត្រូវបានចាត់ទុកថានឹងសំខាន់នៅក្នុងឆ្នាំ២០២០ នឹងអាចជំនួសបានដោយមនុស្សយន្តទំនើប យានជំនិះដែលអាចបើកដោយខ្លួនឯង (Self-driving transport ation) បញ្ញាសិប្បនិម្មិត (AI), ការរៀនម៉ាស៊ីន (Machine learning) នៅក្នុងបដិវត្តន៍ឧស្សាហកម្មទី៤។ ក្នុងករណីនេះ មនុស្សគ្រប់គ្នាដែលរួមមាន និយោជក និយោជិត រដ្ឋាភិបាល និងអ្នកអប់រំ នឹងត្រូវតែពង្រឹងជំនាញរបស់ខ្លួនអោយកាន់តែប្រសើរឡើងរៀនកាន់តែច្រើននិងពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីអាចសម្របខ្លួនបាន។[43]

គួរអោយកត់សំគាល់ផងដែរថា សហគ្រាសដែលធ្វើការពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន ពិបាកនៅក្នុងការស្វែងរកបុគ្គលិកដែលមានជំនាញច្បាស់លាស់នៅក្នុងផ្នែកនេះណាស់ គម្លាតជំនាញនេះកំពុងតែធ្វើអោយការអភិវឌ្ឍរបស់សហគ្រាស ស្ថិតនៅក្នុងកម្រិតយឺតយ៉ាវ កើនឡើងចំណាយនៅក្នុងសហគ្រាស និងប៉ះពាល់ទៅលើកម្រិតនៃការប្រកួតប្រជែងនៃសហគ្រាសនៅក្នុងប្រទេសកម្ពុជា។[44]

---

[43] វេទិកាសេដ្ឋកិច្ចពិភពលោក (២០១៦)

[44] Khmertimes , *Digitising Cambodia's Economic Future (២០១៩)*

នៅពេលដែលយើងធ្វើការលើកឡើងអំពីកម្រិតនៃការត្រៀមខ្លួននៃកម្លាំងពលកម្មដើម្បីធ្វើការចាប់ផ្តើមនៅក្នុងបដិវត្តន៍ឌីជីថល ប្រទេសដែលកំពុងអភិវឌ្ឍន៍ជួបបញ្ហាប្រឈមច្រើននៅក្នុងការទទួលបាននូវជំនាញខាងបច្ចេកវិទ្យាព័ត៌មានបានគ្រប់គ្រាន់។ ដោយយោងទៅតាមការស្រាវជ្រាវកាលពីឆ្នាំ២០១៦របស់ Markova និង Wray ប្រទេសកម្ពុជាមានគម្លាតជំនាញនៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ដែលសហគ្រាសភាគច្រើនពិបាកនៅក្នុងជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពខាងបច្ចេកវិទ្យាព័ត៌មាន។ ខណៈដែលមានបេក្ខជនជាច្រើនបានដាក់ពាក្យចូលបម្រើការងារក្នុងជំនាញ IT កម្រិតទាប ការសិក្សាស្រាវជ្រាវបានបង្ហាញអោយឃើញថា សម្រាប់ការងារដែលទាមទារការប្រើប្រាស់ជំនាញ IT កម្រិតខ្ពស់នៅមានគម្លាតជំនាញខ្លាំងនៅឡើង ដែលបង្ខំចិត្តអោយនិយោជកធ្វើការជ្រើសរើសបេក្ខជនដែលមានកម្រិតជំនាញទន់និងជំនាញភាសាដែលមាមកម្រិតខ្ពស់ជាជាងបេក្ខជនដែលមានសមត្ថភាពខាងបច្ចេកទេស។[45]

បើយើងក្រឡេកមើលការស្រាវជ្រាវរបស់លោក ភក្តី កាលពីឆ្នាំ២០១៩ ដែលលើកឡើងអំពីការត្រៀមខ្លួននៃកម្លាំងពលកម្មបែបឌីជីថលនៃប្រទេសកម្ពុជា បានបញ្ជាក់អោយឃើញថាគម្លាតជំនាញមានដូចជា ការប្រើប្រាស់ភាសាបរទេស ជំនាញខាងបច្ចេកទេស ការដោះស្រាយបញ្ហាជូនអតិថិជន ការទំនាក់ទំនង ការដោះស្រាយបញ្ហា និងការធ្វើការងារជាក្រុម។ ទាក់ទងទៅនឹងជំនាញខាងបច្ចេកវិទ្យាព័ត៌មាន និយោជកភាគច្រើនបានបង្ហាញគំនិតរបស់ខ្លួនថា ការដែលចេះគ្រប់គ្រងព័ត៌មានតាមប្រព័ន្ធអនឡាញ និងការចេះសហការគឺជាជំនាញដែលសំខាន់បំផុត បន្ទាប់ពីជំនាញខាងវិភាគ ដែលគេចង់បាននៅពេលជ្រើសរើសបុគ្គលិកក្នុងរយៈពេល១០ឆ្នាំខាងមុខ។ លើសពីនេះទៅទៀត ការស្រាវជ្រាវរបស់លោក ក៏បានបង្ហាញអោយឃើញទៀតថា និយោជិកភាគច្រើនអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលមូលដ្ឋានដូចជា ការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណេត ការចេះទាញយក(Download) ការផ្ញើអ៊ីមែល ការឆ្លើយសារតាមប្រព័ន្ធអ៊ីនធើណេត និងកម្មវិធីដែលពេញនិយមប្រើនៅកន្លែងធ្វើការគឺកម្មវិធី Microsoft Office ។[46]

## ៣.៥. ទស្សនៈយុវជនភ្នំពេញមកលើសេដ្ឋកិច្ចឌីជីថល

កាលពីកន្លងទៅនេះ ធនាគារជាតិបានធ្វើការស្រាវជ្រាវអំពីទស្សនៈយុវជនមកលើសេដ្ឋកិច្ចឌីជីថលជារួម។ សំណាកនៅក្នុងការស្រាវជ្រាវនេះមានការរាប់បញ្ចូលតែយុវជនដែលរស់នៅទីក្រុងភ្នំពេញដែលមានជីវភាពសមរម្យ និងនិយមប្រើប្រាស់កម្មវិធីឌីជីថលតែប៉ុណ្ណោះ។ ការស្រាវជ្រាវនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងយល់ដឹងពីទស្សនៈរបស់យុវជនដែលរស់នៅទីក្រុងភ្នំពេញមកលើសេដ្ឋកិច្ចឌីជីថល កម្រិតនៃការចាប់យកឌីជីថល បញ្ហាប្រឈមនិងអត្ថប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល កត្តាដែលជំរុញក្នុងការ

[45] Jitka និង Christ, *Skills for Digital Economy (២០១៦)*

[46] Pheakdey Heng, *Preparing Cambodia's Workforce for a Digital Economy (២០១៩)*

ប្រើប្រាស់សេវាកម្មឌីជីថល និងការកម្រិតនៃការត្រៀមខ្លួនក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថលនាពេលអនាគត។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងដោយប្រមូលទិន្នន័យនៃការស្ទង់មតិតាមប្រព័ន្ធអនឡាញដោយបានផ្ញើតំណភ្ជាប់ទៅកាន់យុវជនតាមប្រព័ន្ធសង្គម និងស្ថាប័នផ្សេងៗដើម្បីទទួលបានការឆ្លើយតប ហើយទទួលបានសំណាកចំនួន ៣៧៨ នាក់ ដែលភាគច្រើនជាស្ត្រី ។ ក្នុងនោះផងដែរ ភាគច្រើននៃអ្នកស្ទង់មតិមានការពេញនិយមប្រើប្រាស់សម្រាប់ការអប់រំ ទូទាត់តាមប្រព័ន្ធអនឡាញ និងបញ្ជាទិញអាហារតាមអនឡាញ។ បញ្ហាប្រឈមដែលធ្វើអោយមានការព្រួយបារម្ភនៅក្នុងការប្រើប្រាស់កម្មវិធី និងសេវាកម្មឌីជីថល គឺបណ្ដាញតភ្ជាប់ដែលមានកម្រិតល្បឿនយឺត និងការបារម្ភពីសុវត្ថិភាពនៅក្នុងការប្រើប្រាស់ខ្លាចថាមានការលួចយកទិន្នន័យផ្ទាល់ខ្លួនដែលជាហានិភ័យនាពេលណាមួយ។ ថ្វីត្បិតតែកម្រិតនៃការប្រើប្រាស់កម្មវិធីឌីជីថលទាំងនេះមានការកើនឡើងគួរអោយកត់សម្គាល់នៅក្នុងចំណោមយុវជនដែលរស់នៅភ្នំពេញ ក៏ការយល់ដឹងពីសេដ្ឋកិច្ចឌីជីថលហាក់នៅមានកម្រិតនៅឡើយ។ ក្នុងចំណោមយុវជន ៣៧៨ នាក់ មានតែ ៤៥.៥% តែប៉ុណ្ណោះដែលមានការយល់ដឹងពីសេដ្ឋកិច្ចឌីជីថល។ លើសពីនេះទៅទៀត យុវជនភាគច្រើនបានទទួលស្គាល់ថា ការចាប់យកឌីជីថលពិតជាមានសារៈសំខាន់សម្រាប់កម្ពុជានៅក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថលហើយពួកគេក៏មានកម្រិតនៃការត្រៀមខ្លួនខ្ពស់ក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថលផងដែរ។[47]

## ៣.៦. ការកសាងពលរដ្ឋឌីជីថល

### ៣.៦.១. វិធានការគោលនយោបាយផ្នែកអ្នកដឹកនាំឌីជីថល

ដោយយោងទៅតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលបានលើកឡើងថាក្នុងនិន្នាការធ្វើការនៃការធ្វើឌីជីថលូបនីយកម្មសំដៅទៅបរិវត្តកម្មឌីជីថល ការអភិវឌ្ឍធនធានមនុស្សកម្ពុជាក្លាយជាអ្នកដឹកនាំឌីជីថលតម្រូវអោយមានការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាព ទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ ការអភិវឌ្ឍសមត្ថភាពនៃអ្នកដឹកនាំឌិជីថលនៅក្នុងវិស័យសាធារណៈជាចម្បង ដោយការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ដូចខាងក្រោម៖

- រៀបចំក្របខណ្ឌរួមស្ដីពីការលើកកម្ពស់អក្ខរកម្មឌីជីថលក្នុងចំណោមអ្នកដឹកនាំនិងមន្ត្រីនៅតាមក្រសួង-ស្ថាប័នរដ្ឋដែលរួមបញ្ចូលទាំងការបណ្ដុះបណ្ដាលជំនាញ និងការកសាងភាពជាអ្នកដឹកនាំឌីជីថល
- រៀបចំក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅតាមក្រសួង-ស្ថាប័នព្រមទាំងដាក់ចេញនូវយន្តការរួមក្នុងការលើកទឹកចិត្តអ្នកដឹកនាំ និងមន្ត្រីដែលមានគុណវុឌ្ឍិសមត្ថភាពនិងនវានុវត្តន៍ឌីជីថលខ្ពស់

[47] Pirun, Siriwat, & Darlin, *Developing Cambodia's Digital Economy: Youth's perspective (2021)*

- រៀបចំផែនការយុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរជាកំណាក់កាលលើនីតិវិធីរដ្ឋបាលនិងរបៀបវារៈនៃការគ្រប់គ្រង និងការចាត់ចែងការងារនៅតាមសក្រសួង-ស្ថាប័នដោយជំនួសឬបំពេញដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល
- រៀបចំផែនការរយៈពេលខ្លីនិងមធ្យមសម្រាប់ការជំរុញការចាប់យកនិងការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និងការចាត់ចែងការងារព្រមទាំងជម្រុញ និងការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថលក្នុងចំណោមអ្នកដឹកនាំ និងមន្ត្រីនៅតាមមូលដ្ឋាននិងសាធារណជន
- រៀបចំផែនការរយៈពេលខ្លី និងមធ្យមសម្រាប់ការជម្រុញការចាប់យកនិងការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និងការចាត់ចែងការងារ ព្រមទាំងលើកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថលនិងភាពជាអ្នកដឹកនាំឌីជីថលនៅក្នុងវិស័យឯកជន
- បង្កើនការផ្ទេរធនធាន និងកៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាក៏ដូចជាកិច្ចសហប្រតិបត្តិការនានាពីសំណាក់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនសម្រាប់ការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ។

### ៣.៦.២. វិធានការផ្នែកបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល

ការប្រមូលផ្តុំ និងការកសាងធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ជាចំណែកមួយទៀតនៃការគិតគូរក្នុងការអភិវឌ្ឍធនធានមនុស្សឌីជីថល ដែលនេះអាចសម្រចបានតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ដូចខាងក្រោម៖

- បង្កើត និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងជាតិស្តីពីតម្រូវការនិងការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញឌីជីថល ដោយធ្វើការសិក្សាជាទៀងទាត់ដើម្បីកំណត់អោយបានជាក់លាក់អំពីបរិមាណនិងប្រភពជំនាញឌីជីថលដែលមានតម្រូវការនៅក្នុងទីផ្សារបច្ចុប្បន្ន និងពេលអនាគត។
- កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការជម្រុញសិក្សា ការបណ្តុះបណ្តាល និងការកសាងជំនាញឌីជីថលនៅថ្នាក់ឧត្តមសិក្សា និងនៅគ្រប់កម្រិតបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងជំរុញការកែលម្អកម្មវិធីសិក្សា ដើម្បីបន្ថែគ្លាវរាងតម្រូវការជំនាញនិងការបណ្តុះបណ្តាល
- រៀបចំ និងអនុវត្តកម្មវិធី ឬកំនិតផ្តួចផ្តើមថ្នាក់ជាតិក្នុងការអភិវឌ្ឍនិងការបណ្តុះធនធានមនុស្សដែលមានទេពកោសល្យឌីជីថល រួមមានជាអាទិ៍ ការបង្កើតមូលនិធិថ្នាក់ជាតិសម្រាប់ផ្តល់អាហារូបករណ៍លើផ្នែកបច្ចេកវិទ្យាឌីជីថល ទាំងក្នុងប្រទេសនិងក្រៅប្រទេសដោយកៀរគរការធ្វើសហហិរញ្ញប្បទានពីវិស័យសាធារណៈ វិស័យឯកជន និងគ្រឹះស្ថានសិក្សាបណ្តុះបណ្តាល

- រៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញនិងការបណ្តុះគនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី (New Skill Requirement) នៅក្នុងវិស័យឯកជន
- រៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញនិងការបណ្តុះគំនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី (New Skill Requirement) នៅក្នុងវិស័យសាធារណៈ
- កសាងយុទ្ធសាស្រ្តលើកទឹកចិត្ត និងទាក់ទាញអ្នកមានទេពកោសល្យឌីជីថលពីក្រៅប្រទេស គួបផ្សំនឹងការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានា នៅក្នុងវីស័យឯកជន
- កសាងយុទ្ធសាស្រ្តលើកទឹកចិត្ត និងទាក់ទាញអ្នកមានទេពកោសល្យឌីជីថលពីក្រៅប្រទេស គួបផ្សំនឹងការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានា នៅក្នុងវិស័យសាធារណៈ
- រៀបចំយន្តការលើកទឹកចិត្ត គ្រាំទ្រ និងផ្តល់ភាពងាយស្រួលដល់វិស័យឯកជនក្នុងការផ្តល់វគ្គបណ្តុះបណ្តាលដល់កម្មករនិយោជិកលើជំនាញឌីជីថល ឬការផ្លាស់ប្តូរជំនាញទៅចាប់យកជំនាញឌីជីថល
- ជំរុញសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍ឌីជីថលនៅតាមបណ្តាសាលកវិទ្យាល័យគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ វិទ្យាស្ថាននិងមជ្ឈបណ្ឌលស្រាវជ្រាវនានាតាមរយៈការចងក្រងជាប្រព័ន្ធនូវបណ្តាស្ថាប័ន-គ្រឹះស្ថានស្រាវជ្រាវ
- កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជម្រុញ និងការអភិវឌ្ឍការងារស្រាវជ្រាវអភិវឌ្ឍន៍និងនវានុវត្តរួមជាអាទិ៍ ការរៀបចំអោយមានបណ្តុំមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តឌីជីថលដើម្បីជម្រុញការផ្លាស់ប្តូរទិន្នន័យ ព័ត៌មាននិងចំណេះដឹង គួបផ្សំនឹងការរៀបចំមូលនិធិថវិការគាំទ្រ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។

### ៣.៦.៣. វិធានការគោលនយោបាយផ្នែកពលរដ្ឋឌីជីថល

ការលើកកម្ពស់គុណភាពនៃការសិក្សារកម្រិតទូទៅជារួម និងការបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃប្រព័ន្ធអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ អាចសម្រេចទៅបានតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាល់ដូចខាងក្រោម៖

- កែលម្អប្រព័ន្ធកម្មវិធីសិក្សា ដោយដាក់បញ្ចូលការសិក្សាផ្នែកបច្ចេកវិទ្យាឌីជីថលជាមុខវិជ្ជាគោលមួយនៅគ្រប់កម្រិត ចាប់ពីថ្នាក់បឋមសិក្សាដល់មធ្យមសិក្សា និងបណ្តុះបណ្តាល់ជំនាញបច្ចេកទេសនិងវិជ្ជាជីវៈគ្រប់កម្រិត គួបផ្សំការគាំទ្រនិងការឧបត្ថម្ភដល់ក្រុមមនុស្សដែលមានតម្រូវការជាក់លាក់ និងក្រុមមនុស្សដែលងាយរងគ្រោះ

- កសាងផែនការវិនិយោគលើការបំពានសម្ភារបច្ចេកវិទ្យាឌីជីថល ការកសាងបន្ទប់ពិសោធឌីជីថល និងការតភ្ជាប់បណ្ដាញអគ្គីសនីនិងអ៊ីនធើណេតនៅតាមសាលារៀនរដ្ឋ និងគ្រឹះស្ថានបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ការសិក្សា និងការបណ្ដុះបណ្ដាលផ្នែកបច្ចេកវិទ្យាឌីជីថល
- រៀបចំកម្មវិធីលើកកម្ពស់គុណវុឌ្ឍិ និងអភិវឌ្ឍស្តង់ដាសមត្ថភាពឌីជីថលសម្រាប់គ្រូបង្រៀនគ្រប់កម្រិតថ្នាក់ សំដៅបង្កើនការអនុវត្តវិធីសាស្ត្របង្រៀនដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៅតាមគ្រប់គ្រឹះស្ថានសិក្សានិងបណ្ដុះបណ្ដាល
- រៀបចំផែនការផ្ដល់បត្តទេសក៍ជំនាញ និងអាជីពឌីជីថលនៅគ្រប់កម្រិតអប់រំនិងកម្រិតបណ្ដុះបណ្ដាលព្រមទាំងបញ្ជ្រាបការយល់ដឹង និងការបំពាក់បំប៉នចំណេះដឹងនិងជំនាញឌីជីថល សម្រាប់ការអប់រំក្រៅប្រព័ន្ធ ដើម្បីជំរុញការចាប់យកឌីជីថលប្រកបដោយបរិយាបន្នកម្ម
- ការរៀបចំយន្តការផ្សព្វផ្សាយរួមមានជាអាទិ៍ ការរៀបចំព្រឹត្តិការណ៍ជាតិ ឬយុទ្ធនាការជាតិដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចាប់យកឌីជីថល ដោយសហការជាមួយនឹងដៃគូអភិវឌ្ឍន៍អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន។

# ជំពូកទី៤

# ការវិភាគ និងបកស្រាយទិន្នន័យ

# ជំពូកទី៤
# ការវិភាគ និងបកស្រាយទិន្នន័យ

➢ **ការវិភាគតាមបែបពណ៌នា**

នៅក្នុងជំពូកនេះ យើងនឹងធ្វើការវិភាគទៅលើលទ្ធផលស្រាវស្រាវ ដែលបានមកពីការធ្វើកម្រងសំណួរ វាស់ស្ទង់មតិពីយុវជនខ្មែរចំនួន ៣៩០នាក់ ដែលក្នុងនោះមានស្ត្រីចូលរួមក្នុងការឆ្លើយចំនួន ២២៨រូប ដែលត្រូវនឹង ៥៨.៥ ភាគរយនៃអ្នកចូលរួមសរុបក្នុងការវាស់ស្ទង់មតិនេះ។

នៅក្នុងការវិភាគនេះ យើងនឹងផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចជា ស្ថានភាពទូទៅរបស់គាត់ ដែលរួមមាន ភេទ និង អាយុ ទីតាំងរស់នៅ កម្រិតនៃការអប់រំ និង ស្ថានភាពការងារ និងកម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស ។ បន្ទាប់ពីស្ថានភាពទូទៅ យើងនឹងធ្វើការវិភាគទៅលើកម្រិតនៃការយល់ដឹងរបស់យុវជនអំពីសេដ្ឋកិច្ចឌីជីថល ការប្រើប្រាស់បណ្តាញ ការចាប់យកឌីជីថល កម្រិតជំនាញនៃយុវជន និងការយល់ដឹងពីបញ្ហាប្រឈមនិងកត្តាជំរុញអោយមានការកើនឡើងពលរដ្ឋឌីជីថល ។ ទិន្នន័យទាំងនេះត្រូវបានយកមកវិភាគដោយប្រើប្រាស់កម្មវិធី Excel បង្កើតចេញជាក្រាហ្វិកផ្សេងៗដើម្បីធ្វើការបកស្រាយលទ្ធផលនៃទិន្នន័យដែលប្រមូលបានពីការស្ទង់មតិ។

➢ **វិធីសាស្ត្រជ្រើសរើសសំណាក និងចំនួននៃសំណាក**

ដោយសារតែពេលវេលានៃការស្រាវជ្រាវមានកំណត់ និងស្ថានភាពនៃបរិបទកូវីដ១៩ ធ្វើអោយមានភាពពិបាកនៅក្នុងការចុះសម្ភាសយុវជនផ្ទាល់ ការកំណត់យកចំនួនសំណាកសម្រាប់ការសិក្សានេះនឹងធ្វើឡើងតាមវិធីសាស្ត្រ “Convenience Sampling Method” ដែលអាចទទួលបានការឆ្លើយតបបានរហ័សដោយយើងបានធ្វើការផ្ញើតំណភ្ជាប់នៃការវាស់ស្ទង់មតិដែលបង្កើតដោយប្រើប្រាស់កម្មវិធី Google Form ទៅកាន់យុវជនដែលសិក្សានៅវិទ្យាល័យ សាកលវិទ្យាល័យ និងស្ថាប័នផ្សេងៗគ្នា តាមរយៈប្រព័ន្ធបណ្តាញសង្គមដូចជា Facebook ឬ Telegram ជាដើម។ ។

សំណាកដែលត្រូវបានជ្រើសរើសយកមកនេះមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១. ត្រូវមានអាយុចន្លោះពី ១៥ ទៅ ៣៥ ឆ្នាំ

២. ត្រូវមានកម្រិតអប់រំចាប់ពីកម្រិតថ្នាក់វិទ្យាល័យ ដល់ថ្នាក់អនុបណ្ឌិតនៅក្នុងប្រទេសកម្ពុជា

៣. មានកម្រិតភាសាអង់គ្លេសចាប់ពី Elementary ដល់ Proficient

➢ **វិធីសាស្ត្រប្រមូលទិន្នន័យ**

វិធីសាស្រ្តក្នុងការប្រមូលទិន្នន័យមានសារៈសំខាន់បំផុតក្នុងការឆ្លុះបញ្ចាំង និងឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ ដូចនេះទិន្នន័យដែលបានយកមកសិក្សាត្រូវពឹងផ្អែកលើវិធីសាស្រ្ត ២ យ៉ាងសំខាន់ គឺ វិធីសាស្រ្តប្រមូលទិន្នន័យបន្ទាប់បន្សំ និងវិធីសាស្រ្តប្រមូលទិន្នន័យចម្បង។

- ទិន្នន័យបន្ទាប់បន្សំ ជាទិន្នន័យដែលបានមកពីការសិក្សានូវអ្វីដែលគេបានចងក្រងកន្លងមក ដែលមានការជាប់ទាក់ទងទៅនឹងប្រធានបទនៃការសិក្សា។ ដើម្បីទទួលបានទិន្នន័យប្រភេទនេះ ចាំបាច់ត្រូវការស្រាវជ្រាវលើឯកសារនិងរបាយការណ៍ផ្សេងៗដែលពាក់ព័ន្ធដែលភាគច្រើនត្រូវបានដកស្រង់ចេញតាមប្រព័ន្ធអ៊ីនធើណេតពីគេហទំព័រនៃស្ថាប័ន និងក្រសួងនានាដែលពាក់ព័ន្ធនឹងប្រធានបទ។
- ទិន្នន័យចម្បងជាទិន្នន័យដែលបានមកពីការប្រមូលព័ត៌មានតាមការវាស់ស្ទង់មតិតាមប្រព័ន្ធអនឡាញដោយការប្រើប្រាស់កម្មវិធី Google Form ។ នៅក្នុងការស្ទង់មតិនេះ មានការចូលរួមពីសំណាកដែលជាយុវជនចំនួន ៣៩០ នាក់។

## ៤.១. ស្ថានភាពទូទៅនៃយុវជនដែលចូលរួមការស្ទង់មតិ

សំណាកដែលត្រូវបានស្ទង់មតិក្នុងការសិក្សានេះមានលក្ខណៈប្រជាសាស្រ្តសេដ្ឋកិច្ច និងសង្គមដូចតទៅ៖

### ៤.១.១. ភេទ និងអាយុ

តាមលទ្ធផលស្ទង់មតិបានបង្ហាញថាយុវជនដែលបានចូលរួមក្នុងការស្ទង់មតិទាំងអស់មានចំនួន៣៩០ នាក់ ដែលក្នុងនោះមានស្រ្តីចំនួន ២២៨ នាក់ ដែលត្រូវនឹង ៥៨ ភាគរយ។ ភាគច្រើននៃអ្នកចូលរួមមានអាយុចន្លោះ ១៨ ទៅ ២២ ឆ្នាំ ដែលមានរហូតដល់ ៦៣ ភាគរយនៃចំនួនអ្នកចូលរួមសរុប។

ក្រាហ្វិកទី ៥៖ ភេទនៃអ្នកចូលរួមក្នុងការស្ទង់មតិ




ប្រភព៖ ទិន្នន័យវិភាគ

### ៤.១.២. ទីតាំងរស់នៅ

យោងទៅតាមការវិភាគទិន្នន័យបានបង្ហាញថា ជាងពាក់កណ្ដាលនៃអ្នកចូលរួមក្នុងការស្ទង់មតិនេះ រស់នៅទីក្រុងភ្នំពេញ ដែលស្មើនឹង ៥២% (២០៤ នាក់) ហើយចំណែកអ្នកដែលរស់នៅខេត្តក្រុងដែលស្ថិតនៅក្នុងចំណោមទីប្រជុំជន ឬទីរួមខេត្តមាន ៣០% (១១៨ នាក់)។ ចំពោះអ្នកដែលរស់នៅជនបទ ឬតំបន់ដាច់ស្រយាល មានត្រឹមតែ ១៨% តែប៉ុណ្ណោះ។

ក្រាហ្វិកទី ៦៖ ទីតាំងរស់នៅនៃអ្នកចូលរួមក្នុងការស្ទង់មតិ




ប្រភព៖ ទិន្នន័យវិភាគ

### ៤.១.៣. កម្រិតនៃការអប់រំ និងស្ថានភាពការងារ

ភាគច្រើននៃអ្នកចូលរួមក្នុងការសិក្សានេះមានការអប់រំកម្រិតថ្នាក់បរិញ្ញាបត្រដែលមានរហូតទៅដល់ ៧៤% (២៩០ នាក់) នៃអ្នកចូលរួមក្នុងការស្ទង់មតិសរុប ។

ក្រាហ្វិកទី ៧៖ កម្រិតនៃការអប់រំ




ប្រភព៖ ទិន្នន័យវិភាគ

លើសពីនេះទៅទៀត អ្នកចូលរួមស្ទង់មតិទាំងអស់ត្រូវបានសួរនាំពីស្ថានភាពការងារ ដែលក្នុងចំណោម ៣៩០ នាក់ មានចំនួន ៥៩ % (២៣១នាក់) ជាអ្នកដែលមិនទាន់ធ្វើការនៅឡើយ ។ នៅក្នុងចំណោមអ្នកធ្វើការ មាន ២៥ % ជាអ្នកដែលកំពុងធ្វើការនៅក្នុងវិស័យឯកជន ៩% ធ្វើការក្នុងវិស័យរដ្ឋ ។ សម្រាប់អ្នកធ្វើការប្រកបអាជីវកម្មផ្ទាល់ខ្លួន មានត្រឹមតែ ៤% ហើយអ្នកធ្វើការឯករាជ្យ មានត្រឹម ៣% ដែលបានឆ្លុះបញ្ចាំងអោយឃើញថា ភាគច្រើននៃយុវជន មានចំនួនតិចខ្លាំងមែនទែនដែលធ្វើការបែបឯករាជ្យ(Freelancer) ។

ក្រាហ្វិកទី៨៖ ស្ថានភាពការងារ




ប្រភព៖ ទិន្នន័យវិភាគ

### ៤.១.៤. កម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស

កម្រិតនៃការអាចប្រើប្រាស់ភាសាអង់គ្លេសបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការចាប់យកឌីជីថល ពីព្រោះថាឧបករណ៍ឌីជីថលភាគច្រើនត្រូវបានបង្កើតឡើងដោយប្រើប្រាស់ភាសាអង់គ្លេសជាចម្បង ដែលជាហេតុកាលណាដែលយើងមានកម្រិតភាសាអង់គ្លេសល្អ ធ្វើអោយយើងអាចងាយស្រួលមានការយល់ដឹងទៅលើការប្រើប្រាស់ឧបករណ៍ឌីជីថល និងសេវាកម្មឌីជីថលផ្សេងៗ។ នៅក្នុងការស្ទង់មតិ យើងបានធ្វើការសួរសំណួរដើម្បីស្វែងយល់ពីកម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេសរបស់យុវជនផងដែរ។

នៅក្នុងចំណោមអ្នកចូលរួមការស្ទង់មតិចំនួន៣៩០នាក់ អ្នកដែលមានកម្រិតភាសាអង់គ្លេសProficient គឺមានចំនួនតិចនៅឡើយ បើប្រៀបធៀបទៅនឹងកម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស ៣កម្រិតផ្សេងទៀត។ ការប្រើប្រាស់ភាសាអង់គ្លេសត្រូវបានបែងចែកជា ៤ ផ្នែកដែលក្នុងនោះមាន ការអាន ការស្តាប់ ការនិយាយ និងការសរសេរ។ ភាគច្រើននៃអ្នកចូលរួមមានកម្រិតការអាន Upper Intermediate, ការស្តាប់ ការនិយាយ និងការសរសេរមានកម្រិត Lower Intermediate។

ក្រាហ្វិកទី ៩៖ កម្រិតនៃការប្រើប្រាស់ភាសាអង់គ្លេស




ប្រភព៖ វិភាគទិន្នន័យ

## ៤.២. ការយល់ដឹងពីសេដ្ឋកិច្ចឌីជីថល

តាមរយៈការស្ទួរសំណួរទាក់ទងជាមួយនឹងសេដ្ឋកិច្ចឌីជីថល បានបង្ហាញអោយឃើញថា ជាសរុបមានរហូតដល់ ៨៥ % នៃចំនួនអ្នកស្ទង់មតិបានឆ្លើយថាពួកគេធ្លាប់បានលឺពាក្យថា សេដ្ឋកិច្ចឌីជីថល និង ១៥% មិនធ្លាប់បានលឺពីមុនមកសោះតែម្តង។ ក៏ប៉ុន្តែ ក្នុងចំណោម ៣៩០ នាក់ មានតែ ៨% តែប៉ុណ្ណោះដែលធ្លាប់លឺ យល់ និងអនុវត្តជាក់ស្តែង និង ២៧ % ធ្លាប់បានលឺ និងយល់ពីនិយមន័យនៃពាក្យសេដ្ឋកិច្ចឌីជីថល ។ អ្វីដែលកត់សម្គាល់នោះគឺ មានរហូតដល់ ៥០% នៃអ្នកចូលរួមបានត្រឹមតែលឺពាក្យសេដ្ឋកិច្ចឌីជីថល តែមិនបានយល់ថាអ្វីទៅដែលហៅថាសេដ្ឋកិច្ចឌីជិថលនោះឡើយ។

ក្រាហ្វិកទី ១០៖ កម្រិតនៃការយល់ដឹងពីសេដ្ឋកិច្ចឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

ក្រោយមកទៀតយើងក៏បានសាកសួរពីមូលហេតុដែលគាត់ជ្រើសរើសនូវចម្លើយខាងលើ ហើយភាគច្រើនអ្នកដែលនិយាយថា ធ្លាប់លឺ និងយល់ពីនិយមន័យ និងអ្នកដែលថាធ្លាប់លឺ យល់និងអនុវត្តប្រចាំថ្ងៃជាក់ស្តែងនោះ គឺដោយសារតែពួកគាត់បានឆ្លងកាត់ការស្រាវជ្រាវដោយខ្លួនឯង ធ្លាប់រៀនមុខវិជ្ជាសេដ្ឋកិច្ចឌីជីថលពីមុនមកចូលរួមសិក្ខាសាលា និងបានដឹងពីមាតិកាដែលបានផ្សព្វផ្សាយក្នុងបណ្តាញសង្គមទាក់ទងនឹងសេដ្ឋកិច្ចឌីជីថល។ អ្វីដែលគួរអោយកត់សម្គាល់នោះ ក្នុងចំណោមយុវជន២៩០នាក់ មានតែ ១០% តែប៉ុណ្ណោះដែលធ្លាប់បានសិក្សាមុខវិជ្ជាសេដ្ឋកិច្ចឌីជីថលពីសាលារៀនរបស់ខ្លួន ហើយភាគច្រើនពួកគេបានដឹងតាមរយៈការស្រាវជ្រាវដោយខ្លួនឯងដែលមានប្រមាណ ៤៧.៧% នៃអ្នកស្ទង់មតិសរុប។

ចំណែកអ្នកដែលជ្រើសរើសថា គាត់ធ្លាប់លឺ ក៏ប៉ុន្តែមិនយល់ពីនិយមន័យសេដ្ឋកិច្ចឌីជីថលនោះ ដោយសារតែបានត្រឹមតែលឺគេនិយាយនៅក្នុងបណ្តាញសង្គម អ្នកព័ត៌មាន និងសិស្សច្បងបានលើកឡើងពីពាក្យនេះ តែគាត់មិនធ្លាប់បានស្រាវជ្រាវពីសេដ្ឋកិច្ចឌីជីថលដោយខ្លួនឯងបន្ថែម និងមិនសូវប្រើប្រាស់កម្មវិធីឌីជីថលច្រើន។ ចំណែកអ្នកដែលនិយាយថាគាត់មិនធ្លាប់លឺពាក្យសេដ្ឋកិច្ចឌីជីថល បានឆ្លើយថាដោយសារតែ គាត់មិនសូវប្រើប្រាស់កម្មវិធីឌីជីថល និងមិនបានស្រាវជ្រាវអំពីសេដ្ឋកិច្ចឌីជីថល។

## ៤.៣. ការប្រើប្រាស់បណ្តាញ

### ៤.៣.១. ប្រភេទបណ្តាញដែលប្រើប្រាស់

តាមរយៈការស្ទង់មតិបានបង្ហាញអោយឃើញថា ភាគច្រើននៃយុវជនកម្ពុជា និយមប្រើប្រាស់ទាំង Wifi និងអ៊ីនធើណេតទូរស័ព្ទដៃ ដែលមានរហូតដល់ ៧២ % នៃអ្នកស្ទង់មតិសរុប។ មានត្រឹមតែ ២៤% តែប៉ុណ្ណោះដែលប្រើតែអ៊ីនធើណេតទូរស័ព្ទតែមួយមុខដោយមិនមានប្រើ Wifi និង ៤% ជាអ្នកដែលប្រើប្រាស់តែ Wifi សុទ្ធដោយមិនប្រើអ៊ីនធើណេត។

ក្រាហ្វិកទី ១១៖ ប្រភេទបណ្តាញតភ្ជាប់ដែលនិយមប្រើប្រាស់




ប្រភព៖ ទិន្នន័យវិភាគ

នៅក្នុងចំណោមអ្នកដែលប្រើប្រាស់ទាំងអ៊ីនធើណេតទូរស័ព្ទ និង wifi ចំនួន ២៨២ នាក់ (៧២%) មានអ្នកដែលប្រើប្រាស់ wifi ច្រើនជាង Internet ចំនួន ៧៣ នាក់ អ្នកដែលប្រើប្រាស់ Internet ច្រើនជាង Wifi ចំនួន ៥៨ នាក់ និង ១៥១ នាក់ប្រើWifi និងអ៊ីនធើណេតទូរស័ព្ទប្រហាក់ប្រហែលគ្នា។

តាមរយៈទិន្នន័យនេះបានបង្ហាញអោយឃើញថាភាគច្រើនគេនិយមប្រើប្រាស់ទាំង Wifi និងអ៊ីនធើណេតទូរស័ព្ទ ដោយសារតែនៅពេលដែលចេញទៅក្រៅពីផ្ទះរបស់ខ្លួនដែលមានភ្ជាប់ Wifi វាពិបាកនៅក្នុងការប្រើប្រាស់ Wifi របស់អ្នកដទៃ ជាក់ស្តែងដើម្បីប្រើប្រាស់ Wifi នៅហាងកាហ្វេ យើងត្រូវតែជាវកាហ្វេនៅហាងគេជាមុនសិនទើបអាចទទួលបានលេខសម្ងាត់ Wifi ។ ដូចនេះហើយ ដើម្បីសម្រួលនៅពេលដែលយើងចេញក្រៅម្តងៗ ដោយមិនចាំបាច់ប្រើ Wifi គេ និងមិនពិបាកចំណាយច្រើនជាមួយនឹងអ្វីដែលមិនចាំបាច់ដើម្បីប្រើប្រាស់ Wifi របស់ហាងណាមួយ គេប្រើទាំង Internet ដើម្បីជំនួសម្តងម្កាលនៅពេលគ្មាន Wifi ជាមួយនឹងខ្លួន។

### ៤.៣.២. កម្រិតល្បឿននៃបណ្តាញ

នៅក្នុងចំណោមអ្នកដែលបានស្ទង់មតិមានរហូតដល់ ៤៦%នៃអ្នកស្ទង់មតិសរុប បានឆ្លើយតបថា ល្បឿននៃបណ្តាញនៅទីតាំងរបស់ខ្លួនមានល្បឿនលឿន ចំណែកឯ ២២% ទៀតបាននិយាយថា យូរៗមានជួបបញ្ហាដាច់ម្តង ។ ទិន្នន័យនេះបានបង្ហាញអោយឃើញថា កម្រិតនៃល្បឿនក្នុងពេលបច្ចុប្បន្ននេះ មានកម្រិតមួយគួរសមអាចទទួលបានសម្រាប់ប្រើប្រាស់។

ក្រាហ្វិកទី ១២៖ កម្រិតល្បឿននៃបណ្តាញតភ្ជាប់




ប្រភព៖ ទិន្នន័យវិភាគ

នៅក្នុងចំណោមអ្នកស្ទង់មតិទាំងអស់មានតែអ្នកដែលនៅភ្នំពេញប៉ុណ្ណោះដែលជ្រើសរើសថាបណ្តាញតភ្ជាប់របស់ខ្លួនមានល្បឿន លឿនណាស់។ ផ្ទុយទៅវិញ នៅក្នុងជនបទឬតំបន់ដាច់ស្រយាលជាទីកន្លែងដែលមានបណ្តាញតភ្ជាប់ឧស្សាហ៍ដាច់ជាងគេដែលជាផលរំខានទៅលើការប្រើប្រាស់កម្មវិធីឌីជីថលផ្សេងៗមិនបាន

ទាន់ចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ថ្វីត្បិតតែមានតំបន់មួយចំនួនមានបញ្ហាបណ្តាញតភ្ជាប់យឺត និងយូរៗដាច់ម្តងក៏ពិតមែន កម្រិតនៃអ្នកដែលជ្រើសរើសថា យឺតណាស់ មានចំនួនតិចជាងគេបើប្រៀបធៀបទៅនឹងកម្រិតនៃល្បឿនផ្សេងៗទៀត។

ក្រាហ្វិកទី ១៣៖ កម្រិតល្បឿននៃបណ្តាញតភ្ជាប់ និងតំបន់




ប្រភព៖ ទិន្នន័យវិភាគ

### ៤.៣.៣. កម្រិតនៃការពេញចិត្តល្បឿននិងតម្លៃនៃបណ្តាញតភ្ជាប់

ថ្វីត្បិតតែល្បឿននៃបណ្តាញតភ្ជាប់មានល្បឿនមួយដែលអាចទទួលយកបានក៏ពិតមែនក្នុងចំណោមយុវជនភាគច្រើនមិនថានៅភ្នំពេញ ទីប្រជុំជន ឬ តំបន់ដាច់ស្រយាល បានបង្ហាញនូវកម្រិតនៃការពេញចិត្តរបស់ខ្លួនថាទំនាក់ទំនងនៃតម្លៃនិងគុណភាពហាក់មានភាពមិនទាន់ស៊ីចង្វាក់គ្នានៅឡើយ។ តាមទិន្នន័យដែលប្រមូលបានពីការស្ទង់មតិបានបង្ហាញអោយឃើញថា ៤៦ % នៃអ្នកស្ទង់មតិបានវាយតម្លៃថា ថ្លៃនៅមិនទាន់សាកសមនឹងគុណភាពនៅឡើយ ។ នៅក្នុងនោះផងដែរ មានត្រឹមតែ ៣៦ ភាគរយតែប៉ុណ្ណោះដែលបាននិយាយថា ថ្លៃសាកសមនឹងគុណភាព។

ក្រាហ្វិកទី ១៤៖ កម្រិតនៃការពេញចិត្តល្បឿននិងតម្លៃនៃបណ្តាញតភ្ជាប់




ប្រភព៖ ទិន្នន័យវិភាគ

#### ៤.៣.៤. រយៈពេលនៃការប្រើប្រាស់បណ្តាញអ៊ីនធើណេត

នៅក្នុងការស្ទង់មតិបានធ្វើការសាកសួរពីរយៈពេលដែលប្រើប្រាស់អ៊ីនធើណេតប្រចាំថ្ងៃនៃយុវជន ហើយលទ្ធផលដែលយើងទទួលបានគឺ យុវជន ៦៦% មានការប្រើប្រាស់អ៊ីនធើណេតលើសពី ៦ម៉ោងក្នុងមួយថ្ងៃ ដែលភាគច្រើនជានិស្សិតដែលកំពុងសិក្សាបរិញ្ញាបត្រ និងមិនទាន់មានការងារធ្វើនៅឡើយ។ នៅក្នុងនោះមានតែ ៣% តែប៉ុណ្ណោះដែលប្រើតិចជាង ២ ម៉ោង។

តាមទិន្នន័យនេះ បង្ហាញអោយយល់បានថា ដោយសារតែការប្រមូលទិន្នន័យនេះត្រូវបានធ្វើឡើងក្នុងកំឡុងពេលដែលមានស្ថានភាពកូវីដ១៩ ដូចនេះយុវជនភាគច្រើនត្រូវការប្រើប្រាស់បណ្តាញអ៊ីនធើណេតច្រើនដើម្បីបំពេញតម្រូវការសំខាន់ៗរបស់ខ្លួនជាពិសេសការសិក្សាតាមបណ្តាអនឡាញ សម្រាប់អ្នកដែលធ្វើការវិញភាគច្រើនត្រូវប្តូរមកជាការប្រើប្រាស់បណ្តាញអ៊ីនធើណេត ដោយសារតែមានការផ្លាស់ប្តូររបៀបនៃការធ្វើការខុសពីពេលមុនៗ ដែលសហគ្រាសតម្រូវអោយមានការប្រើប្រាស់បច្ចេកវិទ្យាអោយបានកាន់តែស៊ីជម្រៅជាងមុន។

ក្រាហ្វិកទី ១៥៖ រយៈពេលនៃការប្រើប្រាស់បណ្តាញអ៊ីនធើណេត




ប្រភព៖ ទិន្នន័យវិភាគ

### ៤.៤. ការចាប់យកឌីជីថល

#### ៤.៤.១. ឧបករណ៍ឌីជីថល

នៅក្នុងការស្ទង់មតិយើងបានដាក់ជាជម្រើសឧបករណ៍ឌីជីថលដែលសំខាន់ៗនៅក្នុងការចាប់យកឌីជីថល មានដូចជា កាតធនាគារ គណនីធនាគារ កុំព្យូទ័រ Desktop, Tablet, Laptop, និងទូរស័ព្ទ Smart phone សម្រាប់យុវជនក្នុងការជ្រើសរើស។ ក្នុងលទ្ធផលបានបង្ហាញអោយឃើញថា ឧបករណ៍ឌីជីថល៣ ដែលភាគច្រើនយុវជនមានការនិយមប្រើប្រាស់ ទូរស័ព្ទ Smart phone, Laptop, និងគណនីធនាគារ។

នៅក្នុងចំណោមយុវជន ៣៩០រូប មានយុវជនចំនួន ៣៨៣ រូប ដែលមានទូរស័ព្ទ (Smart phone) ។ តាមរយៈទិន្នន័យនេះ បានបង្ហាញអោយឃើញថា យុវជនភាគច្រើនអាចមានការយល់ដឹងពីការប្រើប្រាស់ទូរស័ព្ទ

ដៃដែលមានមុខងារជាច្រើនក្នុងការចូលទៅកាន់សេវាកម្មផ្សេងៗមិនថាការសិក្សា ការកម្សាន្ត ការទិញទំនិញ ដោយកម្មវិធីឌីជីថល និងផ្សេងៗជាដើម។ បន្ថែមពីនេះទៅទៀត ក្នុងចំណោម ៣៩០រូប មាន ២៩៣ រូបមាន Laptop ដែលបង្ហាញថាភាគច្រើនពួកគាត់មានប្រើប្រាស់ Laptop ដែលអាចចូលទៅប្រើប្រាស់កម្មវិធីផ្សេងៗជាច្រើនលើសពីទូរស័ព្ទដៃមានហើយវាមានភាពងាយស្រួលយកតាមខ្លួន មិនថាទៅទីណាក៏ដោយ ដូចនេះទើបពួកគេនិយមប្រើប្រាស់វាជាង។ នៅក្នុងចំណោមយុវជន ៣៩០រូប មានយុវជនរហូតដល់ ២១៤រូបដែលមានប្រើប្រាស់គណនីធនាគារ។ ការនិយមប្រើប្រាស់គណនីធនាគារបានឆ្លុះបញ្ចាំងអោយឃើញទៀតថាយុវជនកម្ពុជាភាគច្រើនកាន់តែមានការយល់ដឹងពីបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសម្របខ្លួនក្នុងការប្រើប្រាស់ក្នុងការទូទាត់បែបសម័យថ្មី ដែលនឹងមានសារៈសំខាន់នៅក្នុងការបណ្តុះទម្លាប់នេះនាពេលខាងមុខទៀត។

ក្រាហ្វិកទី ១៦៖ ឧបករណ៍ឌីជីថលដែលយុវជនប្រើប្រាស់




ប្រភព៖ ទិន្នន័យវិភាគ

### ៤.៤.២. ការប្រើប្រាស់សេវាកម្មបែបឌីជីថល

យើងបានធ្វើការសាកសួរទៅកាន់យុវជនអំពីការប្រើប្រាស់សេវាកម្មឌីជីថលផ្សេងៗ នៅក្នុងការរស់នៅប្រចាំថ្ងៃ ដែលក្នុងនោះ កម្មវិធីដែលមានការប្រើប្រាស់ច្រើនបំផុតក្នុងចំណោមកម្មវិធីឌីជីថលទាំងអស់មានដូចជាការអប់រំតាមអនឡាញ ការទិញទំនិញអនឡាញ និងការទូទាត់ឬការផ្ទេរប្រាក់បែបឌីជីថល។ តាមរយៈទិន្នន័យនេះបានបង្ហាញអោយឃើញថា យុវជនកម្ពុជាបានផ្លាស់ប្តូរទម្លាប់នៅក្នុងការរស់នៅ មិនថាការសិក្សា ការទូទាត់ប្រាក់ ឬការទិញទំនិញនោះឡើយ ពីបែបការសិក្សានៅក្នុងថ្នាក់រៀនតែមួយមុខ មកជាការសិក្សាតាមប្រព័ន្ធឌីជីថល ដែលមានសារៈសំខាន់នៅក្នុងសតវត្សទី២១ នៅក្នុងការសម្របខ្លួនជាមួយនឹងការអប់រំឌីជីថល ចំណែក

ឯការទូទាត់ប្រាក់វិញ ដោយសារតែបរិបទកូវីដ១៩ បានធ្វើអោយយុវជនភាគច្រើនមានការពេញនិយមក្នុងការទូទាត់ដោយមិនប្រើក្រដាសប្រាក់ ដោយបែរមកជាការទូទាត់ដោយការផ្ទេរប្រាក់ពីគណនីធនាគារ ឬ ការស្កេន QR ដែលមានភាពងាយស្រួល និងរហ័សទាន់ចិត្តទាំងអ្នកលក់ និងអ្នកទិញ។ ជាពិសេស ការទិញទំនិញតាមប្រព័ន្ធអនឡាញទទួលបានការពេញនិយមច្រើនក្នុងចំណោមយុវជន ដោយសារតែវាធ្វើអោយគេកាន់តែចំណេញពេលវេលាជាងមុន ដោយមិនចាំបាច់ត្រូវចំណាយពេលវេលាធ្វើដំណើរស្មុះផ្លូវទៅកាន់ទីតាំងហាងផ្ទាល់ដូចមុនទើបបានទំនិញទេ គឺគេអាចធ្វើការទិញទំនិញបានត្រឹមតែមានទូរស័ព្ទមួយនៅក្នុងដៃដោយប្រើប្រាស់កម្មវិធីឌីជីថល ឬកម្មវិធីបណ្ដាញសង្គមដូចជា Facebook, Instagram ជាដើម។

អ្វីដែលគួរអោយកត់សម្គាល់នោះគឺ ក្នុងចំណោមការចាប់យកឌីជីថល ការប្រកបការងារតាមអនឡាញហាក់មានកម្រិតមួយដែលទាបបើធៀបជាមួយនឹងសេវាកម្មឌីជីថលដទៃទៀត ពោលគឺមានត្រឹមតែ ៣៤%តែប៉ុណ្ណោះក្នុងចំណោម ៣៩០ នាក់។ ក៏ប៉ុន្តែទៅថ្ងៃខាងមុខ អាចនឹងមានការកើនឡើងនូវអ្នកដែលធ្វើការតាមប្រព័ន្ធអនឡាញ ដោយសារតែការសម្របខ្លួនជាមួយនឹងការអប់រំតាមប្រព័ន្ធអនឡាញ យូរៗទៅអាចនឹងបណ្ដុះទម្លាប់ដែលធ្វើការពីចម្ងាយបាន ដោយមិនចាំបាច់ទៅការិយាល័យ។ ជាពិសេសក្នុងពេលបច្ចុប្បន្នមានកន្លែងធ្វើការជាច្រើនដែលបានអោយបុគ្គលិកធ្វើការពីចម្ងាយ ដែលជាចំណុចមួយដែលចាប់ផ្ដើមបង្វែរឥរិយាបទនៅក្នុងការធ្វើការងារសម័យទំនើបនេះ។

កម្មវិធីសម្រាប់កក់យានជំនិះទទួលបានចំណាប់អារម្មណ៍តិចនៅក្នុងការប្រើប្រាស់ ដោយសារតែភាគច្រើនយុវជនកម្ពុជាមានយានជំនិះរបស់ខ្លួនរួចទៅហើយដូចជា ម៉ូតូ ឡាន ហើយភាគច្រើនគេតែងតែប្រើប្រាស់យានជំនិះរបស់ខ្លួនមិនថាធ្វើដំណើរទៅកាន់សាលារៀន កន្លែងធ្វើការ ឬ ហាងកាហ្វេក្ដី។ ភាគច្រើននៃយុវជនប្រើប្រាស់កម្មវិធីកក់យានជំនិះម្ដងម្កាលតែប៉ុណ្ណោះនៅពេលណាដែលចាំបាច់មិនអាចប្រើប្រាស់យានជំនិះរបស់ខ្លួនបាន ឬ មិនចេះបើកបរដោយខ្លួនឯងជាដើម។

ក្រាហ្វិកទី ១៧៖ ការប្រើប្រាស់សេវាកម្មបែបឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

លើសពីនេះទៅទៀត យើងបានធ្វើការសួរពីកម្រិតនៃការប្រើប្រាស់របស់អ្នកស្ទង់មតិ ថាតើជាធម្មតា គេប្រើកម្មវិធីឌីជីថលទាំងនោះញឹកញាប់កម្រិតណា។ នៅក្នុងនោះផងដែរ កម្មវិធីឌីជីថលដែលមានកម្រិតខ្ពស់ជាងគេនៅក្នុងការប្រើប្រាស់យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ គឺការប្រើប្រាស់ក្នុងគោលបំណងទាក់ទងនឹងការអប់រំតាមប្រព័ន្ធអនឡាញ បន្ទាប់មកទៀតគឺការប្រើប្រាស់កម្មវិធីកម្សាន្ត។ ភាគច្រើននៃអ្នកចូលរួមក្នុងការស្ទង់មតិនេះ ភាគច្រើនមិនធ្លាប់បានធ្វើការស្វែងរកការងារធ្វើតាមប្រព័ន្ធអនឡាញ(Freelance)សោះដែលបានឆ្លុះបញ្ចាំងអោយឃើញថាការធ្វើការងារបែបឯករាជ្យហាក់មិនសូវមានការពេញនិយមក្នុងចំណោមយុវជននៅឡើយ។

ថ្វីត្បិតតែទិន្នន័យខាងលើបានបញ្ជាក់ថា ភាគច្រើនយុវជនធ្លាប់បានធ្វើការទិញទំនិញតាមប្រព័ន្ធអនឡាញក៏ពិតមែន ក៏ប៉ុន្តែភាគច្រើនគេទិញនៅក្នុងរយៈពេលយ៉ាងហោចមួយខែម្តងតែប៉ុណ្ណោះ។ ចំណែកឯការប្រើសម្រាប់កក់យានជំនិះវិញបានបង្ហាញអោយឃើញថាភាគច្រើនសម្បូរអ្នកដែលកម្រប្រើប្រាស់ណាស់ ដោយសារតែភាគច្រើនគេប្រើយានជំនិះផ្ទាល់ខ្លួនរបស់គេផ្ទាល់តែម្តង។

អ្វីដែលគួរអោយកត់សម្គាល់នោះ ភាគច្រើននៃយុវជនកម្ពុជាដែលបានចូលរួមក្នុងការស្ទង់មតិនេះ មានការទូទាត់បែបឌីជីថល យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ដែលបានឆ្លុះបញ្ចាំងពីកម្រិតនៃការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុកាន់តែមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ថ្វីត្បិតតែសង្គមបច្ចុប្បន្នសម្បូរអ្នកដែលប្រើប្រាស់កម្មវិធីឌីជីថលក្នុងការទិញអាហារក៏ពិតមែន ក៏កម្រិតនៃភាពញឹកញាប់នៃការប្រើប្រាស់សម្រាប់សេវាកម្មដឹកអាហារតាមរយៈ Foodpanda ឬ Nham24 ហាក់នៅមាន

កម្រិតមួយដែលមានមនុស្សជាច្រើនមិនធ្លាប់បានប្រើនៅឡើយ ដោយសារតែយុវជនកម្ពុជាភាគច្រើននៅជាមួយនឹងក្រុមគ្រួសារនិងចម្អិនអាហារដោយខ្លួនឯង ហើយកម្មង់អាហារតាមអនឡាញម្តងម្កាល។

ក្រាហ្វិកទី ១៨៖ កម្រិតនៃការប្រើប្រាស់សេវាកម្មបែបឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

បញ្ហាប្រឈមជាឧបសគ្គមួយដែលរាំងដល់ការសម្រេចចិត្តនៅក្នុងការប្រើប្រាស់កម្មវិធី ឬសេវាកម្មឌីជីថល។ នៅក្នុងការវាស់ស្ទង់មតិនេះ បានបង្ហាញអោយឃើញថា បញ្ហាប្រឈមដែលធំបំផុតសម្រាប់យុវជនក្នុងការប្រើប្រាស់កម្មវិធីឌីជីថល គឺសេវាអ៊ីនធើណេតដែលមានកម្រិតល្បឿនយឺតម្តងៗ។ បញ្ហាប្រឈមចម្បងទី២នោះគឺការយល់ដឹងពីរបៀបនៃការប្រើប្រាស់ឧបករណ៍ឌីជីថលនៅមានកម្រិត និងទី ៣ គឺការមិនទុកចិត្តនឹងសេវាកម្មតាមអនឡាញ។ នៅពេលដែលល្បឿននៃបណ្តាញតភ្ជាប់មានកម្រិតយឺត វាបានធ្វើអោយមានបញ្ហាជាច្រើនដូចជាការមានភាពយឺតយ៉ាវ ការមិនទទួលបានសេវាពេញលេញនិងរហ័សទាន់ចិត្ត។ ជាពិសេសនៅពេលដែលការយល់ដឹងនៅមានកម្រិត វាបណ្តាលអោយយុវជនមានភាពអរមិនសូវហ៊ានប្រើប្រាស់ដោយសារខ្លាចថាមានបញ្ហាផ្សេងៗនឹងកើតមានឡើងដោយសារកំហុសរបស់ខ្លួន។ ការទុកចិត្តនឹងសេវាកម្មតាមអនឡាញមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការផ្តល់ភាពជឿជាក់លើយុវជនក្នុងការប្រើប្រាស់ ដូចនេះ នៅពេលដែលមានការមិន

ទុកចិត្ត នោះវាធ្វើអោយយុវជនមានភាពមិនសូវធ្វើប្រតិបត្តិការតាមអនឡាញនោះទេ ដោយសារតែខ្លាចមានបញ្ហាឆបោក ឬ គុណភាពនៅខាងក្រៅ និងគុណភាពនៅក្នុងអនឡាញមិនដូចគ្នា។

ក្រាហ្វិកទី ១៩៖ បញ្ហាប្រឈមនៃការប្រើប្រាស់សេវាកម្មឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

## ៤.៥. កម្រិតជំនាញនៃយុវជន

កម្រិតនៃជំនាញប្រៀបដូចជាសញ្ញាណមួយដែលឆ្លុះបញ្ចាំងពីបច្ចុប្បន្នភាពនៃជំនាញយុវជនកម្ពុជា។ នៅក្នុងការវាស់វែងកម្រិតជំនាញនេះ នឹងផ្តោតទៅលើជំនាញ ៣ ធំៗគឺ ការប្រើប្រាស់ភាសាបរទេស ជំនាញសំខាន់ៗក្នុងសេដ្ឋកិច្ចឌីជីថល ជំនាញឌីជីថល និងកម្រិតនៃការត្រៀមខ្លួនរបស់យុវជនកម្ពុជាទៅកាន់សេដ្ឋកិច្ចឌីជីថល។

### ៤.៥.១. ការប្រើប្រាស់ភាសាបរទេស

នៅក្នុងចំណោមអ្នកដែលចូលរួមការស្រង់មតិនេះ ភាគច្រើនមានកម្រិតនៃការយល់ដឹង និងអាចប្រើប្រាស់ភាសាអង់គ្លេសច្រើនជាងភាសានានាទាំងអស់។ ក្នុងចំណោម ៣៩០ នាក់ មានតែ ៥៣ នាក់តែប៉ុណ្ណោះដែលអាចប្រើប្រាស់ភាសាចិនបាន ៣៤ នាក់អាចប្រើប្រាស់ភាសាថៃ ២៤ នាក់អាចប្រើប្រាស់ភាសាបារាំងបាន ចំណែកអ្នកដែលអាចប្រើប្រាស់ភាសាជប៉ុន និងកូរ៉េ គឺមានចំនួនតិចខ្លាំងមែនទែនបើប្រៀបធៀបទៅនឹងភាសាដទៃ។ ភាគច្រើននៃយុវជនតែងមានជំនាញភាសាអង់គ្លេស ដោយសារតែវាជាភាសាមួយដែលត្រូវការប្រើប្រាស់ជាមូលដ្ឋានមិនថានៅថ្នាក់វិទ្យាល័យ សាកលវិទ្យាល័យ ឬកន្លែងធ្វើការក្តី។ បច្ចុប្បន្ននៅពេលដែលយុវជនមិនអាចប្រើប្រាស់ភាសាអង់គ្លេស ធ្វើអោយកម្រិតនៃការប្រកួតប្រជែងក្នុងទីផ្សារការងាររបស់ខ្លួនមានកម្រិតមួយដែលមានកម្រិតនៅឡើយ បើប្រៀបធៀបជាមួយនឹងអ្នកដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

ក្រាហ្វិកទី ២០៖ ការប្រើប្រាស់ភាសាបរទេស




ប្រភព៖ ទិន្នន័យវិភាគ

### ៤.៥.២. ជំនាញដែលសំខាន់ក្នុងសេដ្ឋកិច្ចឌីជីថល

នៅក្នុងការវាស់ស្ទង់មតិ យើងបានដាក់ជំនាញ៣សម្រាប់យុវជននៅក្នុងការកំណត់នូវកម្រិតនៃជំនាញរបស់ខ្លួន។នៅក្នុងនោះផងដែរ ភាគច្រើននៃអ្នកចូលរួមស្ទង់មតិ មានកម្រិតល្អនៅក្នុងជំនាញក្នុងការយល់ដឹងទូទៅ ដែលអាចស្វែងយល់នូវបញ្ហាស្មុគស្មាញ ចេះដោះស្រាយបញ្ហាដែលមានភាពស្មុគស្មាញ ចេះសម្របខ្លួនបានល្អនៅក្នុងបរិយាកាសការងារ អាចរៀនពីបទពិសោធន៍ និងមានសមត្ថភាពក្នុងការដោះស្រាយឧបសគ្គដោយមានការគិតស៊ីជម្រៅបែបពិចារណា។

លើសពីនេះទៅទៀត ភាគច្រើនយុវជនមានកម្រិតល្អខាងជំនាញខាងសង្គម និងអាកប្បកិរិយា ដែលមានភាពចេះបត់បែន សម្របខ្លួនតាមកាលៈទេសៈ និងមានអត្តចរិកងាយស្រួលនៅក្នុងការបង្កើតទំនាក់ទំនង និងឆ្លើយតបទៅនឹងស្ថានភាពសង្គមជាក់ស្តែងយ៉ាងមានប្រសិទ្ធភាព។ ក៏ប៉ុន្តែ សម្រាប់ជំនាញខាងបច្ចេកទេសមានចំនួន ៤៥% កម្រិតមធ្យម ហើយ ៣៦.៤ % កម្រិតល្អ។

តាមរយៈទិន្នន័យខាងលើធ្វើអោយយើងអាចសន្និដ្ឋានបានថា យុវជនភាគច្រើនមានកម្រិតល្អនៅក្នុងជំនាញក្នុងការយល់ដឹងទូទៅ និងជំនាញខាងសង្គមនិងអាកប្បកិរិយា ក៏ប៉ុន្តែជំនាញបច្ចេកទេសហាក់នៅមានកម្រិតទាបនៅឡើយដែលតម្រូវអោយមានការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនក្នុងជំនាញនេះអោយកាន់តែប្រសើរឡើងដើម្បីអាចឈានទៅរកសេដ្ឋកិច្ចឌីជីថលមួយដែលពេញលេញនាពេលអនាគត។

ក្រាហ្វិកទី ២១៖ កម្រិតជំនាញសំខាន់ក្នុងសេដ្ឋកិច្ចឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

### ៤.៥.៣. ជំនាញឌីជីថល

នៅក្នុងការស្ទង់មតិបានបង្ហាញអោយឃើញថា ភាគច្រើននៃយុវជនចេះនូវជំនាញមូលដ្ឋានឌីជីថល។ ចំណែកឯជំនាញបន្ទាប់បន្សំជាមួយនឹងឌីជីថល ភាគច្រើននៃអ្នកដែលចូលរួមស្ទង់មតិបាននិយាយថា ចេះតិចតួចតែប៉ុណ្ណោះ ដែលជំនាញនេះមានដូចជាការទំនាក់ទំនងតាមបណ្ដាញសង្គម ការបង្ហាញផលិតផលនិងសេវាកម្មតាមបច្ចេកវិទ្យាឌីជីថល ឬ វិភាគទិន្នន័យដែលប្រមូលបានតាមរយៈគេហទំព័រ។ ដូចគ្នាផងដែរភាគច្រើននៃយុវជនចេះតិចតួចនៅក្នុងជំនាញ Advanced និង Specialist ដែលមានដូចជាការចេះប្រើកម្មវិធី Software បង្កើតកម្មវិធី គ្រប់គ្រងបណ្ដាញ និងវិភាគទិន្នន័យ។

ក្នុងចំណោមជំនាញទាំងបី ជំនាញដែលមានយុវជនមិនចេះច្រើនជាងគេ គឺជំនាញAdvanced និង Specialist ដែលមានត្រឹមតែ១២ នាក់ក្នុងចំណោម ៣៩០នាក់តែប៉ុណ្ណោះដែលចេះច្រើននៅក្នុងជំនាញនេះ និងមានត្រឹមតែ ៥៥នាក់ដែលចេះជំនាញនេះតែម្ដង។ ជំនាញមូលដ្ឋានឌីជីថលមានអ្នកជ្រើសរើសថាចេះច្រើនខ្លាំងជាងគេ ដែលជាហេតុយុវជនត្រូវតែពង្រឹងសមត្ថភាពបន្ថែមទៀតចំពោះជំនាញខាង Advanced និង Specialist។

ក្រាហ្វិកទី ២២៖ កម្រិតជំនាញឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

### ៤.៥.៤. កម្រិតនៃការត្រៀមខ្លួនសម្រាប់ការឈានទៅរកសេដ្ឋកិច្ចឌីជីថល

ថ្វីត្បិតតែយុវជនមានការពេញនិយមនៅក្នុងការប្រើប្រាស់អ៊ីនធើណេត និងសេវាកម្មឌីជីថលផ្សេងៗជាច្រើនក៏ពិតមែន ក៏ប៉ុន្តែនៅក្នុងចំណោមយុវជន ៣៩០នាក់ មានតែយុវជន៦០%ទេ មានទំនុកចិត្តខ្ពស់នៅក្នុងការត្រៀមខ្លួនសម្រាប់ការឈានទៅកាន់សេដ្ឋកិច្ចឌីជីថលនាពេលអនាគត។ ចំណែកឯ ៣៧% មិនប្រាកដចិត្តជាមួយនឹងខ្លួនឯងថាតើនឹងត្រៀមខ្លួនរួចរាល់ហើយរឺនៅ សម្រាប់ការឈានទៅរកសេដ្ឋកិច្ចឌីជីថល ដែលភាគច្រើនពួកគេជាអ្នកដែលចេះតិចតួច និងមិនចេះសោះនៅក្នុងផ្នែកជំនាញ Advanced និង Specialist។ នៅក្នុងនោះ មានតែ ៣% តែប៉ុណ្ណោះ ដែលមិនមានទំនុកចិត្តនៅក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល។

ក្រាហ្វិកទី ២៣៖ កម្រិតនៃការត្រៀមខ្លួនសម្រាប់ការឈានទៅរកសេដ្ឋកិច្ចឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

## ៤.៦. ការយល់ដឹងពីពលរដ្ឋឌីជីថល

នៅក្នុងចំណោម ៣៩០ នាក់ ជាសរុបមាន ៦៥% ដែលធ្លាប់លឺពាក្យពលរដ្ឋឌីជីថល តែមានត្រឹមចំនួន ២៧% តែប៉ុណ្ណោះដែលធ្លាប់លឺ និងស្គាល់ពីនិយមន័យនៃពាក្យពលរដ្ឋឌីជីថល ២៨% ធ្លាប់លឺ ប៉ុន្តែមិនយល់ពីនិយមន័យ និង ១០% ធ្លាប់លឺ យល់ និងអនុវត្តប្រចាំថ្ងៃជាក់ស្តែង។

ក្រាហ្វិកទី២៤៖ កម្រិតនៃការយល់ដឹងពីពលរដ្ឋឌីជីថល




ប្រភព៖ ទិន្នន័យវិភាគ

### ៤.៦.១. បញ្ហាប្រឈមនៃពលរដ្ឋឌីជីថល

ភាគច្រើននៃអ្នកចូលរួមស្ទង់មតិបានបញ្ជាក់អោយឃើញថា បញ្ហាប្រឈមដែលរារាំងដល់ការអភិវឌ្ឍពលរដ្ឋឌីជីថល មានដូចជា៖

- បណ្តាញតភ្ជាប់នៅមានកម្រិត
- ភាសានៅមានកម្រិត
- ការយល់ដឹងពីឌីជីថលនៅមានកម្រិត
- ច្បាប់ដែលធ្វើអោយមានជំនឿទុកចិត្តនៅមានកម្រិត

### ៤.៦.២. កត្តាជំរុញអោយមានពលរដ្ឋឌីជីថល

➢ **ហេដ្ឋារចនាសម្ព័ន្ធឌីជីថល**

- បង្កើនប្រព័ន្ធតភ្ជាប់អោយមានល្បឿនកាន់តែលឿន និងមានតម្លៃកាន់តែសមរម្យ
- បង្កើតអោយមានការធានានូវព័ត៌មានបុគ្គល
- បង្កើនគុណភាពនៃសេវាកម្មអ៊ីនធើណេតអោយកាន់តែមានភាពរីកចម្រើន ជាពិសេសនៅតំបន់ជនបទ

- កែប្រែទម្រង់កម្មវិធីឌីជីថលឲមានភាពសមញ្ញងាយស្រួលប្រើប្រាស់

➢ **ធនធានមនុស្ស**

- ផ្សព្វផ្សាយអោយកាន់តែមានការយល់ដឹងពីផលប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថលនៅក្នុងការរស់នៅប្រចាំថ្ងៃ ដូចជាការទូទាត់តាមប្រព័ន្ធអនឡាញ
- ការពង្រឹងការយល់ដឹងពីការប្រើប្រាស់ឌីជីថល
- ការដាក់ចូលការអប់រំពាក់ព័ន្ធជាមួយនឹងសេដ្ឋកិច្ចឌីជីថល
- ការពង្រឹមបន្ថែមនូវអក្ខរកម្មឌីជីថល
- ការបង្កើតមេរៀន ឬកម្មវិធីដែលមានភាសាខ្មែរកាន់តែច្រើនដើម្បីអោយអ្នកដែលមិនសូវចេះប្រើប្រាស់ភាសាអង់គ្លេសក៏អាចប្រើប្រាស់បាន
- អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ អ្នកមិនចេះសោះយកចិត្តទុកដាក់រៀន សង្គមបរិយាកាសគាំទ្រដំណើរការទាំងមូល

➢ **គោលនយោបាយ ឬ ច្បាប់**

- មានច្បាប់ដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថលដែលបង្កើនទំនុកចិត្តដល់ពលរដ្ឋប្រើប្រាស់ដោយសុវត្ថិភាពនៅក្នុងទម្រង់ឌីជីថល
- ច្បាប់ពាក់ព័ន្ធនឹងសុវត្ថិភាពនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យា
- រដ្ឋាភិបាលគួរបង្កើនការងាររដ្ឋបាលផ្សេងៗ ដោយប្តូរមកជាការដែលអាចដំណើរការឯកសារផ្សេងៗដោយប្រើប្រព័ន្ធអនឡាញជំនួសវិញ ដែលចំណេញពេលវេលា និងមានភាពងាយស្រួល។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ជារួមមក ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវពីឯកសារផ្សេងៗ និងការវិភាគទិន្នន័យដែលបានមកពីការវាស់ស្ទង់មតិដែលស្តីអំពីទស្សនៈយុវជនមកលើការយល់ដឹងពីបញ្ហាប្រឈមនៃពលរដ្ឋឌីជីថល និងកត្តាដែលជម្រុញអោយមានពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល បានបង្ហាញអោយឃើញថាសេដ្ឋកិច្ចឌីជីថលនៅប្រទេសកម្ពុជាកំពុងតែស្ថិតនៅក្នុងស្ថានភាពមួយដែលកំពុងតែធ្វើការកសាងមូលដ្ឋានគ្រឹះនិងការចាប់យកឌីជីថល។ ជាពិសេសបរិបទកូវីដ១៩បានចូលរួមចំណែកនៅក្នុងការផ្លាស់ប្តូរឥរិយាបថសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ សហគ្រាស និងរដ្ឋាភិបាលមកជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងការស្តារនិងទ្រទ្រង់សេដ្ឋកិច្ចជាតិ។ ស្ថានភាពកូវីដ១៩ បានធ្វើអោយកម្ពុជាមកដល់ចំណុចរបត់សេដ្ឋកិច្ចឌីជីថល ដោយសារតែមានការកើនឡើងនៃអ្នកប្រើប្រាស់អ៊ីនធើណេត សហគ្រាសបង្វែររបៀបក្នុងការធ្វើអាជីវកម្មរបស់ខ្លួនមកជាការប្រកបតាមអនឡាញបន្ថែម កំណើននៃការប្រើប្រាស់ការដឹកជញ្ជូនរហ័ស ការផ្លាស់ប្តូររបៀបនៅក្នុងការធ្វើការងារ និងកំណើននៃការប្រើប្រាស់ E-wallet សម្រាប់ការទូទាត់។ ដើម្បីអាចសម្រេចទៅរកសេដ្ឋកិច្ចឌីជីថលបាន យើងត្រូវការមានការចូលរួមចំណែកពីសហគ្រាសឌីជីថល រដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល ហេតុដូចនេះហើយ ការត្រៀមខ្លួនរួចរាល់នៃពលរដ្ឋឌីជីថលមានសារៈសំខាន់ណាស់ក្នុងការជំរុញសេដ្ឋកិច្ចឌីជីថល។ ក្នុងការចាប់យកនូវបរិវត្តកម្មឌីជីថល ពលរដ្ឋឌីជីថលត្រូវពង្រឹងនូវជំនាញរបស់ខ្លួនបន្ថែមទៀត ដើម្បីអាចសម្របខ្លួនបានទៅនឹងបរិបទសេដ្ឋកិច្ចបែបថ្មី និងអាចទទួលបាននូវអត្ថប្រយោជន៍អតិបរមាពីបច្ចេកវិទ្យាឌីជីថល។ ជំនាញសំខាន់ៗដែលពលរដ្ឋឌីជីថលត្រូវមានគឺ ជំនាញក្នុងការយល់ដឹងទូទៅ ជំនាញខាងបច្ចេកវិទ្យា និងជំនាញខាងសង្គម និងអាកប្បកិរិយា។ លើសពីនេះទៅទៀត ពលរដ្ឋគួរមានជំនាញឌីជីថលដូចជា ជំនាញឌីជីថលកម្រិតមូលដ្ឋាន ជំនាញបន្ទាប់បន្សំផ្នែកឌីជីថល និងជំនាញខ្ពស់និងឯកទេសខាងបច្ចេកវិទ្យាឌីជីថល។

ដើម្បីធ្វើការយល់ដឹងពីទស្សនៈរបស់យុវជនមកលើបញ្ហាប្រឈមនៃពលរដ្ឋឌីជីថល និងកត្តាជម្រុញអោយមានពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល យើងបានធ្វើការវាស់ស្ទង់មតិយុវជនចំនួន៣៩០នាក់ដែលមានអាយុចន្លោះពី ១៥ទៅ៣៥ឆ្នាំ ដែលរស់នៅក្នុងតំបន់បីផ្សេងៗគ្នាគឺ ភ្នំពេញ តំបន់ទីប្រជុំជននិងតំបន់ដាច់ស្រយាលនៅខេត្តក្រុង ដោយប្រើប្រាស់កម្មវិធី Google Form ដែលប្រើវិធីសាស្ត្រជ្រើសរើសសំណាកបែប Convenience Sampling។ ភាគច្រើននៃអ្នកដែលចូលរួមក្នុងការស្ទង់មតិ មានកម្រិតអប់រំថ្នាក់បរិញ្ញាបត្រ ប្រើភាសាអង់គ្លេសបានល្អ និងប្រើប្រាស់អ៊ីនធើណេតលើសពី៦ម៉ោងក្នុងមួយថ្ងៃ។ តាមរយៈការវិភាគទិន្នន័យបានបង្ហាញអោយឃើញថា កម្រិតនៃការយល់ដឹងរបស់យុវជនមកលើសេដ្ឋកិច្ចឌីជីថលហាក់នៅមានកម្រិតព្រោះថាមានយុវជនត្រឹមតែ ៥០% ក្នុងចំណោម៣៩០ នាក់ តែប៉ុណ្ណោះដែលធ្លាប់បានលឺពាក្យសេដ្ឋកិច្ចឌីជីថល និងដឹង

ពីនិយមន័យរបស់វា ដោយសារតែគេធ្លាប់បានរៀនមុខវិជ្ជានេះ ចូលរួមក្នុងសិក្ខាសាលាដែលលើកឡើងពីសេដ្ឋកិច្ចឌីជីថល និងការស្រាវជ្រាវដោយខ្លួនឯងពីមុនមក។ ក៏ប៉ុន្តែមានយុវជនប្រមាណ ១៥ ភាគរយមិនធ្លាប់បានលឺពីសេដ្ឋកិច្ចឌីជីថលទាល់តែសោះ ដោយសារតែមិនធ្លាប់បានសិក្សានៅសាលាពីមុខវិជ្ជានេះឬធ្វើការស្រាវជ្រាវពីសេដ្ឋកិច្ចឌីជីថលកន្លងមក និងខ្លះទៀតធ្លាប់បានលឺពាក្យសេដ្ឋកិច្ចឌីជីថលដែរក៏ប៉ុន្តែមិនបានយល់ថាវាជាអ្វីនោះឡើយ។ អ្វីដែលពិសេសជាងនេះទៅទៀត អ៊ីនធើណេតល្បឿនលឿនដែលមានគុណភាពសមជាមួយនឹងតម្លៃពិតជាមានសារៈសំខាន់ណាស់នៅក្នុងការចូលរួមចំណែកអោយមានពលរដ្ឋឌីជីថលកាន់តែមានការកើនឡើង ក៏ប៉ុន្តែតាមរយៈការស្ទង់មតិបានបង្ហាញអោយឃើញថា មានយុវជនរហូតដល់ ៤៦% ដែលបានយល់ឃើញថាតម្លៃមិនសូវសាកសមនឹងគុណភាពនៅឡើយ មិនថានៅក្នុងចំណោមអ្នកដែលនៅភ្នំពេញ រឺតាមបណ្តាខេត្ត។ ការប្រើប្រាស់បណ្តាញតភ្ជាប់ដែលមានល្បឿនលឿនតែមួយមុខនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ពោលពលរដ្ឋឌីជីថលត្រូវចេះប្រើអ៊ីនធើណេតក្នុងគោលបំណងផ្សេងៗដើម្បីទាញយកផលប្រយោជន៍ពេញលេញ។ តាមរយៈការស្ទង់មតិបានបង្ហាញអោយឃើញថាយុវជនកម្ពុជាភាគច្រើនមានការពេញនិយមប្រើប្រាស់នូវអ៊ីនធើណេត សម្រាប់សេវាកម្មឌីជីថលមួយចំនួនដូចជា ការអប់រំបែបឌីជីថល ការទិញទំនិញតាមប្រព័ន្ធអនឡាញ និងការទូទាត់ផ្ទេរប្រាក់តាមគណនីធនាគារ ដែលបានឆ្លុះបញ្ចាំងពីការសម្របខ្លួនយ៉ាងសកម្មនៅក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថលនាពេលអនាគត។ ថ្វីត្បិតតែសេវាកម្មទាំង៣ខាងលើទទួលបានប្រជាប្រិយភាពក្នុងចំណោមសេវាកម្មឌីជីថលផ្សេងទៀតក៏ពិតមែន ក៏កម្រិតនៃភាពញឹកញាប់នៅក្នុងការប្រើប្រាស់សេវាកម្មទាំងនោះ នៅមានគម្លាតពីគ្នានៅឡើយ។ ភាគច្រើននៃយុវជនប្រើអ៊ីនធើណេត សម្រាប់គោលបំណងការអប់រំបែបឌីជីថលយ៉ាងហោចម្តងក្នុងមួយថ្ងៃ តែសម្រាប់ការទូទាត់តាមប្រព័ន្ធឌីជីថលវិញគឺភាគច្រើនទូទាត់ក្នុងមួយសប្តាហ៍ម្តងតែប៉ុណ្ណោះ។ សម្រាប់ការទិញទំនិញអនឡាញវិញ គឺភាគច្រើននៃយុវជនធ្វើការជាវទំនិញមួយខែម្តងតែប៉ុណ្ណោះ។ អ្វីដែលពិសេសជាងនេះទៅទៀត យុវជនភាគច្រើនបានជ្រើសរើសថាបញ្ហាបណ្តាញតភ្ជាប់មានល្បឿនយឺត និងកម្រិតនៃការយល់ដឹងពីរបៀបនៃការប្រើប្រាស់សេវាកម្មឌីជីថលនៅមានកម្រិត ជាបញ្ហាប្រឈមចម្បងសម្រាប់ការសម្រេចចិត្តនៅក្នុងការប្រើប្រាស់សេវាកម្មឌីជីថលមួយចំនួន។ ភាគច្រើនយុវជនដែលបានធ្វើការស្ទង់មតិមានកម្រិតល្អនៅក្នុងជំនាញក្នុងការយល់ដឹងទូទៅ និងជំនាញសង្គមនិងអាកប្បកិរិយា និងកម្រិតមធ្យមក្នុងជំនាញបច្ចេកទេស។ តាមរយៈការវិភាគទិន្នន័យបានបង្ហាញអោយឃើញទៀតថា យុវជនភាគច្រើនចេះជំនាញមូលដ្ឋានឌីជីថល ចេះតិចតួចក្នុងជំនាញបន្ទាប់បន្សំជាមួយនឹងឌីជីថល ពោលមានត្រឹមតែក្រោម១០% តែប៉ុណ្ណោះដែលមិនចេះជំនាញទាំងពីរនេះ។ អ្វីដែលគួរអោយកត់សម្គាល់នោះគឺ មានប្រមាណរហូតដល់ ៣៨.៤៦% ដែលមិនចេះសោះនៅក្នុងជំនាញ Advanced និង Specialist។

ការអភិវឌ្ឍពលរដ្ឋឌីជីថលពិតជាមានសារៈសំខាន់នៅក្នុងការធ្វើអោយកម្ពុជាឈានទៅរកសេដ្ឋកិច្ចឌីជីថលដែលពេញលេញមួយ ហេតុនេះហើយនៅក្នុងការវាស់ស្ទង់មតិរបស់យើងក៏បានធ្វើការសួរទៅកាន់យុវជនអំពីបញ្ហាប្រឈមនានាដែលមានឥទ្ធិពលទៅលើការអភិវឌ្ឍពលរដ្ឋឌីជីថល ហើយយើងបានទទួលចំណុចរួមមួយចំនួនដូចជា បណ្ដាញតភ្ជាប់ ភាសា ការយល់ដឹងពីឌីជីថលមានកម្រិត ជាពិសេសគឺច្បាប់ដែលធ្វើអោយមានជំនឿទុកចិត្តនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងសកម្មភាពសេដ្ឋកិច្ច ជាបញ្ហាប្រឈមដែលធ្វើអោយការកើនឡើងនៃពលរដ្ឋឌីជីថលស្ថិតនៅក្នុងកម្រិតមួយដែលយឺត។ ក្រោយពីបានធ្វើការចែករំលែកពីបញ្ហាប្រឈម យុវជនបានធ្វើការផ្ដល់នូវមតិយោបល់មកលើកត្តាដែលជំរុញអោយមានការកើនឡើងពលរដ្ឋឌីជីថលកាន់តែប្រសើរឡើងដូចជា ការបង្កើនហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការអភិវឌ្ឍធនធានមនុស្ស និងការគាំទ្រគោលនយោបាយ ឬច្បាប់ដែលពាក់ព័ន្ធនឹងការលើកតម្កើងទំនុកចិត្តពលរដ្ឋអោយមានភាពជឿជាក់ក្នុងសេដ្ឋកិច្ចឌីជីថល។ នៅក្នុងចំណោមយុវជន ៣៩០រូប មានយុវជន ៦០% ដែលមានទំនុកចិត្តខ្ពស់នៅក្នុងការត្រៀមខ្លួនឈានទៅរកសេដ្ឋកិច្ចឌីជីថល ហើយសម្រាប់អ្នកដែលមិនប្រាកដចិត្ត និងអ្នកដែលមិនមានទំនុកចិត្តក្នុងការត្រៀមខ្លួនទៅកាន់សេដ្ឋកិច្ចឌីជីថលវិញភាគច្រើនជាអ្នកដែលចេះតិចតួចនិងមិនចេះសោះនៅក្នុងជំនាញ Advanced និង Specialist។

## ២. អនុសាសន៍

ការឈានទៅរកសេដ្ឋកិច្ចឌីជីថលមួយដែលពេញលេញទាមទារអោយមានការចូលរួមយ៉ាងសកម្មពីពលរដ្ឋ សហគ្រាស និងរាជរដ្ឋាភិបាល។ ខាងក្រោមនេះជាអនុសាសន៍មួយចំនួនដែលបុគ្គល ឬស្ថាប័នពាក់ព័ន្ធអាចធ្វើការផ្ដោតសំខាន់ ដើម្បីអាចឈានទៅរកសេដ្ឋកិច្ចឌីជីថលរួមគ្នាប្រកបដោយចីរភាព៖

- **យុវជន៖**

ភាគច្រើននៃយុវជនមានការយល់ដឹងនៅមានកម្រិតអំពីសេដ្ឋកិច្ចឌីជីថល អាស្រ័យហេតុនេះហើយ យុវជនគួរតែចំណាយពេលវេលាទៅលើការស្រាវជ្រាវ ក៏ដូចជាចូលរួមនៅក្នុងកម្មវិធីផ្សេងៗដែលទាក់ទងនឹងការបណ្ដុះបណ្ដាលពីជំនាញនេះ ដើម្បីអាចត្រៀមខ្លួនរួចរាល់ជាមួយនឹងបរិវត្តកម្មឌីជីថលនេះ។

ជាពិសេស យុវជនគួរធ្វើការសិក្សាតាមវិធីផ្សេងៗដើម្បីអភិវឌ្ឍជំនាញបច្ចេកវិទ្យា និងជំនាញឌីជីថលខាង Advanced និង Specialist ដោយសារតែវាជំនាញទាំងពីរនេះហាក់នៅមានកម្រិតជាយូរឆ្នាំណាស់មកហើយ។ ដូចនេះ ដើម្បីអាចត្រៀមខ្លួនបានរួចរាល់នៅក្នុងសេដ្ឋកិច្ចឌីជីថល គេគួរតែបង្កើនសមត្ថភាពរបស់ខ្លួនក្នុងជំនាញទាំងនេះ និងចូលរួមកម្មវិធីផ្សេងៗដែលបង្កើនការយល់ដឹងពីអក្ខរកម្មឌីជីថល។

- **សហគ្រាស៖**

សម្រាប់សហគ្រាសដែលមានការប្រើប្រាស់កម្មវិធីឌីជីថលក្នុងការសម្របក្នុងអាជីវកម្មរបស់ខ្លួនគួរតែបន្តអភិវឌ្ឍន៍នូវគុណភាពកម្មវិធី និងសេវាកម្មរបស់ខ្លួនដើម្បីអាចមានជំហរកាន់តែមានភាពរឹងមាំ និងអាចធ្វើការឆ្លើយតបជាមួយនឹងដៃគូប្រកួតប្រជែង។ ចំណែកឯស្ថាប័នដែលមិនទាន់មានការដាក់បញ្ចូលនូវបច្ចេកវិទ្យាឌីជីថលនៅក្នុងស្ថាប័នរបស់ខ្លួនគួរគិតគូពង្រឹងសេវាកម្មរបស់ខ្លួន ដើម្បីអាចសម្របខ្លួនជាមួយនឹងបច្ចេកវិទ្យាឌីជីថលនៅក្នុងសេដ្ឋកិច្ច និងអាចបំពេញតម្រូវការរបស់អតិថិជននៅក្នុងសម័យឌីជីថលនេះ។ តាមការស្ទង់មតិបានបង្ហាញអោយឃើញថាបញ្ហាប្រឈមមួយនៅក្នុងបញ្ហាប្រឈមផ្សេងទៀតនៅក្នុងការប្រើប្រាស់សេវាកម្មឌីជីថលគឺបណ្តាលមកពីកម្រិតនៃការយល់ដឹងអំពីរបៀបប្រើប្រាស់កម្មវិធីឌីជីថល ហេតុដូចនេះ នៅពេលដែលសហគ្រាសធ្វើការបង្កើតនូវកម្មវិធីឌីជីថលគួរតែមានការរៀបចំកម្មវិធីនោះអោយមានភាពងាយស្រួលនៅក្នុងការប្រើប្រាស់ និងបង្ហាញពីរបៀបនៅក្នុងការចូលទៅប្រើប្រាស់ដើម្បីអោយពលរដ្ឋមានទំនុកចិត្តនៅក្នុងការប្រើប្រាស់កម្មវិធីទាំងនោះនៅក្នុងការជាវទំនិញ ឬសេវាកម្មពីសហគ្រាស។ ថ្វីត្បិតតែការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងជីវិតប្រចាំថ្ងៃក្នុងចំណោមយុវជនភាគច្រើនមានការកើនឡើងក៏ពិតមែន ក៏ប៉ុន្តែតម្លៃនៃបណ្តាញតភ្ជាប់ហាក់នៅមិនសូវសមជាមួយនឹងគុណភាពនៅឡើយ ដូចនេះហើយក្រុមហ៊ុនដែលធ្វើការផ្គត់ផ្គង់សេវាកម្មបណ្តាញតភ្ជាប់គួរតែធ្វើការគិតគូរអភិវឌ្ឍនូវសេវាកម្មរបស់ខ្លួនអោយកាន់តែប្រសើរឡើងជាមួយនឹងតម្លៃមួយដែលសមរម្យ និងគួរតែមានទំនួលខុសត្រូវនៅក្នុងការដោះស្រាយបញ្ហាអតិថិជននៅពេលដែលមានបញ្ហាបណ្តាញតភ្ជាប់ដើម្បីធ្វើការផ្តល់ទំនុកចិត្ត និងភាពងាយស្រួលសម្រាប់ការប្រើប្រាស់កម្មវិធីឌីជីថល។

- **រាជរដ្ឋាភិបាលៈ**

សមស្របជាមួយនឹងការកើនឡើងនៃការចាប់យកឌីជីថលរបស់យុវជនភាគច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ រាជរដ្ឋាភិបាលគួរតែធ្វើការផ្តោតសំខាន់នៅក្នុងការធ្វើការយ៉ាងណាបង្កើនទំនុកចិត្តនៅចំណុចត្រង់ណាដែលជាបញ្ហាប្រឈមរារាំងក្នុងការឈានទៅរកសេដ្ឋកិច្ចឌីជីថល ដូចជាសេវាអ៊ីនធើណេតនៅមានកម្រិត និងកម្រិតនៃការយល់ដឹងនិងទំនុកចិត្តលើសេវាកម្មឌីជីថល ដោយបង្កើតគោលការណ៍ផ្សេងៗដែលយកចិត្តទុកដាក់លើការការពារព័ត៌មានឯកជន ការការពារពីការវាយប្រហារ និងការឆបោកតាមប្រព័ន្ធអនឡាញ។ មួយវិញទៀត រដ្ឋាភិបាលគួរយកចិត្តទុកដាក់នៅក្នុងការចូលរួមគាំទ្រកម្មវិធី ឬគម្រោងទាំងឡាយណាដែលធ្វើការពាក់ព័ន្ធជាមួយនឹងការបង្កើនចំណេះដឹងយុវជនអំពីអក្ខរកម្មឌីជីថល។ តាមការស្រាវជ្រាវរបស់យើងបានបង្ហាញអោយឃើញថាមានត្រឹមតែ១០%នៃអ្នកស្ទង់មតិតែប៉ុណ្ណោះដែលធ្លាប់បានសិក្សាមុខវិជ្ជាសេដ្ឋកិច្ចឌីជីថល ដូចនេះ ក្រសួងអប់រំគួរធ្វើការពិចារណាបញ្ចូលនូវជំនាញដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថលចូលទៅក្នុងការសិក្សាគ្រប់ជាន់ថ្នាក់ដើម្បីបន្សាំយុវជនជំនាន់ក្រោយជាមួយនឹងអក្ខរកម្មឌីជីថលដែលនាំអោយឈានទៅរកសេដ្ឋកិច្ចឌីជីថលពេញលេញនាពេលអនាគត។

# ឯកសារយោង

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១) *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១ - ២០៣៥* យកពី https://mef.gov.kh/ (ចូលទស្សនាថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២១)

ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ (២០១៦) *គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០*

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច, ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧, ០៨ តុលា ២០១៩ យកពី national-assembly.org.kh (ចូលទស្សនាថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២១)

និយ័តករទូរគមនាគមន៍កម្ពុជា (២០២១) យកពី www.trc.gov.kh (ចូលទស្សនាថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០២១)

យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ (២០១៨) យកពី www.mcs.gov.kh

Bizkhmer (២០២០) *ជំនាញទន់ចំនួន ៤ ប្រសិនបើអ្នកចង់ឲ្យអាជីពការងាររបស់អ្នករីកលូតលាស់ទៅមុខបន្ត* យកពី www.bizkhmer.com (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១)

## ឯកសារជាភាសាបរទេស

ADB (២០១៦) *Here Comes Cambodia: Asia's New Tiger Economy* ,

យកពី www.adb.org (ចូលទស្សនាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០២១)

Annika Hedberg និង Stefan Šipka (២០២០) *The circular economy: Going digital*

យកពី www.epc.eu/en/ (ចូលទស្សនាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២១)

Bukht និង Heeks (២០១៧) *Defining, Conceptualising and Measuring the Digital Economy*

យកពី www.researchgate.net ( ចូលទស្សនាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០២១)

Data Reportal (២០២១) *Digital 2021: Cambodia*. យកពី: datareportal.com ( ចូលទស្សនាថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០២១)

European Commission (២០២០) *The Digital Economy and Society Index (DESI)*

យកពី digital-strategy.ec.europa.eu/en (ចូលទស្សនាថ្ងៃទី១២ខែឧសភា ឆ្នាំ២០២១)

GSM Association (២០១៧) *Embracing the Digital Revolution*

យកពី www.gsma.com (ចូលទស្សនាថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០២១)

Jitka & Christ (២០១៦) *Cambodian IT industry: skills for a digital economy*

យកពី *digitalrain.agency* ( ចូលទស្សនាថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០២១)

Khmertimes (២០១៩) *Digitising Cambodia´s economic future* យកពី www.khmertimeskh.com (ចូលទស្សនាថ្ងៃទី១៧ ខែឧសភាឆ្នាំ២០២១)

Khmertimes (២០២០) *Cambodia records 14.8 million mobile internet subscribers as of May, down 2.36 percent* យកពី www.khmertimeskh.com (ចូលទស្សនាថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០២១)

KOICA (២០១៤) *Summary on Cambodian ICT Master Plan 2020* យកពី www.trc.gov.kh ( ចូលទស្សនាថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២១)

Mekong Connect (២០២១) *Post-COVID-19 Economic Recovery In The Mekong Region* យកពី https://www.kas.de/en/ ( ចូលទស្សនាថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២១)

Mekong Strategic Partners (2020) *Cambodia´s Fintech 2021 [Report].* យកពី https://www.mekongstrategic.com/ (ចូលទស្សនាថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២១)

Miller, B. and R.D. Atkinson (២០១៤), *Raising European productivity growth through ICT* យកពី http://www2.itif.org/2014-raising-eu-productivity-growth-ict.pdf ( ចូលទស្សនាថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០២១)

Monetary Authority of Singapore. (2020). *Foundational Digital Infrastructures for Inclusive Digital Economy*, យកពី https://www.nbc.org.kh/ (ចូលទស្សនាថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២១)

OECD (២០១២) *The Digital Economy* យកពី https://www.oecd.org/ ( ចូលទស្សនាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២១)

OECD (២០១៦) *Harnessing the digital economy for developing countries* យកពី https://www.oecd.org/ ( ចូលទស្សនាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២១)

OECD (២០០១) *Understanding the Digital Divide* យកពី https://www.oecd.org/ ( ចូលទស្សនាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)

Pheakdey Heng (២០១៨). *Embracing the Digital Economy: Policy Considerations for Cambodia*, Phnom Penh: Enrich Institute. យកពី www.enrichinstitute.org/ ( ចូលទស្សនាថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០២១)

Pheakdey Heng (២០១៩) *Preparing Cambodia's Workforce for a Digital Economy* យកពី https://www.kas.de/en/ ( ចូលទស្សនាថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២១)

Pirun, Siriwat, & Darlin (២០២១) *Developing Cambodia's Digital Economy: Youth's perspective* យកពី www.nbc.org.kh (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១)

Portulans Institute. (2019). *Network Readiness Index 2019*, Washington D.C., USA. យកពី networkreadinessindex.org ( ចូលទស្សនាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១)

Portulans Institute. (២០២០). *Network Readiness Index ២០២០*, Washington D.C., USA. យកពី networkreadinessindex.org ( ចូលទស្សនាថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២១)

UNDP (2020) *Digital Literacy for Employability and Entrepreneurship among Cambodian Youth* , យកពី www.kh.undp.org ( ចូលទស្សនាថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២១)

World Bank (២០១៦) *World Development Report 2016: Digital Dividends* យកពី www.worldbank.org ( ចូលទស្សនាថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២១)

World Bank (២០១៨) *Benefiting from Digital Economy* យកពី www.worldbank.org (ចូលទស្សនាថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២១)

World Bank (២០១៩) *The Digital Economy in Southeast Asia: Strengthening the Foundations for Future Growth ( Working paper No. 137143)* យកពី www.worldbank.org ( ចូលទស្សនាថ្ងៃទី ២៦ខែឧសភា ឆ្នាំ២០២១)

World Bank (២០២១), Cambodia Overview យកពី www.worldbank.org ( ចូលទស្សនាថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១)

World Economic Forum (២០១៦) *The Future of Jobs* យកពី www.weforum.org ( ចូលទស្សនាថ្ងៃទី ១៩ខែមិថុនា ឆ្នាំ២០២១)

World Economic Forum (២០១៨). *Global Competitiveness Report 2018.* យកពី www.weforum.org ( ចូលទស្សនាថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២១)

World Economic Forum (២០១៩) *Global Competitiveness Report 2019.* យកពី www.weforum.org ( ចូលទស្សនាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១)

Xinhua. 2019. *"Cambodia needs a decade to grow digital economy: Economy Minister."* យកពី www.xinhuanet.com ( ចូលទស្សនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ កម្រងសំណួរ

កម្រងសំណួរនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងទាក់ទងនឹងការសិក្សាសម្រាប់សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "សេដ្ឋកិច្ចឌីជីថលកម្ពុជា"។ លទ្ធផលនៃកម្រងសំណួរនេះ ត្រូវបានប្រើប្រាស់សម្រាប់វិភាគដើម្បីបកស្រាយលទ្ធផលនៃការស្រាវជ្រាវនេះ។

យើងខ្ញុំសូមធានាថា រាល់ការឆ្លើយតបរបស់អ្នក នឹងត្រូវបានរក្សាជាការសម្ងាត់។ ការវាស់ស្ទង់មតិនេះទាមទាររយៈពេលប្រហែល ២ ទៅ ៣ នាទីនៅក្នុងការបំពេញ! សូមអរគុណទុកជាមុនសម្រាប់ការចូលរួមរបស់អ្នកនៅក្នុងការឆ្លើយតបនឹងកម្រងសំណួរ។

១. ភេទ (រើសយកតែមួយគត់)

- ☐ ស្រី
- ☐ ប្រុស

២. អាយុ (រើសយកតែមួយគត់)

- ☐ ១៥-១៧
- ☐ ១៨-២២
- ☐ ២៣-២៩
- ☐ ៣០-៣៥

៣.ចូរជ្រើសរើសទីតាំងរស់នៅរបស់អ្នក (រើសយកតែមួយគត់)

- ☐ ភ្នំពេញ
- ☐ ខេត្ត/ក្រុង (ទីប្រជុំជន ឬទីរួមខេត្ត)
- ☐ ខេត្ត/ក្រុង (ជនបទ ឬតំបន់ដាច់ស្រយាល)

៤. កម្រិតនៃការអប់រំ (រើសយកតែមួយគត់)

- ☐ វិទ្យាល័យ
- ☐ បរិញ្ញាបត្រ
- ☐ អនុបណ្ឌិត
- ☐ បណ្ឌិត

៥. ស្ថានភាពការងារ (រើសយកតែមួយគត់)

- ☐ វិស័យរដ្ឋ
- ☐ វិស័យឯកជន
- ☐ អាជីវកម្មផ្ទាល់ខ្លួន
- ☐ អ្នកធ្វើការឯករាជ្យ (Freelancer)
- ☐ អ្នកមិនទាន់មានការងារ (កំពុងរៀន)

៦. ចូរជ្រើសរើសភាសាដែលអ្នកអាចប្រើបានក្រៅពីភាសាជាតិ (អាចរើសបានលើសពីមួយ)

- ☐ អង់គ្លេស
- ☐ ចិន
- ☐ ជប៉ុន
- ☐ បារាំង
- ☐ កូរ៉េ
- ☐ ថៃ
- ☐ ផ្សេងៗ

៧. កម្រិតនៃការយល់ដឹងផ្នែកភាសាអង់គ្លេស (រើសយកតែមួយគត់ក្នុងមួយជួរដេក)

| | Elementary | Lower Intermediate | Upper Intermediate | Proficient |
|---|---|---|---|---|
| ការអាន | | | | |
| ការស្តាប់ | | | | |
| ការនិយាយ | | | | |
| ការសរសេរ | | | | |

៨. តើអ្នកធ្លាប់ដឹងថា អ្វីទៅជា "សេដ្ឋកិច្ចឌីជីថល" ដែរឬទេ? (រើសយកតែមួយគត់)

- ☐ មិនធ្លាប់លឺពីមុនមក
- ☐ ធ្លាប់លឺ តែមិនធ្លាប់យល់ពីនិយមន័យ
- ☐ ធ្លាប់លឺ និងយល់ពីនិយមន័យ
- ☐ ធ្លាប់លឺ យល់ និងអនុវត្តប្រចាំថ្ងៃជាក់ស្តែង

៩. ចូរជ្រើសរើសមូលហេតុដែលអ្នកជ្រើសយកចម្លើយទី១ខាងលើ (រើសយកតែមួយគត់)

- ☐ ធ្លាប់រៀនសេដ្ឋកិច្ចឌីជីថលពីមុនមក
- ☐ ធ្លាប់បានស្រាវជ្រាវដោយខ្លួនឯង

- ☐ មិនសូវបានប្រើប្រាស់កម្មវិធីឌីជីថល
- ☐ ផ្សេងៗ

១០. តើអ្នកកំពុងប្រើប្រាស់ឧបករណ៍ឌីជីថលអ្វីខ្លះ? (អាចរើសបានលើសពីមួយ)

- ☐ ទូរស័ព្ទ (Smart Phone)
- ☐ Laptop
- ☐ Tablet
- ☐ កុំព្យូទ័រ Desktop
- ☐ គណនីធនាគារ
- ☐ កាតធនាគារ

១១. តើអ្នកប្រើប្រាស់ប្រព័ន្ធ Internet ឬ Wifi សម្រាប់ការប្រើប្រាស់អនឡាញ? (រើសយកតែមួយគត់)

- ☐ អ៊ីនធើណេត
- ☐ អ៊ីនណេត និង Wifi
- ☐ Wifi
- ☐ អ៊ីនធើណេតច្រើនជាង Wifi
- ☐ Wifi ច្រើនជាងអ៊ីនធើណេត

១២. ចូរជ្រើសរើសកម្រិតល្បឿននៃបណ្តាញតភ្ជាប់នៅទីតាំងដែលអ្នករស់នៅ (រើសយកតែមួយគត់)

- ☐ លឿនណាស់
- ☐ លឿន
- ☐ យឺត
- ☐ យឺតណាស់
- ☐ ឧស្សាហ៍ដាច់
- ☐ យូរៗដាច់ម្តង

១៣. តើអ្នកគិតថាថ្លៃបណ្តាញតភ្ជាប់ (InternetឬWifi) សាកសមទៅនឹងគុណភាពនៃល្បឿនដែលជាតម្រូវការរបស់អ្នកដែរទេ? (រើសយកតែមួយគត់)

- ☐ ថ្លៃមិនសាកសមនឹងគុណភាព
- ☐ ថ្លៃមិនសូវសាកសមនឹងគុណភាព
- ☐ ថ្លៃសាកសមនឹងគុណភាព

- ☐ ថ្លៃសាកសមនឹងគុណភាពណាស់

១៤. តើអ្នកប្រើប្រាស់អ៊ីនធើណេតប៉ុន្មានម៉ោងក្នុងមួយថ្ងៃ? (រើសយកតែមួយគត់)

- ☐ តិចជាង២ម៉ោង
- ☐ តិចជាង៤ម៉ោង
- ☐ តិចជាង៦ម៉ោង
- ☐ លើសពី៦ម៉ោង

១៥. ចូរជ្រើសរើសទម្រង់កម្មវិធីដែលអ្នកប្រើប្រាស់កន្លងមក(អាចរើសបានលើសពីមួយ)

- ☐ ការទូទាត់បែបឌីជីថល/ការផ្ទេរប្រាក់ប្រើសេវាកម្មដឹកអាហារ (Foodpanda, Nham 24...)
- ☐ ប្រើសេវាកម្មកំសាន្ត
- ☐ ប្រើសម្រាប់កក់យានជំនិះ (Grab, Passapp...)
- ☐ ទិញទំនិញតាមអនឡាញ
- ☐ ការអប់រំតាមអនឡាញ
- ☐ ស្វែងរកការងារតាមអនឡាញ (Freelancer)

១៦. តើអ្នកប្រើប្រាស់ Platform ខាងក្រោមនេះញឹកញាប់ប៉ុណ្ណាដែរ? (រើសយកតែមួយគត់ក្នុងមួយជួរដេក)

| | យ៉ាងហោចម្តងក្នុងមួយថ្ងៃ | ២ទៅ៣ដងក្នុងមួយសប្តាហ៍ | ម្តងក្នុងមួយសប្តាហ៍ | មួយខែម្តង | កម្រណាស់ | មិនធ្លាប់សោះ |
|---|---|---|---|---|---|---|
| ការទូទាត់បែបឌីជីថល/ការផ្ទេរប្រាក់ | | | | | | |
| ប្រើសេវាកម្មដឹកអាហារ (Foodpnada, Nham 24...) | | | | | | |
| ប្រើសេវាកម្មកំសាន្ត | | | | | | |
| ប្រើសម្រាប់កក់យានជំនិះ( Grab, Passapp...) | | | | | | |
| ទិញទំនិញតាមអនឡាញ | | | | | | |
| ការអប់រំតាមអនឡាញ | | | | | | |
| ស្វែងរកការងារតាមអនឡាញ (Freelancer) | | | | | | |

១៧. តើកត្តាអ្វីខ្លះជាឧបសគ្គសម្រាប់អ្នកក្នុងការប្រើប្រាស់សេវាកម្មឌីជីថលសេវាអ៊ីនធឺណេតយឺត (អាចរើសបានលើសពីមួយ)

- ☐ កង្វះឧបករណ៍ឌីជីថល (ទូរស័ព្ទ Laptop...)
- ☐ ភាសានូវមានកម្រិត
- ☐ ការយល់ដឹងពីរបៀបប្រើប្រាស់ឧបករណ៍ឌីជីថលនៅមានកម្រិត
- ☐ មិនទុកចិត្តនឹងសេវាកម្មអនឡាញ
- ☐ ផ្សេងៗ

១៨. ចូរជ្រើសរើសកម្រិតនៃជំនាញដែលអ្នកមាន (រើសយកតែមួយគត់ក្នុងមួយជួរដេក)

| | ល្អណាស់ | ល្អ | មធ្យម | ខ្សោយ | ខ្សោយខ្លាំង |
|---|---|---|---|---|---|
| ជំនាញក្នុងការយល់ដឹងទូទៅ | | | | | |
| ជំនាញខាងសង្គម និងអាកប្បកិរិយា | | | | | |
| ជំនាញបច្ចេកទេស | | | | | |

១៩. ចូរជ្រើសរើសកម្រិតនៃជំនាញដែលអ្នកមានទាក់ទងនឹងឌីជីថលក្នុងពេលបច្ចុប្បន្ន (រើសយកតែមួយគត់ក្នុងមួយជួរដេក)

| | ចេះច្រើន | ចេះ | ចេះតិចតួច | មិនចេះសោះ |
|---|---|---|---|---|
| ជំនាញមូលដ្ឋាននៃឌីជីថល-Basic Digital | | | | |
| ជំនាញបន្ទាប់បន្សំជាមួយនឹងឌីជីថល-Digital Complementary Skill | | | | |
| ជំនាញ Advance និង Specialist | | | | |

២០. តើអ្នកស្គាល់និយមន័យពលរដ្ឋឌីជីថលដែរឬទេ? (រើសយកតែមួយគត់)

- ☐ មិនធ្លាប់លឺពីមុនមកធ្លាប់លឺ តែមិនយល់ពីនិយមន័យ
- ☐ ធ្លាប់លឺ និងយល់ពីនិយមន័យ
- ☐ ធ្លាប់លឺ យល់ និងអនុវត្តប្រចាំថ្ងៃជាក់ស្តែង

២១. តើអ្នកគិតថាអ្នកបានត្រៀមខ្លួនរួចហើយឬនៅ សម្រាប់ការឈានទៅរកសេដ្ឋកិច្ចឌីជីថលនាពេលអនាគត? (រើសយកតែមួយគត់)

- ☐ មានទំនុកចិត្តខ្ពស់
- ☐ មិនប្រាកដចិត្ត
- ☐ មិនមានទំនុកចិត្ត
- ☐ តើអ្នកគិតថាបញ្ហាអ្វីខ្លះដែលរារាំងដល់ការអភិវឌ្ឍពលរដ្ឋឌីជីថល ?

២២.តើអ្នកគិតថាយើងគួរធ្វើបែបណាដើម្បីជម្រុញអោយមានការកើនឡើងពលរដ្ឋឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថល?

...............................................................................................................................

២៣. តើអ្នកគិតថាពលរដ្ឋឌីជីថលសំខាន់កម្រិតណានៅក្នុងការឈានទៅកាន់ពលរដ្ឋឌីជីថល?

...............................................................................................................................

២៤. សូមធ្វើការវាយតម្លៃដោយជ្រើសរើសរវាងកម្រិត១ទៅកម្រិត៥( លេខ១មានន័យថាសំខាន់តិចជាងគេបំផុត និងលេខ៥សំខាន់ខ្លាំងបំផុត) (រើសយកតែមួយគត់)

- ☐ 1
- ☐ 2
- ☐ 3
- ☐ 4
- ☐ 5

# ឧបសម្ព័ន្ធទី២៖ សន្ទានុក្រម

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ១ | Algorithm | ក្បួនដោះស្រាយ | ក្បួន ឬ បណ្តុំនៃជំហានដែលត្រូវអនុវត្តដោយកុំព្យូទ័រ ដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយ ។ |
| ២ | Application Programming Interface ( APIs ) | សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ( អេភីអាយ ) | ច្រកចេញ-ចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរ ឬ ច្រើន ។ |
| ៣ | Application Software | កម្មវិធីសុស្វវែរ | កម្មវិធីកុំព្យូទ័រដែលបង្កើតឡើងក្នុងគោលបំណងសម្រួលដល់អ្នកប្រើប្រាស់ដើម្បីបំពេញការងារជាក់លាក់ណាមួយ តាមរយៈកុំព្យូទ័រ ទូរស័ព្ទឆ្លាត ឬ ឧបករណ៍បច្ចេកវិទ្យានានា ។ |
| ៤ | Artificial Intelligence ( AI ) | បញ្ញាសិប្បនិម្មិត | បច្ចេកវិទ្យាដែលអនុញ្ញាតឱ្យម៉ាស៊ីនកុំព្យូទ័រមានសមត្ថភាពរៀន គិត វិភាគ និង យល់ដឹងពីបញ្ហាជាក់លាក់ណាមួយ ដោយយកលំនាំតាមសមត្ថភាពរបស់ខួរក្បាលមនុស្ស ។ |
| ៥ | Bakong | ប្រព័ន្ធបាគង | ឈ្មោះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងផ្តល់អន្តរប្រតិបត្តិការទូទាត់ និង ផ្ទេរប្រាក់ រវាងធនាគារនៅក្នុងស្រុកដែលជាសមាជិក ។ |
| ៦ | Big data | ទិន្នន័យធំ | បណ្តុំទិន្នន័យដែលមានទំហំធំ មានច្រើនសណ្ឋាន និង ជាទូទៅគ្មានរចនាសម្ព័ន្ធច្បាស់លាស់ ហើយត្រូវបានប្រើប្រាស់ដើម្បីវិភាគរកលំនាំ និន្នាការ និង ការជាប់ទាក់ទងគ្នា រវាងដែនមួយទៅដែនមួយទៀត ។ |
| ៧ | Blockchain Technology | បច្ចេកវិទ្យាប្លុកឆេន | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យជាខ្សែច្រវាក់ដែលមិនត្រូវការកែប្រែ ហើយទិន្នន័យទាំងនោះនឹងត្រូវចម្លងដើម្បីផ្ទុកនៅតាមបណ្តាម៉ាស៊ីនមេ ដែលចូលរួមក្នុងហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យនេះក្នុងទម្រង់បែបវិមជ្ឈការ ។ |
| ៨ | Broadband | បណ្តាញអ៊ីនធឺណិតល្បឿនលឿន | សំដៅដល់ការបញ្ជូនទិន្នន័យក្នុងល្បឿនលឿនដោយពឹងផ្អែកទៅលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ។ |
| ៩ | Cambodia Data Exchange ( CamDX ) | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា | ថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល សម្រាប់ផ្លាស់ប្តូរទិន្នន័យដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ននានា និង រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់វិស័យឯកជន ដោយសុវត្ថិភាព និង ដោយយន្តការច្បាស់លាស់តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬ បណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ ។ |

| | | | |
|---|---|---|---|
| ១០ | Cloud (computing) Technology | បច្ចេកវិទ្យាក្លោដ | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាកម្ម ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ១១ | Cloud-Based Service | សេវាកម្មក្លោដ | សេវាកម្មនៃការប្រើប្រាស់កម្មវិធីសុស្វវែរដែលប្រតិបត្តិការលើបច្ចេកវិទ្យាក្លោដ ។ |
| ១២ | Cybercrime | ឧក្រិដ្ឋកម្មសាយប័រ | បទល្មើស ដែលប្រព្រឹត្តនៅក្នុងបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ដូចជា ការចូលលួច ក្លែងបន្លំ ឬ កែឯកសារ ការបញ្ចូលមេរោគ ការផ្ញើសារគំរាមកំហែង ឬចាប់ជំរិត ឬ ការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ច និង សង្គមជាតិ ។ |
| ១៣ | Cybersecurity | សន្តិសុខសាយប័រ | ការអនុវត្តនៃការទប់ស្កាត់ ការឆ្លើយតប និង ការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំង ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ប្រព័ន្ធប្រតិបត្តិការ និង កម្មវិធី ពីការជ្រៀតចូល និង ការវាយប្រហារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ១៤ | Data | ទិន្នន័យ | បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬ កម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក ។ |
| ១៥ | Data Center | មជ្ឈមណ្ឌលទិន្នន័យ | ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាកម្ម ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ |
| ១៦ | Data Infrastructure | ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ | ហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីផ្ទុក បំប្លែង និង វិភាគទិន្នន័យដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ និង ការប្រើប្រាស់ទិន្នន័យ ។ |
| ១៧ | Data Privacy (Information Privacy) | ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន | នីតិវិធីដែលធានាថាទិន្នន័យរបស់រូបវន្តបុគ្គល និង នីតិបុគ្គលដែលទទួលបានការយល់ព្រមឱ្យកត់ត្រាដោយនីតិបុគ្គលណាមួយក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមិនត្រូវបានចែករំលែក លួចយក ឬ យកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យ ។ |
| ១៨ | Database | មូលដ្ឋានទិន្នន័យ | បណ្តុំទិន្នន័យដែលមានទំនាក់ទំនងគ្នាបង្កើតឡើងក្នុងគោលបំណងងាយស្រួលគ្រប់គ្រង និង ស្វែងរក ។ |
| ១៩ | Data-Driven Governance | អភិបាលកិច្ចដោយផ្អែកលើទិន្នន័យ | អភិបាលកិច្ចដោយប្រើប្រាស់ទិន្នន័យដើម្បីនាំឱ្យមានការសម្រេចចិត្តជាគោលនយោបាយ កំណត់គោលដៅ ផ្លាស់ប្តូរវិធានការគោលនយោបាយ និង តាមដានការអនុវត្តគោលនយោបាយក្នុងន័យបង្កើនតម្លាភាព ។ |

| | | | |
|---|---|---|---|
| ២០ | Digital Technology | បច្ចេកវិទ្យាឌីជីថល | បច្ចេកវិទ្យាដែលប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ឧបករណ៍ឆ្លាត ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ធនធានគណនា សម្រាប់បង្កើត ផ្ទុក បំប្លែង និង វិភាគទិន្នន័យ ។ |
| ២១ | Digital Adaptation | ការសម្របឌីជីថល | សមត្ថភាពរបស់មនុស្សក្នុងការយល់ដឹង និង ការសម្របខ្លួនទៅតាមការវិវឌ្ឍឥតឈប់ឈររបស់បច្ចេកវិទ្យាឌីជីថលដែលចាក់ឫសជ្រៅទៅក្នុងធុរកិច្ច សេដ្ឋកិច្ច និង សង្គម ។ |
| ២២ | Digital Adoption | ការស្រូបយក ឬ ការចាប់យកឌីជីថល | ស្ថានភាពដែលមនុស្សមានជំនាញក្នុងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ថ្នាលឌីជីថលតាមបំណង និង ឱ្យអស់លទ្ធភាព ។ |
| ២៣ | Digital business | ធុរកិច្ចឌីជីថល | ធុរកិច្ចដែលមានអាជីវកម្មចម្បងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬ ផ្តល់សេវាឌីជីថល ឬ បង្កើតផលិតផលជាបច្ចេកវិទ្យាឌីជីថល ។ |
| ២៤ | Digital Citizen | ពលរដ្ឋឌីជីថល | ប្រជាពលរដ្ឋដែលចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកិច្ចការ និង ការរស់នៅប្រចាំថ្ងៃ ។ |
| ២៥ | Digital Content | ខ្លឹមសារឌីជីថល | ខ្លឹមសារនៃព័ត៌មានក្នុងទម្រង់ឌីជីថល ដែលអាចមើល អាន ស្តាប់ ឬ ទាញយកបាន ក្នុងទម្រង់ជាអត្ថបទ រូបភាពសំឡេង វីដេអូ ។ល។ |
| ២៦ | Digital Government | រដ្ឋាភិបាលឌីជីថល | ដំណើរការនៃការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និង សេវាសាធារណៈតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដូចជាកុំព្យូទ័រ ឧបករណ៍ឆ្លាត និង ប្រព័ន្ធអ៊ីនធឺណិត សំដៅជួយសម្រួលដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋ ការសម្រេចចិត្ត និង ការផ្តល់សេវាជូនប្រជាពលរដ្ឋ វិស័យឯកជន និង ស្ថាប័នពាក់ព័ន្ធនានាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និង បរិយាបន្នកម្ម ។ |
| ២៧ | Digital Identity | អត្តសញ្ញាណឌីជីថល | ព័ត៌មានដែលបញ្ជាក់ពីអត្តសញ្ញាណរូបវន្តបុគ្គល និង នីតិបុគ្គលក្នុងពិភពឌីជីថលដែលព័ត៌មាននេះបានភ្ជាប់ទៅនឹងអត្តសញ្ញាណរូបវន្តបុគ្គល និង នីតិបុគ្គលនៅក្នុងពិភពពិត ។ |
| ២៨ | Digital Literacy | អក្ខរកម្មឌីជីថល | ជំនាញដែលជំរុញសមត្ថភាពឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ សម្រាប់ការសិក្សារៀនសូត្រ កម្សាន្ត ការងារ និង ការប្រាស្រ័យទាក់ទង ។ |
| ២៩ | Digital Platform | ថ្នាលឌីជីថល | កម្មវិធីបច្ចេកវិទ្យាព័ត៌មានបង្កើតបានជាពិភពឌីជីថលបម្រើក្នុងគោលបំណងជាក់លាក់មួយ និង សម្រាប់សម្របសម្រួលអ្នកប្រើប្រាស់ធ្វើអន្តរសកម្ម និង អន្តរប្រតិបត្តិការជាមួយនឹងអ្នកពាក់ព័ន្ធនានា ។ |

| | | | |
|---|---|---|---|
| ៣០ | Digital Signature | ហត្ថលេខាឌីជីថល | ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខី ដែលរួមមាន ហត្ថលេខាអេឡិចត្រូនិក ហត្ថលេខាជីវមាត្រ និង ហត្ថលេខាផ្សេងៗ ។ |
| ៣១ | Digital Transformation | បរិវត្តកម្មឌីជីថល | ការធ្វើសមាហរណកម្មបច្ចេកវិទ្យាឌីជីថលទៅក្នុងគ្រប់ទិដ្ឋភាពនៃធុរកិច្ច សេដ្ឋកិច្ច និង សង្គម សំដៅផ្លាស់ប្តូរការងារបែបប្រពៃណី ឬ មិនសូវមាននវានុវត្តន៍ទៅជាប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីមិនគ្រាន់តែបង្កើនប្រសិទ្ធភាពការងារ ថែមទាំងផ្តល់ឱកាសឱ្យមាននវានុវត្តន៍ថ្មីៗ ក្នុងការសម្រួលដល់ការធ្វើធុរកិច្ច និង ការរស់នៅរបស់មនុស្សជាតិជំនាន់ថ្មី ។ |
| ៣២ | Digital World | ពិភពឌីជីថល | ពិភពនិម្មិតមួយដែលបង្កើតដោយថ្នាលឌីជីថលមានគោលបំណងជាក់លាក់ ក្នុងការផ្តល់អន្តរសកម្មរវាងតួអង្គពាក់ព័ន្ធនានាដោយប្រើប្រាស់អត្តសញ្ញាណឌីជីថល ។ |
| ៣៣ | Digitalization | ឌីជីថលូបនីយកម្ម | ដំណើរការនៃការកែសម្រួលការធ្វើអភិបាលកិច្ច ឬ ធុរកិច្ច ឬ ដំណើរការសកម្មភាពអ្វីមួយឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ។ |
| ៣៤ | Digitization | ឌេទូបនីយកម្ម | ដំណើរការនៃការបំប្លែងទិន្នន័យ និង ព័ត៌មានពីទម្រង់អាណាឡូកទៅជាទម្រង់ឌីជីថល ។ |
| ៣៥ | Digital Divide | គម្លាតឌីជីថល | ភាពខុសគ្នាក្នុងការចាប់យក ឬ ការមានឱកាសចាប់យកបច្ចេកវិទ្យាឌីជីថល ។ |
| ៣៦ | Digital Financial Service | សេវាហិរញ្ញវត្ថុឌីជីថល | បណ្តាសេវាកម្មហិរញ្ញវត្ថុដែលអាចទទួលបាន និង ផ្តល់ឱ្យតាមរយៈបច្ចេកវិទ្យាឌីជីថល ដែលរួមមានការទូទាត់ ឥណទាន ការសន្សំ ការផ្ទេរប្រាក់ និង ធានារ៉ាប់រង ជាដើម ។ |
| ៣៧ | Digital Inclusion | បរិយាបន្នកម្មឌីជីថល | ដំណាក់កាលមួយដែលមនុស្សគ្រប់រូបមានកាលានុវត្តភាពស្មើគ្នាដើម្បីចូលរួមក្នុងកិច្ចការសេដ្ឋកិច្ច និង សង្គម ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ។ |
| ៣៨ | E-commerce | ពាណិជ្ជកម្មតាមប្រព័ន្ធ<br>អេឡិចត្រូនិក | សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬ សេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និង រដ្ឋប្បវេណីព្រមទាំងសកម្មភាព និង ប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក ។ |

| | | | |
|---|---|---|---|
| ៣៩ | Ecosystem | ប្រព័ន្ធអេកូឡូស៊ី | ប្រព័ន្ធទំនាក់ទំនងដែលមានភាពប្រកួតប្រជែងគ្នានៃសមាសភាពពាក់ព័ន្ធមាន មនុស្ស ស្ថាប័ន កម្មវិធី នីតិវិធី អន្តរាគមន៍ ទីផ្សារ ប្រព័ន្ធផ្សព្វផ្សាយ ។ល។ បង្កើតបានជាប្រព័ន្ធមួយអាចគ្រប់គ្រង និង អភិវឌ្ឍខ្លួនឯងបាន ប្រកបដោយចីរភាព ។ |
| ៤០ | E-government | រដ្ឋាភិបាល អេឡិចត្រូនិក | ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ជាពិសេសប្រព័ន្ធអ៊ីនធឺណិត ដោយរាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវរាជរដ្ឋាភិបាលមួយដែលល្អប្រសើរ ។ |
| ៤១ | Electronic Know Your Customer (eKYC) | ការសម្គាល់អតិថិជនឌីជីថល | ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីបង្កើត និង កំណត់អត្តសញ្ញាណរបស់អតិថិជនក្នុងពិភពឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ដោយពឹងផ្អែកលើឯកសារសម្គាល់អត្តសញ្ញាណដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ។ |
| ៤២ | FinTech (Financial Technology) | បច្ចេកវិទ្យាហិរញ្ញវត្ថុ | បច្ចេកវិទ្យា និង នវានុវត្តន៍លើវិស័យហិរញ្ញវត្ថុ ទាំងវិស័យ ធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បង្កើតឡើងដើម្បីឱ្យមានការចូលប្រើប្រាស់ ផ្តល់ និង ទទួលសេវាហិរញ្ញវត្ថុបានទូលំទូលាយ ប្រកបដោយបរិយាបន្នកម្ម ។ |
| ៤៣ | FinTech Regulatory Sandbox | បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ | បរិស្ថានសម្រាប់ឱ្យគ្រឹះស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុសាកល្បងនូវផលិតផល និង សេវារបស់ខ្លួនជាមួយនឹងអតិថិជនពិតប្រាកដ ប៉ុន្តែក្នុងទំហំ និង រយៈពេលកំណត់មួយ មុននឹងធ្វើការដាក់ចេញ និង ការជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយ ។ |
| ៤៤ | Industry 4.0 | ឧស្សាហកម្ម ៤.០ | បរិបទនៃការវិវឌ្ឍឧស្សាហកម្មដែលបច្ចេកវិទ្យាអនុញ្ញាតឱ្យមានការបញ្ចូលគ្នានៃទិន្នន័យពីម៉ាស៊ីន ឧបករណ៍ និង សេនស័រ ពីខ្សែច្រវាក់ផលិតកម្ម និង ពីការប្រើប្រាស់របស់មនុស្ស ហើយដែលផ្តល់ព័ត៌មានច្បាស់លាស់ និង ទាន់ពេល ដល់អ្នកផលិត និង អ្នកពាក់ព័ន្ធ សំដៅធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់ផលិតកម្មទាំងមូល ។ |
| ៤៥ | Internet | អ៊ីនធឺណិត | បណ្តាញកុំព្យូទ័រសកលដែលភ្ជាប់គ្នាតាមរយៈពិធីសារគមនាគមន៍រួមមួយដើម្បីចែករំលែក និង ផ្តល់ព័ត៌មាន ។ |
| ៤៦ | Internet of Things (IoT) | ប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ | ការបំពាក់ឧបករណ៍អ៊ីនធឺណិតទៅនឹងសត្វ មនុស្ស ផ្ទះ អគារ យានយន្ត និង វត្ថុផ្សេងៗទៀត... ដើម្បីប្រតិបត្តិការជាមួយនឹងមជ្ឈមណ្ឌលអ៊ីនធឺណិតនៅគ្រប់ទីកន្លែង គ្រប់ពេលវេលាសម្រាប់បញ្ជូន-ទទួលព័ត៌មាន ។ |

| | | | |
|---|---|---|---|
| ៤៧ | Interoperability | អន្តរប្រតិបត្តិការ (ទៅវិញទៅមក) | សមត្ថភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចធ្វើសន្ទានកម្មជាមួយគ្នាក្នុងការផ្លាស់ប្តូរ និង ការប្រើប្រាស់ទិន្នន័យ ដែលជាទូទៅ កើតឡើងដោយស្វ័យប្រវត្តិក្រោមលក្ខខណ្ឌច្បាស់លាស់ ។ |
| ៤៨ | Kanban | កានបាន | វិធីសាស្ត្រគ្រប់គ្រងការងារក្នុងទម្រង់ជាខ្សែប្រវាក់ផលិតកម្ម កុំឱ្យកំងស្ទះក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម ឬ បរិក្ខារបម្រុង ។ |
| ៤៩ | Last-mile delivery | ការដឹកជញ្ជូនគោលដៅចុងក្រោយ | សេវាដឹកជញ្ជូនពីកន្លែងផ្គត់ផ្គង់ទំនិញ ទៅកាន់គោលដៅចុងក្រោយរបស់អតិថិជនបានយ៉ាងឆាប់រហ័ស ។ |
| ៥០ | National Payment Gateway | ច្រកចេញ-ចូលទូទាត់សងប្រាក់ថ្នាក់ជាតិ | ថ្នាលឌីជីថលសម្រាប់បម្រើដល់ការទូទាត់សងប្រាក់លើសេវាសាធារណៈ ការប្រមូលចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ព្រមទាំងធុរកិច្ចឌីជីថលនានា ។ |
| ៥១ | Network | បណ្តាញ | បណ្តុំឧបករណ៍គមនាគមន៍ដែលអាចធ្វើការផ្ញើទិន្នន័យទៅឱ្យគ្នាទៅវិញទៅមក ។ |
| ៥២ | Network Infrastructure |ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត | ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវា ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ |
| ៥៣ | Operating System | សុស្វវែរផ្លាតហ្វម | ប្រព័ន្ធសុស្វវែរ បង្កើតឡើងសម្រាប់គ្រប់គ្រងកម្មវិធីសុស្វវែរ និង ឧបករណ៍កុំព្យូទ័រ ដើម្បីផ្តល់សេវារួមឱ្យកុំព្យូទ័រ និង ឧបករណ៍ឆ្លាតមានដំណើរការ ។ |
| ៥៤ | Payment Service Institution (Provider) | គ្រឹះស្ថាន (ភ្នាក់ងារ) ផ្តល់សេវាទូទាត់សងប្រាក់ | គ្រឹះស្ថាន (ភ្នាក់ងារ) ផ្តល់សេវាទូទាត់សងប្រាក់ ដែលទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មត្រឹមត្រូវ ។ |
| ៥៥ | Payment System | ប្រព័ន្ធទូទាត់សងប្រាក់ | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអនុញ្ញាតឱ្យមានការទូទាត់ និង ការផ្ទេរប្រាក់ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ និង ធុរកិច្ច ។ |
| ៥៦ | Physical World | ពិភពពិត (ពិភពរូបវន្ត) | ពិភពពិតដែលមនុស្សគ្រប់គ្នាប្រាស្រ័យទាក់ទងគ្នា និង ទទួលបទពិសោធ តាមរយៈឥន្ទ្រិយារម្មណ៍ ។ |
| ៥៧ | Portal | ផតថល | គេហទំព័រមួយប្រភេទដែលប្រមូលផ្តុំ និង សំយោគព័ត៌មានពីច្រើនប្រភពដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងជាក់លាក់មួយ និង ផ្តល់លទ្ធភាពតភ្ជាប់ទៅកាន់គេហទំព័រផ្តល់សេវានានា ។ |
| ៥៨ | Satellite Technology | បច្ចេកវិទ្យាផ្កាយរណប | បច្ចេកវិទ្យាដែលប្រើប្រាស់ផ្កាយរណបក្នុងការបញ្ជូនទិន្នន័យ រូបភាព សំឡេង វីដេអូ និង ព័ត៌មាន ដើម្បីសម្រួលដល់ប្រព័ន្ធទំនាក់ទំនង ។ |

# ឧបសម្ព័ន្ធទី៣៖

# គំនូសបំព្រួញស្តីពីអន្តរសកម្មរវាងតួអង្គសំខាន់ៗ ផ្អែកលើមូលដ្ឋានបច្ចេកវិទ្យាឌីជីថល

រូបភាពទី ៣. គំនូសបំព្រួញស្តីពីអន្តរសកម្មរវាងតួអង្គសំខាន់ៗ ផ្អែកលើមូលដ្ឋានបច្ចេកវិទ្យាឌីជីថល




**បញ្ជិកាទិន្នន័យរូបវន្តបុគ្គល**
- ទិន្នន័យប្រជាជន
- ទិន្នន័យអន្តោប្រវេសន៍
- ទិន្នន័យអប់រំ
- ទិន្នន័យសុខភាព
- ទិន្នន័យធានារ៉ាប់រងសុខភាព
- ទិន្នន័យចំណូល និងពន្ធ
- ទិន្នន័យហានិភ័យឥណទាន
- ទិន្នន័យកសិករ
- ទិន្នន័យបសុសត្វ

**បញ្ជិកាទិន្នន័យអចលនទ្រព្យ**
- ទិន្នន័យអចលនទ្រព្យ
- ទិន្នន័យយានជំនិះ
- ទិន្នន័យភូមិសាស្ត្រ
- ទិន្នន័យនិវាសនជន

**បញ្ជិកាទិន្នន័យអាជីវកម្ម**
- ទិន្នន័យអាជីវកម្ម
- ទិន្នន័យពន្ធដារ និងពន្ធគយ
- ទិន្នន័យការងារ
- ទិន្នន័យពាណិជ្ជកម្មអន្តរជាតិ

**បញ្ជិកាទិន្នន័យរដ្ឋាភិបាល**
- ទិន្នន័យធនធានមនុស្សសាធារណៈ
- ទិន្នន័យហិរញ្ញវត្ថុសាធារណៈ (FMIS)
- ទិន្នន័យលទ្ធកម្មសាធារណៈ
- ទិន្នន័យ ERP
- ទិន្នន័យធនធានធម្មជាតិ
- ទិន្នន័យឯកសាររដ្ឋបាល

*ប្រភព៖ ក្រុមការងារឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

## ឧបសម្ព័ន្ធទី៤៖ គោលការណ៍ និងក្របខណ្ឌកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា

រូបភាពទី ៤. គោលការណ៍ និង ក្របខណ្ឌកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា




ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

## ឧបសម្ព័ន្ធទី៥៖ ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចឌីជីថលប្រទេសកម្ពុជា



# ឧបសម្ព័ន្ធទី៦៖ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទ






## ឧបសម្ព័ន្ធទី៧៖ ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេត






## ឧបសម្ព័ន្ធទី៨៖ Global Competitiveness Index 2018-2019






ឧបសម្ព័ន្ធទី៨៖ Network Readiness Index 2019

# Cambodia

| | Rank (out of 121) | Score |
|---|---|---|
| **Network Readiness Index** | **107** | **32.29** |
| **A. Technology pillar** | **82** | **36.24** |
| 1st sub-pillar: Access | 75 | 58.00 |
| 2nd sub-pillar: Content | 101 | 21.37 |
| 3rd sub-pillar: Future Technologies | 67 | 29.33 |
| **B. People pillar** | **110** | **21.28** |
| 1st sub-pillar: Individuals | 96 | 34.07 |
| 2nd sub-pillar: Businesses | 118 | 9.70 |
| 3rd sub-pillar: Governments | 113 | 20.06 |
| **C. Governance pillar** | **116** | **32.92** |
| 1st sub-pillar: Trust | 119 | 20.23 |
| 2nd sub-pillar: Regulation | 113 | 34.59 |
| 3rd sub-pillar: Inclusion | 109 | 43.93 |
| **D. Impact pillar** | **96** | **38.71** |
| 1st sub-pillar: Economy | 119 | 2.16 |
| 2nd sub-pillar: Quality of Life | 60 | 62.09 |
| 3rd sub-pillar: SDG Contribution | 99 | 51.95 |




## The Network Readiness Index in detail

| INDICATOR | RANK/121 | SCORE |
|---|---|---|
| **A. Technology pillar** | | |
| **1st sub-pillar: Access** | | |
| 1.1.1 Mobile tariffs | 87 | 49.89 |
| 1.1.2 Handset prices | 100 | 29.07 |
| 1.1.3 Households with Internet access | 85 | 35.99 |
| 1.1.4 4G mobile network coverage | 78 | 80.30 |
| 1.1.5 Fixed-broadband subscriptions | 41 | 85.21 |
| 1.1.6 International Internet bandwidth | 72 | 67.57 |
| 1.1.7 Internet access in schools | n/a | n/a |
| **2nd sub-pillar: Content** | | |
| 1.2.1 Digital participation and content creation | - | - |
| 1.2.2 Mobile apps development | 91 | 46.55 |
| 1.2.3 Intellectual property receipts | 85 | 0.06 |
| **3rd sub-pillar: Future Technologies** | | |
| 1.3.1 Availability of latest technologies | 86 | 41.39 |
| 1.3.2 Company investment in emerging technology | 54 | 39.10 |
| 1.3.3 Government procurement of advanced technology products | 72 | 36.85 |
| 1.3.4 ICT PCT patent applications | n/a | n/a |
| 1.3.5 Computer software spending | 97 | 0.00 |
| 1.3.6 Robot density | n/a | n/a |
| **B. People pillar** | | |
| **1st sub-pillar: Individuals** | | |
| 2.1.1 Internet users | 95 | 33.61 |
| 2.1.2 Active mobile-broadband subscriptions | 55 | 31.48 |
| 2.1.3 Use of virtual social networks | 69 | 50.10 |
| 2.1.4 Tertiary enrolment | 97 | 9.07 |
| 2.1.5 Adult literacy rate | 76 | 69.85 |
| 2.1.6 ICT skills | 57 | 10.30 |
| **2nd sub-pillar: Businesses** | | |
| 2.2.1 Firms with website | 109 | 7.27 |
| 2.2.2 Internet shopping | 98 | 3.88 |
| 2.2.3 Professionals | 106 | 6.95 |
| 2.2.4 Technicians and associate professionals | 114 | 3.28 |
| 2.2.5 Extent of staff training | 65 | 36.44 |
| 2.2.6 R&D expenditure by businesses | 81 | 0.40 |
| **3rd sub-pillar: Governments** | | |
| 2.3.1 Government online services | 116 | 16.93 |
| 2.3.2 Publication and use of open data | n/a | n/a |
| 2.3.3 ICT use and government efficiency | 76 | 39.19 |
| 2.3.4 R&D expenditure by governments and higher education | 101 | 4.07 |

| INDICATOR | RANK/121 | SCORE |
|---|---|---|
| **C. Governance pillar** | | |
| **1st sub-pillar: Trust** | | |
| 3.1.1 Rule of law | 117 | 27.91 |
| 3.1.2 Software piracy rate | n/a | n/a |
| 3.1.3 Secure Internet servers | 100 | 37.46 |
| 3.1.4 Cybersecurity | 113 | 15.57 |
| 3.1.5 Online trust and safety | 88 | 0.00 |
| **2nd sub-pillar: Regulation** | | |
| 3.2.1 Regulatory quality | 98 | 40.29 |
| 3.2.2 Ease of doing business | 111 | 41.76 |
| 3.2.3 Legal framework's adaptability to digital business models | 89 | 40.83 |
| 3.2.4 E-commerce legislation | 117 | 0.00 |
| 3.2.5 Social safety net protection | 104 | 21.71 |
| 3.2.6 ICT regulatory environment | 104 | 62.98 |
| **3rd sub-pillar: Inclusion** | | |
| 3.3.1 E-Participation | 118 | 6.97 |
| 3.3.2 Socioeconomic gap in use of digital payments | 84 | 50.34 |
| 3.3.3 Availability of local online content | 77 | 43.24 |
| 3.3.4 Gender gap in Internet use | 20 | 66.71 |
| 3.3.5 Rural gap in use of digital payments | 89 | 52.97 |
| **D. Impact pillar** | | |
| **1st sub-pillar: Economy** | | |
| 4.1.1 Medium and high-tech industry | 119 | 0.00 |
| 4.1.2 High-tech exports | 99 | 3.51 |
| 4.1.3 PCT patent applications | n/a | n/a |
| 4.1.4 Labour productivity per employee | 99 | 2.96 |
| **2nd sub-pillar: Quality of Life** | | |
| 4.2.1 Happiness | 87 | 43.00 |
| 4.2.2 Freedom to make life choices | 2 | 99.51 |
| 4.2.3 Income inequality | n/a | n/a |
| 4.2.4 Healthy life expectancy at birth | 97 | 43.59 |
| **3rd sub-pillar: SDG Contribution** | | |
| 4.3.1 Access to basic services | 109 | 58.94 |
| 4.3.2 Pollution | 78 | 79.40 |
| 4.3.3 Road safety | 78 | 52.81 |
| 4.3.4 Reading proficiency in schools | n/a | n/a |
| 4.3.5 Maths proficiency in schools | n/a | n/a |
| 4.3.6 Use of clean fuels and technology | 106 | 16.67 |

**ឧបសម្ព័ន្ធទី៩ ៖ Network Readiness Index 2020**

PORTULANS INSTITUTE

# Network Readiness Index 2020 Cambodia

*The Network Readiness Index (NRI) is one of the leading global indices on the application and impact of information and communication technology (ICT) in economies around the world. In its latest version of 2020 the NRI Report maps the network-based readiness landscape of 134 economies based on their performances in four different pillars: Technology, People, Governance, and Impact. Each of these pillars is itself comprised of three sub-pillars (see Figure 1) that have been populated by a total of 60 variables.*

**Figure 1: The NRI 2020 model**




**Global NRI position of Cambodia**

Cambodia ranks 104th out of the 134 economies included in the NRI 2020 (Figure 2). Its main strength relates to Technology. The greatest scope for improvement, meanwhile, concerns Governance.

**Figure 2: Cambodia global ranking, overall and by pillar**

